00222028

**Declassified to Public**
**06 September 2012**

D99/3/3

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | ៖ | ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ-០២) |
| **បញ្ជូនទៅ** | ៖ | អង្គបុរេជំនុំជម្រះ |
| **កាលបរិច្ឆេទនៃឯកសារ** | ៖ | ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៨ |
| **ភាគីបញ្ជូន** | ៖ | ការិយាល័យសហព្រះរាជអាជ្ញា |
| **ភាសាដើម** | ៖ | អង់គ្លេស |
| **ប្រភេទឯកសារ** | ៖ | សាធារណៈ |

---

## បណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញា
## ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៨
## លើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច"

---

**<u>បញ្ជូនដោយ៖</u>**

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Robert PETIT

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 05 / SEP / 2008
ម៉ោង (Time/Heure): 11:45
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fuy

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 05 / Sept / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

**<u>ចែកចាយជូន៖</u>**

**អង្គបុរេជំនុំជម្រះ៖**

ចៅក្រម ប្រាក់ គីមសាន

ចៅក្រម Rowan DOWNING

ចៅក្រម ន៉យ ថុល

ចៅក្រម Katinka LAHUIS

ចៅក្រម ហួត វុទ្ធី

**មេធាវីការពារក្តីរបស់ជនត្រូវចោទ**
**ឈ្មោះ កាំង ហ្គេកអ៊ាវ៖**

លោក ការ សាវុត្ថ

លោក François ROUX

**មេធាវីការពារក្តីរបស់**
**ដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក គង់ ពិសី

លោក ហុង គីមសួន

លោក យង់ ផានិត

លោកស្រី Silke STUDZINSKY

**មាតិកា**

**១. សេចក្តីសង្ខេបសំអាងហេតុ** ............ 4
**២. ប្រវត្តិនីតិវិធីដែលពាក់ព័ន្ធ** ............ 5
**៣. បញ្ហាដំបូងៗ** ............ 8
ក. មិនចាំបាច់តម្រូវឲ្យមានសវនាការផ្ទាល់មាត់ទេ ............ 8
ខ. បណ្តឹងឧទ្ធរណ៍ត្រូវតែជាសាធារណៈ ............ 9
គ. វិសាលភាពនៃបណ្តឹងឧទ្ធរណ៍ ............ 9
**៤. ច្បាប់ស្តីពីការបញ្ជូនរឿងទៅជំនុំជម្រះ** ............ 10
ក. ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវមានបទឧក្រិដ្ឋ និងទម្រង់នៃការទទួលខុសត្រូវទាំងអស់ ដែលបានបង្កើតឡើងទៅតាមអង្គហេតុនានា ............ 10
ខ. សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលព័ត៌មានអំពីបទល្មើស និង ទម្រង់នៃការទទួលខុសត្រូវ នៅពេលសវនាការ និង វិធាន ៩៨.២ ............ 18
**៥. ឧទ្ទិករណ៍ទី ១ - ការខកខានមិនបានចោទប្រកាន់ពី បទល្មើសនានាក្រោមច្បាប់ជាតិ** ............ 21
ក. ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បានអនុញ្ញាតឲ្យធ្វើការចោទប្រកាន់ពីបទល្មើសតាមច្បាប់ជាតិ 21
ខ. លក្ខណៈខុសពីគ្នា នៃបទល្មើសតាមច្បាប់ជាតិ ............ 22
គ. អង្គហេតុនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កំណត់បាននូវ បទឧក្រិដ្ឋតាមតាមច្បាប់ជាតិ ............ 25
ឃ. ហានិភ័យមិនចាំបាច់នៃការលើកលែងការចោទប្រកាន់ក្នុងពេលជំនុំជម្រះក្តី ............ 25
ង. អនុសាសន៍ក្នុងការធ្វើវិសោធនកម្មទៅលើដីកាដំណោះស្រាយ ............ 27
**៦. ឧទ្ទិករណ៍ទី ២ - ការខកខានមិនបានចោទប្រកាន់ពី ការប្រព្រឹត្តិតាមរយៈសហកម្មឧក្រិដ្ឋកម្មរួម** ............ 28
ក. ច្បាប់ អ.វ.ត.ក អនុញ្ញាតឲ្យយកការទទួលខុសត្រូវបែបសហកម្មឧក្រិដ្ឋកម្មរួម មកអនុវត្តបាន ............ 32
ខ. អង្គហេតុនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះកំណត់បាននូវការទទួលខុសត្រូវ សហកម្មឧក្រិដ្ឋកម្មរួម ............ 40

គ. ខកខានមិនបានបញ្ចូលសហកម្មឧក្រិដ្ឋកម្មរួមជាការកម្រិតមិនឱ្យអង្គជំនុំជម្រះមានលទ្ធភាព ក្នុងការវាយតម្លៃពេញលេញទៅលើការទទួលខុសត្រូវ ........................................ 43

ឃ. អនុសាសន៍ក្នុងការធ្វើវិសោធនកម្មទៅលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ ........................ 48

**៧. សំណើ**........................................................................................51

## ១. សេចក្តីសង្ខេបសំអាងហេតុ

១. នៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយមួយ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬ ដីកាដំណោះស្រាយ") នៅក្នុងករណីរបស់ជនត្រូវចោទឈ្មោះ កាំង ហ្កេកអ៊ាវ ហៅ ឌុច ("ឌុច")[1] ។ បន្ទាប់ពីបានសរសេរអង្គហេតុជាក់ស្តែងនានាជាទម្រង់មួយយ៉ាងលម្អិតមក[2] សហចៅក្រមស៊ើបអង្កេតបានចេញដីកាបញ្ជូន ឌុច ទៅជំនុំជម្រះអំពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ("អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ")[3] ដោយមានមូលដ្ឋាននៅលើទម្រង់នៃការទទួលខុសត្រូវមួយចំនួន[4] ។

២. អនុលោមតាមវិធាន ៦៧.៥ ៧៣ និង ៧៤.២ នៃវិធានផ្ទៃក្នុងសម្រាប់ អ.វ.ត.ក ("វិធាន") សហព្រះរាជអាជ្ញាប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ពីព្រោះ សហចៅក្រមស៊ើបអង្កេត បានប្រព្រឹត្តនូវកំហុសឆ្គងចំនួនពីរក្នុងផ្នែកច្បាប់ នៅពេលដែលសហចៅក្រមស៊ើបអង្កេត៖

(i) ខកខានមិនបានចេញដីកាបញ្ជូន ឌុច ទៅជំនុំជម្រះ អំពើមនុស្សឃាត និង ទារុណកម្ម ដូចដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ ហើយដែលអាចផ្តន្ទាទោសបានតាមមាត្រា ៣ នៃច្បាប់ស្តីពីការបង្កើតឲ្យមានអ.វ.ត.ក("ឧក្រិដ្ឋកម្មតាមច្បាប់ជាតិ") ទោះបីជាឧក្រិដ្ឋកម្មទាំងនេះត្រូវបានបង្ហាញទាំងស្រុង ដោយអង្គហេតុជាក់ស្តែងនានាដូចដែលបានរកឃើញនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះក៏ដោយ(**ទឡ្ហីករណ៍ទី ១**)។

---

[1] *ករណីរបស់ កាំង ហ្កេកអ៊ាវ ហៅ ឌុច,* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កាំង ហ្កេកអ៊ាវ ហៅ ឌុច, ចុះថ្ងៃទី០៨ សីហា ២០០៨, D99 [*បន្ទាប់ពីនេះទៅហៅថា៖* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ] ។

[2] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌទី ១០-១២៨ ។

[3] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, ផ្នែកទី ៤, "សេចក្តីសម្រេច" ។

[4] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌទី ១៥៣-១៦១ ។

(ii) ខកខានមិនបានចេញដីកាបញ្ជូន **ឌុច** ទៅជំនុំជម្រះ ចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្ម តាមរយៈការចូលរួមនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម(“JCE”) ទោះបីជាទម្រង់នៃការទទួលខុសត្រូវបែបមួយនេះ ត្រូវបានបង្ហាញទាំងស្រុងដោយអង្គហេតុជាក់ស្តែងនានា ដូចដែលបានរកឃើញនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក៏ដោយ **(ទឡ្ហីករណ៍ទី ២)** ។

៣. បើសិនជា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនត្រូវបានកែប្រែទេនោះ ឧក្រិដ្ឋកម្មទាំងអស់ដែលបានចោទប្រកាន់លើ **ឌុច** នឹងមិនត្រូវបានឆ្លុះបញ្ចាំងឲ្យបានគ្រប់គ្រាន់ទេ ហើយនឹងមានហានិភ័យមួយដែលថា អាចនឹងមានការលើកលែងការចោទប្រកាន់ដោយសារមូលហេតុខាងនីតិវិធី ។ អាស្រ័យហេតុនេះ ស្នើឲ្យ អង្គបុរេជំនុំជម្រះ **កែប្រែ**ដីកាបញ្ជូនរឿងទៅជំនុំជម្រះ **ដាក់បញ្ចូល**នូវអំពើមនុស្សឃាត និង ទារុណកម្ម ដោយអនុលោមតាម ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ និងស្នើឲ្យ **ដាក់បញ្ចូល**នូវការប្រព្រឹត្តិឧក្រិដ្ឋកម្មនានាតាមរយៈការចូលរួម នៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម ថាជាទម្រង់មួយនៃការទទួលខុសត្រូវ ។ សហព្រះរាជអាជ្ញា ស្នើដាក់ជូននូវខ្លឹមសារដូចខាងក្រោមដើម្បីកែតម្រូវនូវកំហុសឆ្គងដែលមាននៅក្នុងដីកាដំណោះស្រាយឡើងវិញដូចមាននៅខាងក្រោមនេះ ។

## ២. ប្រវត្តិនីតិវិធីដែលពាក់ព័ន្ធ

៤. នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ សហព្រះរាជអាជ្ញា បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ[5] ដែលបានបើកនូវការស៊ើបសួរមួយប្រឆាំងនឹង **ឌុច** និង បុគ្គលចំនួនបួននាក់ផ្សេងទៀត ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនោះ បានស្នើឲ្យសហចៅក្រមស៊ើបអង្កេតចោទប្រកាន់លើជនសង្ស័យចំនួនប្រាំនាក់អំពីឧក្រិដ្ឋកម្ម៖ ទី១) អំពើមនុស្សឃាត ទារុណកម្ម និង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ទៅតាមក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦, ទី២) ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍, ទី៣) ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, និងទី៤) អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩[6] ។ ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿង

---

[5] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ, ចុះថ្ងៃទី១៨ កក្កដា ២០០៧, D3[*បន្ទាប់ពីនេះទៅហៅថា៖* ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ]។

[6] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ, កថាខណ្ឌទី ១២២ ។

ឲ្យស៊ើបសួរ សហព្រះរាជអាជ្ញា ក៏បានស្នើផងដែរថា ជនសង្ស័យទាំងប្រាំនាក់នោះ គួរតែត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការស៊ើបអង្កេតចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្ម ក្នុងឋានៈជាអ្នកចូលរួមនៅក្នុង សហកម្មឧក្រិដ្ឋកម្មរួម ដែលជាទម្រង់មួយក្នុងចំណោមទម្រង់នៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនានា[7] ។

៥. ការចូលបង្ហាញខ្លួនលើកដំបូងរបស់ **ឌុច** នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ ដោយបានប្រាប់ដល់ **ឌុច** ជាដំបូង អំពីអង្គហេតុដែលបានដាក់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររួចហើយ សហចៅក្រមស៊ើបអង្កេត បានចោទប្រកាន់ **ឌុច** ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[8] ។ នៅថ្ងៃទី០២ ខែតុលា ឆ្នាំ២០០៧ សហចៅក្រមស៊ើបអង្កេត បានចោទប្រកាន់ **ឌុច** បន្ថែមទៀតពីបទ អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ[9] ។ បន្ទាប់ពី សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងថា ពួកខ្លួនបានពិចារណាបិទការស៊ើបសួរ[10] ជាថ្មីម្តងទៀត សហព្រះរាជអាជ្ញាបានស្នើឲ្យ សហចៅក្រមស៊ើបអង្កេត ចោទប្រកាន់ **ឌុច** ពីអំពើមនុស្សឃាត និង ទារុណកម្ម ដោយអនុលោមតាមក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦[11] ។ សហចៅក្រមស៊ើបអង្កេត បានច្រានចោលសំណើនេះ ដោយបានលើកឡើងថា៖ *“[យល់ឃើញថា] ដីកាដំណោះស្រាយនឹងបញ្ជាក់ពីបទល្មើសជាក់លាក់ ដែលត្រូវកំណត់យកសម្រាប់ឧក្រិដ្ឋកម្មនីមួយៗ ដែលបានប្រព្រឹត្តនៅ ស២១ ដែលត្រូវចោទប្រកាន់លើជនត្រូវចោទ និងយល់ឃើញថា នៅក្នុងដំណាក់កាលនេះ ដោយមិនមានភស្តុតាងអ្វីថ្មីនោះ មិនត្រូវបញ្ជាឲ្យមានការបើកការស៊ើបសួរឡើងវិញជាថ្មី ដើម្បីធ្វើការដាក់ឲ្យនៅក្រោមការពិនិត្យបន្ថែមនោះទេ”*[12] ។

---

[7] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ, កថាខណ្ឌទី ១១៦ ។

[8] *ករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច,* កំណត់ហេតុនៃការចូលបង្ហាញខ្លួនដំបូង, ចុះថ្ងៃទី៣១ កក្កដា ២០០៧, D8, ទំព័រទី ២ ។

[9] *ករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច,* កំណត់ហេតុនៃការសួរចម្លើយ, ចុះថ្ងៃទី០២ តុលា ២០០៧, D20, ទំព័រទី ២ ។

[10] *ករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច,* សេចក្តីជូនដំណឹងស្តីពីការបញ្ចប់កិច្ចស៊ើបការ, ចុះថ្ងៃទី១៥ ឧសភា ២០០៨, លេខERN 00189149-00189149, D89 ។

[11] *ករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច,* សំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យចោទប្រកាន់លើឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចំពោះបទឧក្រិដ្ឋកម្មទៅតាមច្បាប់ជាតិ ពីបទ អំពើមនុស្សឃាត និងអំពើទារុណកម្ម ដែលមានចែងក្នុងមាត្រា ៣ នៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញ, ចុះថ្ងៃទី០២ មិថុនា ២០០៨, លេខERN 00194698-00194700, D94 ។

[12] *ករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច,* ដីកាសម្រេចលើពាក្យសុំកិច្ចស៊ើបសួរ, ចុះថ្ងៃទី០៥ មិថុនា ២០០៨, លេខERN 00194703-00194704, D94/I, ទំព័រទី២, *សង្កត់ន័យបន្ថែមដោយគូសបន្ទាត់ពីក្រោម* ។

៦. នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញា បានដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន ដោយបានធ្វើសេចក្តីសន្និដ្ឋានថា ភស្តុតាងដែលមាននៅក្នុងសំណុំរឿង តម្រូវឱ្យគេធ្វើការចោទប្រកាន់ **ឌុច** ពីបទ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ និង ឧក្រិដ្ឋកម្មតាមច្បាប់ជាតិ[13] ។ សហព្រះរាជអាជ្ញា ក៏បានលើកជាសំអាងផងដែរថា ភស្តុតាងដែលមាននៅក្នុងសំណុំរឿង បានលើកឡើងថា **ឌុច** ធ្លាប់បានប្រព្រឹត្តឧក្រិដ្ឋកម្មនៅមន្ទីរស-២១ ក្នុងឋានៈជាអ្នកចូលរួមម្នាក់នៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម ដែលជាទម្រង់មួយក្នុងចំណោមទម្រង់នៃការទទួលខុសត្រូវ[14] ។

៧. នៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៨ ដីកាដំណោះស្រាយមួយត្រូវបានចេញ ដោយបានបញ្ជូន **ឌុច** ទៅជំនុំជម្រះ ពីបទ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ[15] ។ សហចៅក្រមស៊ើបអង្កេត បានបដិសេធមិនព្រមបញ្ជូន **ឌុច** ទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មតាមច្បាប់ជាតិទេ ដោយបានលើកឡើងថា៖ *"អំពើជាក់លាក់មួយចំនួនដែលបានបង្ហាញតាមរយៈការស៊ើបសួរ និងដែលបានកំណត់ជាបទឧក្រិដ្ឋខាងលើអាចត្រូវបានកំណត់យ៉ាងច្បាស់លាស់ផងដែរស្របតាមច្បាប់ជាតិកម្ពុជាជាបទល្មើស មនុស្សឃាត និងទារុណកម្ម ដែលមានចែង [...នៃ] ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ [...] ។ ប៉ុន្តែ អំពើទាំងនេះត្រូវតែទទួលបានការចោទប្រកាន់ក្រោមការកំណត់ប្រភេទបទល្មើស ដែលមានលក្ខណៈខ្ពស់ជាងគេ ដែលនៅក្នុងករណី នៃសំណុំរឿងនេះគឺឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ [ចុះថ្ងៃទី ១២ ខែសីហា] ឆ្នាំ១៩៤៩"*[16] ។ ដីកាដំណោះស្រាយនេះ មិនមានយោងទៅលើការទទួលខុសត្រូវជា សហកម្មឧក្រិដ្ឋកម្មរួម ទាល់តែសោះ ឬជាទម្រង់ ដទៃទៀត ដែលសហចារីបានប្រព្រឹត្តឧក្រិដ្ឋកម្ម ។

---

[13] *ករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច,* វិធាន ៦៦ ដីកាសន្និដ្ឋានស្ថាពរទាក់ទងនឹង កាំង ហ្គេកអ៊ាវ ហៅ ឌុច, ចុះថ្ងៃទី១៨ កក្កដា ២០០៨, D96, កថាខណ្ឌទី ២៧៥.ក ។

[14] *ករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច,* វិធាន ៦៦ ដីកាសន្និដ្ឋានស្ថាពរទាក់ទងនឹង កាំង ហ្គេកអ៊ាវ ហៅ ឌុច, ចុះថ្ងៃទី១៨ កក្កដា ២០០៨, D96, កថាខណ្ឌទី ២៥០ ។

[15] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, ផ្នែកទី ៤, "សេចក្តីសម្រេច" ។

[16] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌទី ១៥២ ។

៨. តាមរយៈការដាក់ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលបានដាក់នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ និង សំណើទៅសហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០៨ ព្រមទាំង ដីកាសន្និដ្ឋានស្ថាពរ ដែលបានដាក់នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញា បានជូនដំណឹងយ៉ាងទូលំទូលាយដល់ជនជាប់ចោទ អំពីសំណើរបស់ខ្លួន ដែលថា **ឌុច** គួរត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មតាមច្បាប់ជាតិគឺ អំពើមនុស្សឃាត និង ទារុណកម្ម ហើយថា **ឌុច** គួរត្រូវបានដាក់ឱ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងឡាយនៅមន្ទីរស-២១ ក្នុងឋានៈជាអ្នកចូលរួមម្នាក់នៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម ។

## ៣. បញ្ហាដំបូងៗ

## ក. មិនចាំបាច់តម្រូវឱ្យមានសវនាការផ្ទាល់មាត់ទេ

៩. បណ្តឹងឧទ្ធរណ៍នេះ មិនចាំបាច់មានសវនាការផ្ទាល់មាត់ទេ ។ សហព្រះរាជអាជ្ញា សន្និដ្ឋានថា ភាគីនានាអាចដាក់សេចក្តីសង្ខេបឱ្យបានគ្រប់គ្រាន់ ស្តីពីបញ្ហាអង្គហេតុ និងអង្គច្បាប់ពាក់ព័ន្ធផ្សេងៗជូនទៅ អង្គបុរេជំនុំជម្រះ តាមរយៈសារណាជាលាយលក្ខអក្សររបស់ខ្លួន ដូចដែលបានអនុញ្ញាតនៅក្នុងសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ ("សេចក្តីណែនាំអនុវត្ត")[17] ហើយដែល អង្គបុរេជំនុំជម្រះ ធ្លាប់បានអនុវត្តពីមុនកន្លងមកហើយ[18] ។ សហព្រះរាជអាជ្ញា ក៏ទទួលស្គាល់ផងដែរអំពីសេចក្តីត្រូវការនូវដំណោះស្រាយមួយឱ្យបានឆាប់រហ័ស អំពីបញ្ហាតាមផ្លូវច្បាប់នានាដែលនៅសេសសល់ ដើម្បីអាចចាប់ផ្តើមបើកសវនាការសាធារណៈឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ។

---

[17] ការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក, សេចក្តីណែនាំអនុវត្ត 01/2007/Rev.1, ចុះថ្ងៃទី០៥ តុលា ២០០៧, មាត្រា ៨.៤ [*បន្ទាប់ពីនេះទៅហៅថា៖* សេចក្តីណែនាំអនុវត្ត] ។

[18] *ករណីរបស់ អៀង សារី,* សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធទៅនឹងការប្រាស្រ័យទាក់ទងគ្នារវាងជនត្រូវចោទនឹងប្រពន្ធរបស់គាត់, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ-០៥), ចុះថ្ងៃទី៣០ មេសា ២០០៨, លេខERN 00184951-00184956, A104/II/7, កថាខណ្ឌទី ៨ ។

D99/3/3

*សំណុំរឿងលេខៈ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ-០២)*

## ខ. បណ្តឹងឧទ្ធរណ៍ត្រូវតែជាសាធារណៈ

១០. វិធាន ៧៧.៦ ចែងថា អង្គបុរេជំនុំជម្រះ អាចសម្រេចថា នីតិវិធីទាំងស្រុង ឬមួយផ្នែកនៃសវនាការ (ហើយបើតាមការពិចារណាគឺ គ្រប់សារណា និងសេចក្តីសម្រេចទាំងអស់) ត្រូវធ្វើឡើងជាសាធារណៈ បើអង្គបុរេជំនុំជម្រះ យល់ឃើញថាដើម្បីជាប្រយោជន៍យុត្តិធម៌ និងមិនធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬវិធានការការពាររបស់តុលាការ ។ សហព្រះរាជអាជ្ញា ស្នើឲ្យ អង្គបុរេជំនុំជម្រះ ចុះផ្សាយបណ្តឹងឧទ្ធរណ៍ជាលាយលក្ខអក្សរនេះ នៅក្នុងវិបសាយរបស់ អ.វ.ត.ក រួមទាំងឯកសារពាក់ព័ន្ធដទៃទៀតដែលបានដាក់ជូន ។ ការធ្វើដូច្នេះ គឺជាការបំរើដល់ផលប្រយោជន៍យុត្តិធម៌ និងមិនមានការខូចខាតដល់សណ្តាប់ធ្នាប់សាធារណៈ ឬ វិធានការការពាររបស់តុលាការទេ ។

## គ. វិសាលភាពនៃបណ្តឹងឧទ្ធរណ៍

១១. នៅក្នុងសេចក្តីសម្រេចថ្មីៗមួយរបស់ សហចៅក្រមស៊ើបអង្កេត ពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងចំពោះដីកាបដិសេធ ដែលប្តឹងទៅ អង្គបុរេជំនុំជម្រះ អំពីការបដិសេធនោះ អង្គបុរេជំនុំជម្រះ បានរកឃើញថា មានកំហុសនីតិវិធីនៅក្នុងបញ្ហានានាដែលភាគីបានលើកឡើង ។ អង្គបុរេជំនុំជម្រះ បានចែងយ៉ាងច្បាស់ថា "អង្គបុរេជំនុំជម្រះមានសមត្ថកិច្ចលើតែពាក្យសុំរបស់ភាគីដែលបានដាក់ជូនតែប៉ុណ្ណោះ"[19] ។ សហព្រះរាជអាជ្ញា ស្នើឲ្យ អង្គបុរេជំនុំជម្រះ អនុវត្តគោលការណ៍ដូចគ្នាចំពោះបណ្តឹងឧទ្ធរណ៍នេះ ។

១២. វិសាលភាពនៃបណ្តឹងឧទ្ធរណ៍នេះគឺ តិចតួច តែជាក់លាក់ ដោយកំរិតត្រឹមតែកំហុសឆ្គងចំនួនពីរក្នុងផ្នែកច្បាប់ ដូចដែលបានរៀបរាប់រួចមកហើយ ។ សហព្រះរាជអាជ្ញា គ្រាន់តែប្តឹងឧទ្ធរណ៍លើការខកខានរបស់ សហចៅក្រមស៊ើបអង្កេត ក្នុងការមិនបានបញ្ជូន **ឌុច** ទៅជំនុំ

[19] *ករណីរបស់ នួន ជា,* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព, D55/I/8, កថាខណ្ឌទី ៣៥ ។

ជម្រះពីឧក្រិដ្ឋកម្មតាមច្បាប់ជាតិ និង ការខកខានរបស់ខ្លួន ក្នុងការមិនបានដាក់បញ្ចូលនូវការទទួលខុសត្រូវជាទម្រង់សហកម្មឧក្រិដ្ឋកម្មរួម ប៉ុណ្ណោះ ។ សហព្រះរាជអាជ្ញា មិនប្តឹងឧទ្ធរណ៍ពីអង្គហេតុជាក់ស្តែងណាមួយដែល សហចៅក្រមស៊ើបអង្កេត បានរកឃើញទេ ។ ទោះជាយ៉ាងដូច្នេះក៏ដោយ សហព្រះរាជអាជ្ញា មិនឯកភាពទាំងស្រុងទៅនឹងរាល់សេចក្តីសម្រេចនីមួយៗ ដែលសហចៅក្រមស៊ើបអង្កេតបានយល់ឃើញទៅតាមភស្តុតាងនៅក្នុងសំណុំរឿងទេ ។ សហព្រះរាជអាជ្ញា រក្សាទុកនូវសិទ្ធិក្នុងការស្នើសុំឲ្យ អង្គបុរេជំនុំជម្រះសម្រេចលើការរកឃើញនូវអង្គហេតុទាំងឡាយ តាមដែលខ្លួនយល់ឃើញថាជាការជាចាំបាច់ដើម្បីឆ្លុះបញ្ចាំងពីទំហំឧក្រិដ្ឋភាពទាំងស្រុងរបស់ **ឌុច** ។

## ៤. ច្បាប់ស្តីពីការបញ្ជូនរឿងទៅជំនុំជម្រះ

### ក. ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវមានបទឧក្រិដ្ឋ និងទម្រង់នៃការទទួលខុសត្រូវទាំងអស់ ដែលបានបង្កើតឡើងទៅតាមអង្គហេតុនានា

១៣. សហព្រះរាជអាជ្ញាសន្និដ្ឋានថា បើសិនសហចៅក្រមស៊ើបអង្កេតពិចារណាថា អង្គហេតុនានាត្រូវបានបង្កើតឡើងសំរាប់បទឧក្រិដ្ឋ ឬទម្រង់នៃការទទួលខុសត្រូវជាក់លាក់ណាមួយនោះ បទឧក្រិដ្ឋ ឬទម្រង់នៃការទទួលខុសត្រូវនោះ ត្រូវតែដាក់បញ្ចូលទៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។

*ឆន្ទានុសិទ្ធិមានកម្រិតដើម្បីធ្វើការចោទប្រកាន់លើបទឧក្រិដ្ឋ និងទម្រង់នៃការទទួលខុសត្រូវផ្សេងៗ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ*

១៤. សហចៅក្រមស៊ើបអង្កេត មានឆន្ទានុសិទ្ធិក្នុងអំឡុងពេលនៃការអនុវត្តន៍កិច្ចស៊ើបសួរ ប៉ុន្តែឆន្ទានុសិទ្ធិនេះ ត្រូវមានកម្រិត[20] ។ ឧទាហរណ៍ ពួកគេមិនអាចបិដសេធមិនធ្វើការស៊ើបសួរ

[20] *សូមមើល* វិធាន ៥៥.៥ ("ក្នុងការដឹកនាំកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតអាចចាត់វិធានការស៊ើបសួរ ដែលនាំទៅរកការបង្ហាញការពិត") ។ ទោះបីមានឆន្ទានុសិទ្ធិដូច្នេះក៏ដោយ វាមិនមែនមិនមានការកម្រិតនោះទេ ពីព្រោះវិធានការស៊ើបសួរ គឺនៅតែត្រូវធ្វើ

ទៅលើបទឧក្រិដ្ឋនានាដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក បានទេ ប្រសិនបើមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[21] ។ ស្រដៀងគ្នានេះដែរ សហចៅក្រមស៊ើបអង្កេតមានឆន្ទានុសិទ្ធិខ្លះ នៅក្នុងការធ្វើសេចក្តីព្រាងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[22] ប៉ុន្តែឆន្ទានុសិទ្ធិដូច្នេះត្រូវបានកម្រិត ។ ការណ៍នេះ ត្រូវបានបង្ហាញឱ្យឃើញតាមរយៈអង្គហេតុដែល សហព្រះរាជអាជ្ញា មានសិទ្ធិប្តឹងឧទ្ធរណ៍លើ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ[23] គឺជាបុព្វសិទ្ធិមួយ ដែលត្រូវបានផ្តល់ឱ្យទៅ សហព្រះរាជអាជ្ញា ដោយសារតែសិទ្ធិរបស់ខ្លួនក្នុងការដាក់ សេចក្តីសន្និដ្ឋានស្ថាពរ[24] និងកាតព្វកិច្ចរបស់ខ្លួនក្នុងការបង្ហាញនូវសក្ខីកម្មឱ្យហួសពីវិមតិសង្ស័យនៅពេលសវនាការ[25] ។

១៥. ឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតកាន់តែខ្លាំងក្លាឡើងនៅពេលណាកំពុងដើរតួរជាអ្នកស្វែងរកការពិត ។ ទោះជាយ៉ាងនេះក្តី ពេលណាពួកគេបានធ្វើការសន្និដ្ឋានបញ្ចប់ថាកិច្ចស៊ើបសួរបង្កើតបាននូវអង្គហេតុជាក់លាក់មួយចំនួនហើយនោះ ពួកគេបានដាក់កម្រិតចំពោះឆន្ទានុសិទ្ធិនៅក្នុងការកំណត់លើផលវិបាកខាងផ្នែកច្បាប់នៃអង្គហេតុនោះ ។ ការដាក់កម្រិតនេះ អាចទាញជាយោបល់ចេញពីមាត្រា ១ នៃកិច្ចព្រមព្រៀងរបស់អ.វ.ត.ក, មាត្រា ១ និង ២៩ នៃច្បាប់អ.វ.ត.ក, វិធាន ៦៧.១ ៦៧.៣ និង ៦៧.៤ នៃវិធានផ្ទៃក្នុង ព្រមទាំង មាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។ ការបកស្រាយដូចនេះ ក៏មានការគាំទ្រដោយនីតិវិធីនានាដែលបានអនុម័តនៅក្នុងប្រព័ន្ធច្បាប់ក្នុងប្រទេសនានាផងដែរ ដូចជា

---

ឡើងដើម្បីបង្ហាញការពិត ។ វាត្រូវតែបានកម្រិតផងដែរ មកត្រឹមតែអង្គហេតុនានាដូចបានកំណត់នៅក្នុង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ។ *សូមមើល* វិធាន ៥៥.២ ។

[21] *សូមមើល* វិធាន ៥៥.១ ("ការស៊ើបសួរត្រូវតែធ្វើដោយខានពុំបានចំពោះឧក្រិដ្ឋកម្ម ដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ") ។

[22] *សូមមើល* វិធាន ៦៧.១ ("ដីកាសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាមិនចងសហចៅក្រមស៊ើបអង្កេតឡើយ") ។

[23] *សូមមើល* វិធាន ៧៤.២ និងជាពិសេសវិធាន ៧៧.១៣.ខ ("ក្នុងករណីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត ប្រសិនបើមិនអាចរកសម្លេងភាគច្រើនដែលតម្រូវបាននោះទេ អង្គបុរេជំនុំជម្រះត្រូវសម្រេចប្តឹងទៅអង្គជំនុំជម្រះសាលាដំបូង ដោយឈរលើមូលដ្ឋានដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត") ។

[24] *សូមមើល* វិធាន ៦៦ ។ វិធានផ្ទៃក្នុងផ្តល់សារៈសំខាន់យ៉ាងខ្លាំងដល់សេចក្តីសន្និដ្ឋាននេះ ដោយបានទុកពេលវេលាយ៉ាងយូរនៅក្នុងការដាក់ឯកសារ ។ ស្រដៀងគ្នានេះដែរ សេចក្តីណែនាំអនុវត្តមិនបានចែងអំពីការកំរិតចំនួនទំព័រសម្រាប់ដីកាសន្និដ្ឋានស្ថាពរទេ ។

[25] *សូមមើល* វិធាន ៨៧.១ ។

ប្រទេសបារាំង និងប្រទេសអាល្លឺម៉ង់ជាដើម ហើយឆ្លុះបញ្ចាំងពីគោលដៅនានា ផ្នែកគោលនយោបាយរបស់តុលាការអន្តរជាតិ ។

១៦. វិធាន៦៧ បង្កើតនូវប្រព័ន្ធមួយដែលអំពើឧក្រិដ្ឋកម្មទាំងអស់ ដែលបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយ ជាពិសេសដែលមិនត្រូវបានលើកលែងការចោទប្រកាន់ ត្រូវនាំទៅដល់ការបញ្ជូនទៅជំនុំជម្រះ ។ វិធាន៦៧.១ ចែងថា សហចៅក្រមស៊ើបអង្កេតត្រូវបញ្ចប់ កិច្ចស៊ើបសួរ តាមរយៈការបញ្ជូនរឿងទៅជំនុំជម្រះ ឬការលើកលែងការចោទប្រកាន់ ។ វិធាន ៦៧.៤ អនុញ្ញាតឲ្យមានការលើកលែងការចោទប្រកាន់មួយផ្នែក ចំពោះចំណុចជាក់លាក់ណាមួយ ចំពោះករណីនោះ ដោយទុកតែចំណែកនៅសេសសល់បញ្ជូនទៅធ្វើការជំនុំជម្រះ ។ ហេតុដូចនេះ កិច្ចស៊ើបសួរអាចបញ្ចប់បាន វៀរលែងតែមានដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដីកាដំណោះស្រាយ ឬដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានការលើកលែងការចោទប្រកាន់មួយផ្នែក "ចំពោះអំពើមួយចំនួន (នៃបទចោទប្រកាន់) ឬប្រឆាំងនឹងបុគ្គលមួយចំនួន" ។ គ្មានដំណោះស្រាយណាផ្សេងពីនេះ ត្រូវបានអនុញ្ញាតចំពោះកិច្ចស៊ើបសួរនោះឡើយ ។

១៧. យោងវិធាន៦៧.៣ នៃវិធានផ្ទៃក្នុង ដីកាលើកលែងការចោទប្រកាន់ ត្រូវបានចេញប្រសិនបើ: (១) អំពើដែលចោទប្រកាន់មិនរាប់ចូលជាបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញ (២) ជនប្រព្រឹត្តបទឧក្រិដ្ឋនោះមិនទាន់កំណត់អត្តសញ្ញាណនៅឡើយ ឬ (៣) ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសជនត្រូវចោទ ។ ដោយការពិនិត្យរួមគ្នាទាំងអស់ទៅលើវិធាន៦៧.១ ៦៧.៣ និង៦៧.៤ បង្ហាញឲ្យឃើញថា បើសិនអំពើទាំងឡាយដែលបានស៊ើបសួរដោយសហចៅក្រមស៊ើបអង្កេត ពិតជារួមបង្កើតបាននូវបទឧក្រិដ្ឋណាមួយដែលស្ថិតនៅក្រោមយុត្តាធិការនៃអ.វ.ត.ក ហើយជនប្រព្រឹត្តបទឧក្រិដ្ឋនោះត្រូវបានកំណត់អត្តសញ្ញាណ ហើយបើមានភស្តុតាងគ្រប់គ្រាន់ដើម្បីគាំទ្រចំពោះការចោទប្រកាន់ សហចៅក្រមស៊ើបអង្កេតត្រូវតែបញ្ជូនជនត្រូវចោទទៅជំនុំជម្រះសំរាប់បទឧក្រិដ្ឋនោះ ។ វិធាន៦៧ មិនអនុញ្ញាតឲ្យសហចៅក្រមស៊ើបអង្កេតធ្វើការសន្និដ្ឋានបញ្ចប់ដែលថា ភស្តុតាងមានគ្រប់គ្រាន់ហើយចំពោះបទឧក្រិដ្ឋណាមួយ ដើម្បីបញ្ចៀសមិនឲ្យមានដីកាលើកលែងការចោទប្រកាន់ ប៉ុន្តែថែមទាំងជ្រើសរើសមិនដាក់បញ្ចូលបទឧក្រិដ្ឋនោះទៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះទៀតផង ។

១៨. ការបកស្រាយទៅលើវិធាន៦៧ នេះ គឺវាមានភាពស៊ីសង្វាក់គ្នាជាមួយនឹងគោលបំណងរបស់ អ.វ.ត.ក ។ មាត្រា១នៃច្បាប់អ.វ.ត.ក និងកិច្ចព្រមព្រៀងចែងថា គោលបំណងជាចំបងរបស់ អ.វ.ត.ក គឺដើម្បី "នាំខ្លួនមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរ" ទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា និងច្បាប់អន្តរជាតិ ដែលបានប្រព្រឹត្តក្នុងអម្លុងថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ៦ មករា ១៩៧៩ ។ មាត្រា២៩ នៃច្បាប់អ.វ.ត.ក បង្ហាញពីគោលបំណងស្រដៀងគ្នានេះដែរ[26] ។ គោលបំណងនេះនឹងត្រូវខកចិត្ត ប្រសិនបើមេដឹកនាំជាន់ខ្ពស់ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត មិនត្រូវបានចោទប្រកាន់ និងនាំខ្លួនទៅវិនិច្ឆ័យទោសទេនោះ បើទោះបីជាសហចៅក្រមស៊ើបអង្កេត បានធ្វើការសន្និដ្ឋាននៅពេលបញ្ចប់កិច្ចស៊ើបសួរថា មានភស្តុតាងគ្រប់គ្រាន់ដើម្បីបញ្ចៀសចេញពីដីកាលើកលែងការចោទប្រកាន់ណាមួយ ក្រោមវិធាន៦៧.៣ ក៏ដោយ ។

១៩. ការបកស្រាយទៅលើវិធាន៦៧នេះ ក៏មានការគាំទ្រដោយអ្នកវិភាគមួយរូបនៃCPC[27]ផងដែរ។ វិធាន៦៧ ឆ្លុះបញ្ចាំងទៅលើបទបញ្ញត្តិជាច្រើននៃមាត្រា២៤៧ នៃCPC[28] ។ ទោះជាយ៉ាងនេះក្តី

[26] មាត្រា២៩ នៃច្បាប់អ.វ.ត.ក ("ជនសង្ស័យណាមួយ ដែលមានផែនការ ញុះញង់ បញ្ជា ប្រព្រឹត្ត ឬជួយនិងជំរុញក្នុងការរៀបចំផែនការ ឬការប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងមាត្រា ៣(ថ្មី), ៤, ៥, ៦, ៧ និងមាត្រា ៨ នៃច្បាប់នេះ ត្រូវទទួលខុសត្រូវជាបុគ្គលចំពោះឧក្រិដ្ឋកម្មនេះ") ។

[27] ក្នុងខណៈដែលវិធានទាំងឡាយរួមបង្កើតបាននូវប្រភព "ជាចំបង" សំរាប់កំណត់ទៅលើដំណើរការនីតិវិធីនៅពោះមុខអ.វ.ត.ក ក្រម CPC អាចនឹងត្រូវធ្វើការពិគ្រោះយោបល់ផងដែរ ប្រសិនបើមានចន្លោះប្រហោងណាមួយនៅក្នុងវិធានទាំងនោះ៖ *សូមមើល ករណីរបស់ នួន ជា* សាលដីកាជាសាធារណៈលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព អង្គបុរេជំនុំជម្រះ ០០២/១៩-០៩-២០០៧/អ.វ.ត.ក/ក.ស.ច.ស (អបជ ០៦) ចុះថ្ងៃទី២៦ សីហា ២០០៨, សំណុំរឿងលេខ: D55/I/8, ERN 00219322-00219333 (ជាភាសាអង់គ្លេស) កថាខណ្ឌទី ១៤-១៥ ។ តាមរបៀបផ្សេងពីនេះ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា អាចនឹងត្រូវបានប្រើប្រាស់ជាមគ្គុទ្ទេសក៏ក្នុងការបកស្រាយវិធាននានា ក្នុងករណីវិធានទាំងនោះមានន័យមិនច្បាស់លាស់ ។ *សូមមើល ករណីរបស់ នួន ជា* សាលដីកាជាសាធារណៈលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព អង្គបុរេជំនុំជម្រះ ០០២/១៩-០៩-២០០៧/អ.វ.ត.ក/ក.ស.ច.ស (អបជ ០៦) ចុះថ្ងៃទី២៦ សីហា ២០០៨, សំណុំរឿងលេខ: D55/I/8, ERN 00219322-00219333 (ជាភាសាអង់គ្លេស) ត្រង់កថាខណ្ឌទី ៣៦ ។

[28] ឧទាហរណ៍ ប្រយោគទីមួយនៃវិធាន៦៧ គឺសំខាន់ដូចគ្នានឹងពីរប្រយោគដំបូងនៃមាត្រា២៤៧។ ប្រយោគទីពីរនៃវិធាន៦៧ មានបង្ហាញនៅក្នុងកថាខ័ណ្ឌទីបួននៃមាត្រា២៤៧ ។ ប្រយោគដំបូងនៃវិធាន៦៧.៤ មានបង្ហាញ ដូចគ្នានឹងប្រយោគទីមួយនៃកថាខ័ណ្ឌទីបួន នៃមាត្រា២៤៧ ។ មានភាពស្រដៀងគ្នាច្រើនទៀត ហើយវាហាក់ដូចជាច្បាស់ណាស់ថា វិធាន៦៧ ត្រូវបានធ្វើឡើងយកតាមមូលដ្ឋាននៃបទញ្ញត្តិនៃមាត្រា២៤៧ ។

វិធាន៦៧ មិនបានគូសបញ្ជាក់ឱ្យបានច្បាស់លាស់ថាតើ សហចៅក្រមស៊ើបអង្កេតមានសិទ្ធិមិនចោទប្រកាន់ចំពោះបទឧក្រិដ្ឋណាមួយឬទេ បើសិនមានភស្តុតាងគ្រប់គ្រាន់ ដើម្បីបញ្ចៀសចេញពីដីកាលើកលែងការចោទប្រកាន់ណាមួយ មាត្រា២៤៧ ចែងថា: "ប្រសិនបើ ចៅក្រមស៊ើបសួរបិទការស៊ើបសួរថា អង្គហេតុនានារួមបង្កើតបានជាបទឧក្រិដ្ឋ បទមជ្ឈិម ឬ បទលហុ ចៅក្រមស៊ើបសួរសម្រេចបញ្ជូនជនត្រូវចោទ ទៅមុខតុលាការជំនុំជម្រះ"[29] ។ ខ្លឹមសារនេះ តម្រូវឱ្យចៅក្រមស៊ើបសួរបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ បើសិនចៅក្រមស៊ើបសួរបិទការស៊ើបសួរដោយសន្និដ្ឋានថា អង្គហេតុទាំងនេះរួមបង្កើតបាននូវបទឧក្រិដ្ឋណាមួយ។ ដោយស្រដៀងគ្នារវាងមាត្រា ២៤៧ និងវិធាន ៦៧ ដូច្នេះមាត្រា និងវិធាននេះ គួរតែត្រូវបានគេបកស្រាយថា មានភាពស៊ីសង្វាក់គ្នា ។

២០. ការបកស្រាយបែបនេះចំពោះវិធាន៦៧ គឺវាស្របគ្នាទៅនឹងនីតិវិធីដែលបានអនុម័តឡើងនៅក្នុងយុត្តាធិការជាតិនានា រួមទាំងប្រព័ន្ធនៃប្រទេសបារាំង និងអាល្លឺម៉ង់ ផងដែរ ។ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ("FCPC") មានចំណែកជាច្រើនដែលដូចគ្នានឹងបទបញ្ញត្តិនានា ទាំងនៅក្នុងវិធាន៦៧ និងមាត្រា២៤៧ នៃ CPC[30] ។ ជាពិសេស FCPC មានបទបញ្ញត្តិស្រដៀងគ្នានឹងមាត្រា២៤៧ ដែលកម្រិតឆន្ទានុសិទ្ធិចំពោះចៅក្រមស៊ើបសួរ នៅពេលណាគាត់បិទការស៊ើបសួរដោយសន្និដ្ឋានថា អង្គហេតុនានារួមបង្កើតបានជាបទឧក្រិដ្ឋណាមួយ[31] ។ មាត្រា ១៧៨ មាត្រា ១៧៩ និងមាត្រា ១៨១ នៃក្រម FCPC ចែងថា: "ប្រសិនបើចៅក្រមយល់ថា អង្គហេតុនានារួមបង្កើតបាននូវបទឧក្រិដ្ឋណាមួយ ចៅក្រមបញ្ជូនរឿងទៅអង្គជំនុំជម្រះ ដែលពាក់ព័ន្ធ..."[32] ។ វិធានទូទៅ ក៏មានលក្ខណៈស្រដៀងគ្នាយ៉ាងច្បាស់ផងដែរ នៅក្នុង

[29] ការបកប្រែក្រៅផ្លូវការពីភាសាបារាំង: "S'il estime que les faits constituent un crime, un délit ou une contravention, le juge d'instruction ordonne le renvoi du mis en examen devant le tribunal." Projet de Code de procédure pénale du Royaume du Cambodge, Version du 7 Juin 2007 adoptée lors de la session plénière de l'Assemblée Nationale, មាត្រា ២៤៧ ។

[30] ឧទាហរណ៍ មាត្រា១៧៧ នៃក្រម FCPC ឆ្លុះបញ្ចាំងពីវិធាន៦៧.៣ និងកថាខ័ណ្ឌទី៣ នៃមាត្រា២៤៧ នៃក្រម CCPC ។ វាមិនមែនជាការភ្ញាក់ផ្អើលនោះទេដែលថា វិធាននានាត្រូវបានធ្វើឡើងយកតាមមូលដ្ឋានដែលមានវិសាលភាពធំធេងនៃក្រម CCPC ហើយ CCPC ក៏ធ្វើឡើងតាមមូលដ្ឋានវិសាលភាពដ៏ធំធេងដែលមាននៅក្នុងក្រម FCPC ដែរ ។

[31] *សូមមើល* ក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង មាត្រា ១៧៨, ១៧៩, ១៨១ ។

[32] "[s]i le juge estime que les faits constituent un crime, il prononce, par ordonnance, le renvoi de l'affaire devant le tribunal compétent."

ក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសអាល្លឺម៉ង់ ដែលការចោទប្រកាន់ត្រូវតែដំណើរការក្នុងស្ថានភាព ដែលមាន "សញ្ញាបង្ហាញពីអង្គហេតុគ្រប់គ្រាន់" បញ្ជាក់ថា បទឧក្រិដ្ឋមួយពិតជាបានកើតឡើងមែន[33] ។

*បំណងប្រាថ្នានៃការចោទប្រកាន់ត្រួតគ្នានៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ*

២១. ការចោទប្រកាន់ត្រួតគ្នា គឺជាការអនុវត្តន៍មួយដែលថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះធ្វើការចោទប្រកាន់ទៅលើជនជាប់ចោទណាម្នាក់ចំពោះបទល្មើសលើសពីមួយ សំរាប់អំពើដូចគ្នាតែមួយ[34] ។ វាជាទម្រង់មួយដែលទទួលបានការអនុញ្ញាតចំពោះការចោទប្រកាន់ ដែលមានលក្ខណៈស្របតាមបទដ្ឋានទាំង តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា ("ICTR") និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គូស្លាវី ("ICTY")[35] ។ វាត្រូវបានគេអនុញ្ញាត បើសិនបទឧក្រិដ្ឋដែលគេបានចោទប្រកាន់ដាច់ឡែកនីមួយៗ តម្រូវឱ្យមានធាតុផ្សំជាក់ស្តែងដែលមិនមាននៅក្នុងបទឧក្រិដ្ឋដែលបានចោទប្រកាន់ដទៃផ្សេងទៀត[36] ។

---

[33] "លើកលែងតែមានការចែងផ្សេងពីនេះក្នុងច្បាប់ ការិយាល័យអយ្យការសាធារណៈ ត្រូវមានកាតព្វកិច្ចចាត់វិធានការលើគ្រប់បទល្មើសព្រហ្មទណ្ឌទាំងអស់ដែលអាចនឹងត្រូវធ្វើការចោទប្រកាន់ បើសិនមានការបង្ហាញអង្គហេតុគ្រប់គ្រាន់", ក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង វាក្យខ័ណ្ឌទី១៥២.២ ។ មានការកម្រិតចំនួនទៅលើការលើកលែងចំពោះវិធាននេះ ។ *សូមមើល ដដែលដូចខាងលើ* វាក្យខ័ណ្ឌទី ១៥៣.១, ១៥៣គ, ១៥៣ង, ១៥៤ក ។

[34] *រដ្ឋអាជ្ញា ទល់នឹង Blagojevic នឹងគូគន.,* សេចក្តីសម្រេចលើញត្តិស្នើសុំរបស់ជនជាប់ចោទឈ្មោះ Blagojevic ដើម្បីលើកលែងការចោទប្រកាន់ត្រួតគ្នា, ករណីរឿងលេខ: IT-02-60-PT, អង្គជំនុំជំម្រះទី II, ចុះថ្ងៃទី៣១ កក្កដា ២០០២ ទំព័រទី៣ ។ *សូមមើលផងដែរ* Antonio Cassesse, *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* (Oxford University Press 2003) ត្រង់ទំព័រទី២១៤-២១៦ (ដែលជាទូទៅធ្វើការពិភាក្សាអំពីការចោទប្រកាន់ត្រួតគ្នា) ។

[35] *រដ្ឋអាជ្ញា ទល់នឹង Delalic នឹងគូគន.,* សាលក្រម, ករណីរឿងលេខ: IT-96-21-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី២០ កុម្ភៈ ២០០១, កថាខណ្ឌទី ៤០០ ។

[36] *ករណីរឿងក្តីរបស់រដ្ឋអាជ្ញា ទល់នឹង Delalic និងគូកន* ។ សាលដីកា ។ សំណុំរឿងលេខ IT-96-21-A អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី២០ កុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌទី ៤១២ ("ត្រូវមានទោសព្រហ្មទណ្ឌជាច្រើនមុខ(ច្រើនករណី)អនុលោមតាមបញ្ញត្តិនៃច្បាប់ផ្សេងខុសៗគ្នា ក៏ប៉ុន្តែដោយផ្អែកលើការប្រព្រឹត្តតែមួយដដែលនោះ អាចអនុញ្ញាតឲ្យធ្វើទៅបានល្គឹកណាតែបញ្ញត្តិនៃច្បាប់និមួយៗដែលពាក់ព័ន្ធនោះ មានធាតុផ្សំជាក់ស្តែងខុសពីធាតុផ្សំដែលមាននៅក្នុងបញ្ញត្តិនៃច្បាប់ផ្សេងមួយទៀតតែប៉ុណ្ណោះ")។ *សូមអានផងដែរ* នូវអត្ថបទរបស់ Antonio Cassese ដែលមានចំណងជើងថា *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* (បោះពុម្ពផ្សាយដោយ Oxford Press University ឆ្នាំ២០០៣) ត្រងទំព័រ ២១៤ (ដែលពិភាក្សាពីទស្សនទាននៃបទល្មើសនានាដែលមានលក្ខណៈស្រាលជាង)។

២២. ការចោទប្រកាន់ត្រួតគ្នា ត្រូវបានគេរកឃើញថា ជាការពេញចិត្ត ដែលយ៉ាងហោចណាស់ក៏សម្រាប់ហេតុផលចំនួនពីរដែរ ។ ទីមួយ នៅមុនពេលសវនាការជំនុំជម្រះ គេមិនអាចកំណត់បានថាតើ អង្គជំនុំជម្រះនឹងទទួលយកធាតុផ្សំជាក់លាក់ណាមួយនៃបទចោទមួយ ដែលមិនត្រូវបានគេបង្កើតឡើងសម្រាប់បទចោទប្រកាន់ដទៃទៀតឬទេ ។ ហេតុដូច្នេះ ការចោទប្រកាន់គួរតែមានលក្ខណៈទូលំទូលាយតាមដែលអាចធ្វើទៅបាន រហូតដល់ក្រោយពេលនៃការបង្ហាញភស្តុតាង[37] ។ ទីពីរ ការចោទប្រកាន់ត្រួតគ្នាអាចនឹងចាំបាច់ដើម្បីឆ្លុះបញ្ចាំងពីភាពត្រឹមត្រូវនៃអំពើឧក្រិដ្ឋទាំងស្រុងរបស់ជនជាប់ចោទ[38] ។ នេះគឺជាទស្សនៈមួយនៃគង្វល់ជាទូទៅដែលថា កិច្ចដំណើរការនីតិវិធី គួរតែឆ្លុះបញ្ចាំងពីភាពត្រឹមត្រូវនៃឧក្រិដ្ឋភាពរបស់ជនជាប់ចោទ[39] ។

---

[37] *រដ្ឋអាជ្ញា ទល់នឹង Delalic និងគូគន.,* សាលក្រម, ករណីរឿងលេខ: IT-96-21-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី២០ កុម្ភៈ ២០០១, កថាខណ្ឌទី ៤០០., ដដែលដូចខាងលើ, មតិដោយឡែក និងការខ្វែងគំនិតរបស់ចៅក្រម David Hunt និងចៅក្រម Mohamed Bennouna, ត្រង់កថាខ័ណ្ឌទី១២ ។ *រដ្ឋអាជ្ញា ទល់នឹង Blagojevic និងគូគន.,* សេចក្តីសម្រេចលើញត្តិស្នើសុំរបស់ជនជាប់ចោទឈ្មោះ Blagojevic ដើម្បីលើកលែងការចោទប្រកាន់, ករណីរឿងលេខ: IT-02-60-PT, អង្គជំនុំជំម្រះទី II, ចុះថ្ងៃទី៣១ កក្កដា ២០០២ ទំព័រទី៣ ។ *រដ្ឋអាជ្ញា ទល់នឹង Musema,* សាលក្រម, ករណីរឿងលេខ: ICTR-96-13-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី១៦ វិច្ឆិកា ២០០១, កថាខណ្ឌទី ៣៤៦-៣៧០ ។ *រដ្ឋអាជ្ញា ទល់នឹង Nahimana និងគូគន.,* សាលក្រម និងការប្រកាសទោស, ករណីរឿងលេខ: ICTR-99-52-T, អង្គជំនុំជំម្រះ, ចុះថ្ងៃទី៣ ធ្នូ ២០០៣ កថាខណ្ឌទី ១០៨៩ ។ *សូមមើលផងដែរ* ករណី Vladimir Tochilovsky, បទចោទ ភស្តុតាង និងជំនួយផ្នែកច្បាប់នៅក្នុងយុត្តាធិការអន្តរជាតិ (Wolf Legal Publisher 2005) ត្រង់ទំព័រទី ២២ (កម្រងករណីរឿង) ។

[38] *រដ្ឋអាជ្ញា ទល់នឹង Krnojelac,* សេចក្តីសម្រេចលើញត្តិបឋមរបស់មេធាវីការពារក្តី ស្តីពីទម្រង់នៃការបញ្ជូនរឿងទៅជំនុំជម្រះ, ករណីរឿងលេខ: IT-97-25-PT, ចុះថ្ងៃទី២៤ កុម្ភៈ ១៩៩៩, កថាខណ្ឌទី ១០ ។ *រដ្ឋអាជ្ញា ទល់នឹង Kayishema និង Ruzindana,* មតិដោយឡែក និងការខ្វែងគំនិតរបស់ចៅក្រម Khan, ករណីរឿងលេខ: ICTR-95-1-T, ចុះថ្ងៃទី២១ ឧសភា ១៩៩៩, កថាខណ្ឌ៥២ ([ការចោទប្រកាន់ត្រួតគ្នា និងការកាត់ទោស] "បញ្ចៀសបានយ៉ាងត្រឹមត្រូវមិនឲ្យចូលទៅក្នុងបញ្ហាជំពាក់ជាក់វិនផ្នែកច្បាប់នៃអំពើ ធាតុផ្សំ ផលប្រយោជន៍សង្គមដែលត្រួតស៊ីគ្នា នៅដំណាក់កាលនៃការកាត់ទោស ។ បែបនេះ វាផ្តោតទៅលើអំពើឧក្រិដ្ឋនៅក្នុងដំណាក់កាលនៃការប្រកាសទោស ។ ធ្វើដូច្នេះ វាធានាថា អំពើដាក់បន្ទុករបស់ជនជាប់ចោទ ត្រូវបានឆ្លុះបញ្ចាំងឲ្យឃើញនូវភាពទាំងស្រុងរបស់វា និងជៀសវាងបានបុរេនិច្ឆ័យតាមរយៈការប្រកាសទោសដែលស្របគ្នា") ។

[39] ក្តីកង្វល់ស្រដៀងគ្នាផ្សេងៗទៀតក៏ត្រូវបានលើកឡើងនៅក្នុងពេលប្រកាសទោស និងការព្រមព្រៀងប្តូរចម្លើយជាមួយការសម្រាលទោស ។ គោលដៅដែលមានលក្ខណៈបន្ទន់ឥរិយាបថនៅក្នុងការប្រកាសទោស នៅតាមបណ្តាតុលាការអន្តរជាតិនានា ត្រូវធានាបានថា ការប្រកាសទោសស្ថាពរ ឆ្លុះបញ្ចាំងពីអំពើឧក្រិដ្ឋទាំងស្រុង និងការទទួលខុសត្រូវទាំងអស់របស់ជនល្មើស ។ *រដ្ឋអាជ្ញា ទល់នឹង Delalic និងគូគន.,* សាលក្រម, ករណីរឿងលេខ: IT-96-21-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី២០ កុម្ភៈ ២០០១, កថាខ័ណ្ឌទី ៤២៩-៤៣០ ។ តុលាការ ICTY បានសម្រេចថា អង្គជំនុំជម្រះអាចពិនិត្យលើការព្រមព្រៀងប្តូរចម្លើយជាមួយការសម្រាលទោស ដែលធ្វើឲ្យមានលក្ខណៈតូចចង្អៀតដល់ការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ ដើម្បីធានាថា បទចោទប្រកាន់ដែលនៅសល់ ឆ្លុះបញ្ចាំងពីអំពើ

២៣. ការចោទប្រកាន់ត្រួតគ្នា គឺពិតជាសមស្របក្នុងការកាត់សេចក្តី លើការរំលោភច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ។ ចំពោះបទឧក្រិដ្ឋបែបនេះ ការអនុវត្តន៍លើកកំពស់ដល់: ការស្វែងរកការពិត ការបង្កើតបាននូវកំណត់ហេតុប្រវត្តិសាស្ត្រត្រឹមត្រូវមួយ ការការពារសិទ្ធិរបស់ជនរងគ្រោះ ការជម្រុញយុត្តិធម៌ ការអប់រំសាធារណៈតាមរយៈការឆ្លុះបញ្ចាំងឲ្យកាន់តែត្រឹមត្រូវនូវឧក្រិដ្ឋភាពរបស់ជនជាប់ចោទ ។ គោលដៅទាំងនេះ គឺជាការសំខាន់សំរាប់តុលាការអន្តរជាតិទាំងអស់ដែលពាក់ព័ន្ធលើបទឧក្រិដ្ឋសាហាវយង់ឃ្នងលើមហាជន រួមទាំង អ.វ.ត.ក ផងដែរ[40] ។ ការបញ្ចូលបទឧក្រិដ្ឋកម្មថ្នាក់ជាតិ និងការទទួលខុសត្រូវលើសហកម្មឧក្រិដ្ឋកម្មរួម នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះ ដូច្នេះវានឹងមានភាពស៊ីសង្វាក់គ្នាជាមួយគោលបំណងទូទៅរបស់ អ.វ.ត.ក ។

---

ឧក្រិដ្ឋទាំងស្រុង ដែលថា បទចោទប្រកាន់ដែលទទួលបានការកម្រិតកាន់តែខ្លាំងនោះនឹងមិនបង្កឲ្យមានកំណត់ហេតុជាប្រវត្តិសាស្ត្រមិនត្រឹមត្រូវនោះឡើយ និងថា ការព្រមព្រៀងនោះត្រូវតែធ្វើឡើងក្នុងផលប្រយោជន៍នៃយុត្តិធម៌ ។ *រដ្ឋអាជ្ញា ទល់នឹង Momir Nikolic,* សាលក្រមប្រកាស់ទោស, ករណីរឿងលេខ: IT-02-60/1-S, អង្គជំនុំជម្រះ, ចុះថ្ងៃទី២ ធ្នូ ២០០៣, កថាខ័ណ្ឌទី ៥០, ៥២, ៥៤, ៦៣, ៦៧ ។

[40] *សូមមើល* ដូចជាស្នាដៃនិពន្ធរបស់ Cherif Bassiouni, ដែលមានចំណងជើងថា *"ស្វែងរកសន្តិភាព និង សម្រេចឱ្យបានយុត្តិធម៌: តម្រូវការចាំបាច់ឱ្យមានការទទួលខុសត្រូវ"* 59 Law and Contemp. Probe 9 (1996) ត្រង់ទំព័រ ២៤ (សង្កត់ធ្ងន់អំពីសារសំខាន់នៃការបង្កើត "ការពិតដ៏សំខាន់បំផុត" នៅក្នុងស្ថានភាពក្រោយពីមានជម្លោះប្រយោជន៍ដើម្បីផ្តល់នូវកំណត់ប្រវត្តិសាស្ត្រមួយ និងការបង្ហាញភាពគ្មានទោសរបស់ជនរងគ្រោះ)។ សូមមើលផងដែរនូវស្នាដៃនិពន្ធរបស់ Mark W. Janis ដែលមានចំណងជើងថា "សន្និសីទអ្នកជំនាញការ: ច្បាប់ សង្គ្រាម និង សិទ្ធិមនុស្ស: តុលាការអន្តរជាតិ និង មរតកនៃ នូរឹមប៊ឺក: ប្រយោជន៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ 12 Conn. J. ច្បាប់អន្តរជាតិ 161 ត្រង់ទំព័រទី១៦៣-១៧០ (ដែលលើកឡើងខ្លីៗអំពីមុខងារចម្បងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិក្នុងនោះរួមមាន: ការសម្រេចបានយុត្តិធម៌ និង ការផ្តន្ទាទោស ការរាងចាល ការទុកជាឯកសារ និងការអភិវឌ្ឍន៍ទៅមុខនៃច្បាប់អន្តរជាតិ)។ សក្តានុពលនៃតុលាការព្រហ្មទណ្ឌអន្តរជាតិក្នុងការផ្តល់នូវរង្វាស់យុត្តិធម៌ដល់ជនរងគ្រោះរួចហើយជម្រុញឱ្យមានការកែប្រែសង្គមកាន់តែទូលំទូលាយក៏ត្រូវបានពិចារណាផងដែរនៅក្នុងស្នាដៃនិពន្ធរបស់Alexander Greenawalt ដែលមានចំណង ជើងថា *"យុត្តិធម៌ដែលគ្មាននយោបាយ?" ឆន្ទានុសិទ្ធិអយ្យការ និង តុលាការព្រហ្មទណ្ឌអន្តរជាតិ* 39 N.Y.U.J. ច្បាប់អន្តរជាតិ និង នយោបាយ 583 ត្រង់ទំព័រ ៦០១-៦០២។ អ.វ.ត.ក ត្រូវបានរៀបចំឡើងដើម្បីជម្រុញទៅមុខនូវគោលបំណងដូចគ្នានេះជាច្រើន ។

## ខ. សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលព័ត៌មានអំពីបទល្មើស និង ទម្រង់នៃការទទួលខុសត្រូវនៅពេលសវនាការ និង វិធាន ៩៨.២

២៤. មាត្រា ៣៥ (ថ្មី) នៃច្បាប់ អ.វ.ត.ក តម្រូវថា ជនជាប់ចោទត្រូវទទួលព័ត៌មាន "ភ្លាមៗ និង លំអិត" អំពីប្រភេទ និង មូលហេតុនៃការចោទប្រកាន់ចំពោះខ្លួន និង មានពេលវេលា និង លក្ខណៈគ្រប់គ្រាន់ដើម្បីរៀបចំការការពារខ្លួន ។ ប្រការនេះបានរួមបញ្ចូលនូវការធានាជាអប្បបរមាដែលផ្ដល់ដល់ជនជាប់ចោទអនុលោមតាមមាត្រា១៤ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ (ICCPR)[41] ។

២៥. នៅតុលាការផ្សេងៗដែលធ្វើការចោទប្រកាន់ចំពោះបទឧក្រិដ្ឋប្រហាក់ប្រហែលនឹង អ.វ.ត.ក ការខកខានមិនបានចោទប្រកាន់ជនជាប់ចោទណាម្នាក់ ពីបទឧក្រិដ្ឋដែលបទឧក្រិដ្ឋទាំងនោះក្រោយមកត្រូវបានយកមកជំនុំជម្រះ អាចចាត់ទុកថា ជាការរំលោភលើសិទ្ធិរបស់គាត់ក្នុងការដឹងអំពីប្រភេទនៃរឿងក្ដីប្រឆាំងនឹងរូបគាត់ និង សិទ្ធិទទួលបានពេលវេលាគ្រប់គ្រាន់ក្នុងការរៀបចំការការពារខ្លួន ។ យុត្តិសាស្ត្រនៃតុលាការទាំងនេះ ផ្ដល់នូវការណែនាំមួយចំនួនក្នុងការបកស្រាយអំពីសិទ្ធិដែលមាននៅក្នុងមាត្រា១៤៖

(i) ក្នុងការកំណត់ពីបទចោទប្រកាន់អ្វីមួយមកលើរូបគាត់ ជនជាប់ចោទគួរតែទទួលព័ត៌មាន ភ្លាមៗនិងជាលំអិតអំពីប្រភេទ មូលហេតុ និងខ្លឹមសារនៃបទចោទដែលគាត់ត្រូវទទួល ។ ដីកាចោទប្រកាន់មួយមានលក្ខណៈខ្វះចន្លោះជាសារវ័ន្ត ប្រសិនបើដីកានោះមិនបានបញ្ជាក់អំពីទិដ្ឋភាពសំខាន់ៗនៃរឿងក្ដីនោះ[42] ។ ទាំងនេះគឺជា "អង្គហេតុ

[41] *សូមមើល* កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ មាត្រា១៤(៣)។ បន្ថែមពីលើនេះទៀត មាត្រា៣៣ ថ្មី នៃច្បាប់ អ.វ.ត.ក ចែងថា អ.វ.ត.ក ត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនសមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និង ដំណើរការសមស្របនៃច្បាប់ដូចដែលបានចែងនៅក្នុងមាត្រា១៤ និង ១៥ នៃអនុសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ។

[42] រឿងក្ដី *Prosecutor v. Norman et al.*, សេចក្ដីសម្រេចស្ដីអំពីសេចក្ដីស្នើទី១របស់ជនជាប់ចោទសុំសេវាជូនដីកាតុលាការនិងការនាំខ្លួនមកឆ្លើយនៅមុខតុលាការស្ដីអំពីដីកាចោទប្រកាន់, សំណុំរឿងលេខ SCSL-04-14-T ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៤ កថាខណ្ឌ

សំខាន់ៗ" ដែលត្រូវលើកយកមកសំអាងនៅក្នុងដីកាចោទប្រកាន់[43] ។ ប្រភេទនៃបទចោទ សំដៅលើនីតិសម្បទាចំៗច្បាស់លាស់នៃបទល្មើសនោះ ហើយមូលហេតុនៃការចោទប្រកាន់សំដៅដល់អង្គហេតុនានាដែលជាមូលដ្ឋានសំអាង[44] ។

(ii) ទម្រង់នៃការទទួលខុសត្រូវដែលបានលើកឡើងរបស់ជនជាប់ចោទនៅក្នុងបទឧក្រិដ្ឋមួយគួរតែលាតត្រដាងឱ្យបានច្បាស់នៅក្នុងដីកាចោទប្រកាន់[45] ។ ប្រសិនបើការចោទប្រកាន់មានចេតនាចង់ផ្អែកលើសហកម្មឧក្រិដ្ឋកម្មរួម ដើម្បីដាក់ឱ្យជនជាប់ចោទទទួលខុសត្រូវ ក្នុងលក្ខណៈជាចារីដើមគំនិតមួយជាជាងអ្នកសមគំនិត ដីកាចោទប្រកាន់គួរតែលើកមកសំអាងអំពីចំណុចនេះ ក្នុងលក្ខណៈច្បាស់លាស់ហើយកំណត់ ឱ្យបានច្បាស់អំពីទម្រង់នៃសហកម្មឧក្រិដ្ឋកម្មរួមដែលព្រះរាជអាជ្ញាយកជាមូលដ្ឋានបង្អែក[46] ។ ក្នុងករណីសហកម្មឧក្រិដ្ឋកម្មរួម ជនជាប់ចោទត្រូវទទួលព័ត៌មានពីដីកាចោទប្រកាន់នេះអំពី (១) លក្ខណៈនៃគោលបំណងនៃសហកម្មឧក្រិដ្ឋ-កម្មរួម (២) អំឡុងពេលដែលសហកម្មឧក្រិដ្ឋកម្មរួមមានអត្ថិភាពចុងក្រោយ និង (៣) អត្តសញ្ញាណនៃអ្នកដែលចូលរួមពាក់ព័ន្ធនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម[47] ។

---

២៣; រឿងក្តី *Prosecutor v. Halilovic,* សេចក្តីសម្រេចស្តីអំពីសំណើរបស់អយ្យការសុំការអនុញ្ញាតកែប្រែដីកាចោទប្រកាន់, សំណុំរឿងលេខ IT-01-48-PT ថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ ១៣ ។

[43] រឿងក្តី *Prosecutor v. Brdanin and Talic,* សេចក្តីសម្រេចស្តីអំពីការជំទាស់ដោយ Radislav Brdanin ទៅនឹងទម្រង់នៃដីកាចោទប្រកាន់ដែលបានធ្វើវិសោធនកម្ម, សំណុំរឿងលេខ IT-99-36-PT, អង្គជំនុំជម្រះសាលាដំបូង ICTY ថ្ងៃទី២៣ កុម្ភៈ ២០០១ កថាខណ្ឌ ១៣។

[44] រឿងក្តី *Prosecutor v. Ntagerura,* សាលក្រម និង ការសម្រេចទោស, សំណុំរឿងលេខ ICTR-99-46-T, អង្គជំនុំជម្រះសាលាដំបូង ICTR ថ្ងៃទី២៥ កុម្ភៈ ២០០៤ កថាខណ្ឌទី ២៨ និង ៣១ ។

[45] រឿងក្តី *Prosecutor v. Kordic and Cerkez,* សាលដីកា, សំណុំរឿងលេខ IT-95-14-2A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY ថ្ងៃទី១៧ ធ្នូ ២០០៤ កថាខណ្ឌទី ១២៨ ។

[46] រឿងក្តី *Prosecutor v. Ntagerura, សាលក្រម និង ការសម្រេចទោស,* សំណុំរឿងលេខ ICTR-99-46-T អង្គជំនុំជម្រះសាលាដំបូង ICTR ថ្ងៃទី២៥ កុម្ភៈ ២០០៤ កថាខណ្ឌទី ៣៤; រឿងក្តី Prosecutor v. Limaj, សេចក្តីសម្រេចស្តីអំពីសំណើរបស់អយ្យការក្នុងការធ្វើវិសោធនកម្មទៅលើដីកាចោទប្រកាន់ដែលបានធ្វើវិសោធនកម្មរួច សំណុំរឿងលេខ IT-03-66-PT, អង្គជំនុំជម្រះសាលាដំបូង ICTY ថ្ងៃទី១២ កុម្ភៈ ២០០៤ កថាខណ្ឌទី ១៨ ។

[47] រឿងក្តី *Prosecutor v. Niyitegeka,* សាលដីកា, សំណុំរឿងលេខ ICTR-96-14-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTR ថ្ងៃទី០៩ កក្កដា ២០០៤ កថាខណ្ឌទី ១៩៣ ។

២៦. តាមវិធាន ៩៨(២) អង្គជំនុំជម្រះសាលាដំបូងអាច "កែប្រែការកំណត់បទចោទដូចដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះជាថ្មីឡើងវិញ ដរាបណាមិនមានធាតុផ្សំណាថ្មីទៀតសំខាន់ត្រូវបានដាក់បញ្ចូលទេនោះ" ។ ប្រសិនបើ វិធាន ៩៨(២) ត្រូវបានបកស្រាយក្នុងលក្ខណៈចង្អៀតបន្តិច វាអាចអនុញ្ញាតឱ្យកែប្រែការកំណត់បទចោទជាថ្មីឡើងវិញបានតែក្នុងករណីមិនមានធាតុផ្សំណាថ្មីតាមច្បាប់ដែលមកពីបទល្មើសនានាដែលបានចោទនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះតែប៉ុណ្ណោះ។ ប្រសិនបើដីកាបញ្ជូនទៅជំនុំជម្រះ ខកខានមិនបានចោទប្រកាន់ **ឌុច** អំពីបទល្មើសនានាក្រោមច្បាប់ជាតិទេនោះ ការបកស្រាយវិធាន៩៨ (២) បែបនេះ អាចនឹងរារាំងអង្គជំនុំជម្រះសាលាដំបូងមិនឱ្យកំណត់អំពីបទចោទទាំងនោះថាជាបទល្មើសក្រោមច្បាប់ជាតិបានទេ ពីព្រោះបទមនុស្សឃាត និង ទារុណកម្មក្រោមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មានធាតុផ្សំតាមច្បាប់ផ្សេងគ្នា បើប្រៀបធៀបទៅនឹង អំពើមនុស្សឃាត និង ការធ្វើទារុណកម្មក្នុងនាមជាបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ហើយនិងអំពើមនុស្សឃាតដោយចេតនា និង ការធ្វើទារុណកម្មក្នុងនាមជាអំពើបំពារបំពានធ្ងន់ធ្ងរ ដូចដែលបានពិភាក្សានៅខាងក្រោម។ ស្រដៀងគ្នា នេះដែរ ប្រសិនបើដីកាបញ្ជូនរឿងទៅជំនុំជម្រះខកខានមិនបានចោទ **ឌុច** បន្ថែមពីការប្រព្រឹត្តិបទល្មើសដែលចោទតាមរយៈសហកម្មឧក្រិដ្ឋកម្មរួមទេនោះ អង្គជំនុំជម្រះសាលាដំបូងអាចគិតថាខ្លួនឯងត្រូវបានរារាំងមិនឱ្យអនុវត្តនូវទម្រង់នៃការទទួលខុសត្រូវនេះពីព្រោះវាមានធាតុផ្សំច្បាប់ខុសប្លែកពីទម្រង់នៃការទទួលខុសត្រូវផ្សេងទៀត ដូចដែលបានពិភាក្សាខាងក្រោម ។

២៧. ប្រសិនបើបកស្រាយវិធាន ៩៨ (២) ឱ្យបានទូលំទូលាយជាងនេះបន្តិច វាមុខជានឹងអនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការកែប្រែការកំណត់បទចោទឡើងវិញស្របតាមច្បាប់ ឬ ទម្រង់នៃការទទួលខុសត្រូវជាថ្មីនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះឡើងវិញ ដរាបណាបទចោទថ្មី ឬ ទម្រង់នៃការទទួលខុសថ្មីនោះ ពុំមានធាតុផ្សំ*ខាងអង្គហេតុណា*ថ្មីដែលមិនស្ថិតនៅក្នុងវិសាលភាពនៃការស៊ើបអង្កេតនោះទេ ។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងពេញចិត្តនឹងការបកស្រាយបែបនេះនោះ ការខកខានរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការចោទប្រកាន់ឱ្យបានជាក់លាក់ពីបទល្មើសផ្សេងៗក្រោមច្បាប់ជាតិនិងពីទម្រង់នៃការទទួលខុស

ត្រូវតាមសហកម្មឧក្រិដ្ឋកម្មរួមនោះ គឺនឹងមិនរារាំងដល់ សហព្រះរាជអាជ្ញា មិនឱ្យស្នើដាក់បញ្ចូលនូវនីតិសម្បទាខាងនេះនៅក្នុងពេលសវនាការឡើយ។

២៨. ដោយហេតុថា សហព្រះរាជអាជ្ញា ពុំអាចទាយទុកជាមុនអំពីវិធីក្នុងការដោះស្រាយរបស់អង្គជំនុំជម្រះសាលាដំបូងចំពោះវិធាន៩៨(២)បាននោះ សហព្រះរាជអាជ្ញា ធ្វើសេចក្តីសន្និដ្ឋានថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ គួរតែត្រូវបានធ្វើវិសោធនកម្មដើម្បីនឹងដាក់បញ្ចូលបទល្មើសនានាក្រោមច្បាប់ជាតិ និង ការទទួលខុសត្រូវតាមទម្រង់សហកម្មឧក្រិដ្ឋកម្មរួម ដើម្បីនឹងធានាឱ្យប្រាកដថា សហព្រះរាជអាជ្ញា មានលទ្ធភាពអាចលើកឡើងនូវបញ្ហានេះនៅក្នុងពេលសវនាការបាន។

## ៥. ឧទ្ធរណ៍ទី ១
## ការខកខានមិនបានចោទប្រកាន់ពីបទល្មើសនានាក្រោមច្បាប់ជាតិ
### ក. ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បានអនុញ្ញាតឱ្យធ្វើការចោទប្រកាន់ពីបទល្មើសតាមច្បាប់ជាតិ

២៩. មាត្រា ៣ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បានអនុញ្ញាតយ៉ាងច្បាស់ឱ្យចោទប្រកាន់ជនសង្ស័យនានាពីបទមនុស្សឃាត ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញខាងសាសនាដែលផ្ទុយនឹងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦។

៣០. នៅក្នុងតុលាការ អ.វ.ត.ក មិនមានឋានានុក្រមនៃបទល្មើសនោះទេ។ នៅក្នុងមាត្រា ៣ ដល់មាត្រា ៨ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មានបញ្ជីនៃបទល្មើសនានាដែលស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការនេះប៉ុន្តែមិនមានសញ្ញាណាមួយដែលបង្ហាញថាមានបទល្មើសណាមួយមានសារៈសំខាន់ជាងបទល្មើសផ្សេងៗទៀតនោះទេ[48] ។ តាមពិត ភាពដែលផ្ទុយពីនេះ គឺហាក់ដូចជាការពិតទៅវិញ ។ មាត្រា ១ និង ២ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែល

[48] កថាខណ្ឌទី ១៥២ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះបានឱ្យដឹងថា មូលហេតុចំបងដែល សហចៅក្រមស៊ើបអង្កេត បានបដិសេធមិនព្រមចោទប្រកាន់ **ឌុច** ពីបទល្មើសផ្សេងៗក្រោមច្បាប់ជាតិនោះ គឺមកតែពីមានជំនឿថាបទល្មើសនានាក្រោមច្បាប់ជាតិ "មានចំណាត់ថ្នាក់តាមច្បាប់" ទាបជាងបទល្មើនានាក្រមច្បាប់អន្តរជាតិ។

បានដាក់ច្បាប់ព្រហ្មទណ្ឌរបស់កម្ពុជា ឱ្យស្ថិតនៅក្នុងលំដាប់ស្មើគ្នាជាមួយនិងបទល្មើសនានាក្រោមច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ហើយតាមពិតទៅ គ្រប់បទល្មើសទាំងអស់គឺសុទ្ធតែមានទោសបញ្ញត្តិដូចគ្នា[49] ។ អ្នកធ្វើសេចក្តីអត្ថាធិប្បាយខ្លះបានលើកជាអនុសាសន៍ថា ការសម្រេចក្នុងការដាក់បទល្មើសក្រោមច្បាប់ជាតិមុនគេក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក នោះ គឺ "ជាការគិតគូរយកចិត្តទុកដាក់មួយ ដើម្បីសង្កត់ធ្ងន់ចំពោះការណ៍ដែលថា នៅក្នុងពេលជំនុំជម្រះក្តីនឹងមានការលាយបញ្ចូលគ្នាទាំងច្បាប់ជាតិ និងច្បាប់អន្តរជាតិផង"[50] រីឯអ្នកធ្វើសេចក្តីអត្ថាធិប្បាយផ្សេងទៀតបានប្រកែកថា ការចោទប្រកាន់ពីបទល្មើសក្រោមច្បាប់ជាតិនឹងជួយលើកកំពស់នូវអត្ថន័យនៃ "ភាពជាម្ចាស់កម្មសិទ្ធិ" នៃដំណើរការនីតិវិធីសម្រាប់តុលាការកម្ពុជា និងសម្រាប់ប្រជាជនកម្ពុជាទាំងមូល[51]។

## ខ. លក្ខណៈខុសពីគ្នា នៃបទល្មើសតាមច្បាប់ជាតិ

៣១. ការសម្រេចរបស់ សហចៅក្រមស៊ើបអង្កេត ដែលមិនចោទប្រកាន់ **ឌុច** ពីបទល្មើសផ្សេងៗក្រោមច្បាប់ជាតិនោះ គឺដោយផ្អែកលើមូលដ្ឋាននៃគោលគំនិតថា បទល្មើសក្រោមច្បាប់ជាតិគឺត្រូវបានដាក់បញ្ចូលទៅក្រោមបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងនៅក្នុងអំពើបំពារបំពានធ្ងន់ធ្ងរនានា ដែលតំណាងឱ្យ "ចំណាត់ថ្នាក់កំរិតខ្ពស់បំផុតនៅក្នុងច្បាប់ដែលមានស្រាប់"[52] នូវអង្គហេតុនានាដែលបានរកឃើញនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ សហព្រះរាជអាជ្ញាសូមសន្និដ្ឋានថា សេចក្តីសន្និដ្ឋានបែបនេះគឺជាការខុស ដោយមានមូលហេតុចំនួនបី (៣) ។ ទី១ ដូចបានលើកឡើងពិភាក្សាខាងលើ គឺគ្មានឋានានុក្រមរវាងបទល្មើស ហើយនិងបទល្មើសនោះទេនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ហើយគេក៏មិនអាចនិយាយថា បទមនុស្សឃាត

---

[49] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៣៩ ។

[50] ទំព័រ ២២២ ជំពូកទី ១១ ការសម្រេចនៅទីបញ្ចប់ថាត្រូវមានទោស ។ អត្ថបទរបស់លោកស្រី Helen Javish និងលោក Tom Fawthrop ដែលមានចំណងជើងថា: "តើគេចពីបទប្រល័យពូជសាសន៍ឬ? យុត្តិធម៌ដែលពិបាកយល់ និងតុលាការខ្មែរក្រហម" សារព័ត៌មាន Pluto Press ដែលបោះពុម្ពផ្សាយដោយ Chase Publishing Service ប្រទេសអង់គ្លេស ក្នុងឆ្នាំ២០០៤ ។

[51] Etelle Higonnet, *ការរៀបចំរចនាសម្ព័ន្ធនៃតុលាការកូនកាត់ឡើងវិញ: ការផ្តល់អំណាចផ្តល់អំណាចផ្ទៃក្នុង និងការកែទម្រង់ផ្នែកយុត្តិធម៌ព្រហ្មទណ្ឌថ្នាក់ជាតិ* លេខ២៣ ទស្សនាវដ្តី Arizona ស្តីពីច្បាប់អន្តរជាតិ និងការប្រៀបធៀបគ្នា៣៤៧ ។

[52] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌទី ១៥២ ។

និងការធ្វើទារុណកម្មដែលផ្ទុយនឹងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ គឺជាបទល្មើសដែលមានលក្ខណៈ "ស្រាលជាង" បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬអំពើបំពារបំពានធ្ងន់ធ្ងរនានាបានដែរ ។ ទី២ ការបកស្រាយដែលសហចៅក្រមស៊ើបអង្កេតបានអនុម័ត មានបង្កប់ន័យថា បទឧក្រិដ្ឋកម្មតាមច្បាប់ជាតិទាំងនេះ អាចនឹងមិនត្រូវបានចោទប្រកាន់នៅចំពោះមុខ អ.វ.ត.ក ជារៀងរហូត ។

៣២. ទី៣ បទល្មើសនីមួយៗក្រោមច្បាប់អន្តរជាតិដែលមានធាតុផ្សំ ដែលមិនមាននៅក្នុងបទល្មើសនានាក្រោមច្បាប់ជាតិទេ។ ការធ្វើទារុណកម្ម និងអំពើមនុស្សឃាត នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយ គឺតម្រូវឱ្យមានធាតុផ្សំខាងយុត្តាធិការដែលគ្មាននៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ទេ។ ស្រដៀងគ្នានេះដែរ ការធ្វើទារុណកម្ម និងអំពើមនុស្សឃាតដោយចេតនាក្នុងនាមជាអំពើបំពារបំពានធ្ងន់ធ្ងរទៅលើអនុសញ្ញានានានៃទីក្រុងហ្សឺណែវ ក៏តម្រូវឱ្យមានធាតុផ្សំខាងយុត្តាធិការដែលមិនមាននៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដែរ។ អាស្រ័យហេតុនេះ បទល្មើសក្រោមច្បាប់អន្តរជាតិនីមួយៗគឺតម្រូវឱ្យមានសក្ខីកម្មជាធាតុផ្សំណាមួយដែលនៅក្នុងការរំលោភបំពានលើក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មិនបានតម្រូវឱ្យមាន។

៣៣. បទល្មើសនីមួយៗក្រោមច្បាប់ជាតិ ក៏មានធាតុផ្សំណាមួយដែលមិនមាននៅក្នុងបទល្មើសក្រោមច្បាប់អន្តរជាតិដែរ។ ការធ្វើទារុណកម្មក្រោមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ កើតឡើងនៅពេលដែលអំពើនៃការធ្វើទារុណកម្មត្រូវបានប្រព្រឹត្ត ឬមួយៈ (១) ដោយមានចេតនាដើម្បីឱ្យបានទទួលនូវព័ត៌មាន ឬក៏(២) ក្នុងស្មារតីធ្វើការកៀបសង្កត់ ឬប្រើអំពើសាហាវយង់ឃ្នង[53]។ ការធ្វើទារុណកម្ម ក្នុងនាមជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយ និងការធ្វើទារុណកម្មក្នុងនាមជាអំពើបំពារបំពានធ្ងន់ធ្ងរមួយ គឺទាំងពីរនេះសុទ្ធតែតម្រូវឱ្យអំពើនៃការធ្វើទារុណកម្មត្រូវបានអនុវត្តដោយចេតនាដើម្បីឱ្យទទួលបាននូវព័ត៌មាន ដើម្បីធ្វើទារុណកម្ម ដើម្បីសម្លុតបំភ័យ ឬបង្ខិតបង្ខំ ដល់ជនរងគ្រោះ ឬតតិយជនណាម្នាក់ ឬដើម្បីប្រកាន់រើសអើងប្រឆាំងនិងជនរងគ្រោះឬតតិយជនណាម្នាក់[54]។ ការធ្វើទារុណកម្មក្រោមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦

[53] ដីកាសន្និដ្ឋានស្ថាពរ, កថាខណ្ឌទី ២៣២ ។

[54] ដីកាសន្និដ្ឋានស្ថាពរ, កថាខណ្ឌទី ១៩៩ និង ២២៨ ។

អាចត្រូវបានបង្ហាញសក្ខីកម្មដោយការប្រើធាតុផ្សំខាងបញ្ញាស្មារតី ដោយ“ស្មារតីធ្វើការកៀបសង្កត់ដោយប្រើអំពើសាហាវយង់ឃ្នង” ដែលមិនមាននៅក្នុងបទល្មើសនានាក្រោមច្បាប់អន្តរជាតិនោះទេ។ ហេតុដូចនេះ គឺវាមានធាតុផ្សំជាក់ស្ដែងមួយដែលខុសគ្នាពីបទល្មើសនានាក្រោមច្បាប់អន្តរជាតិ។

៣៤. អំពើមនុស្សឃាត ក្រោមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ គឺតម្រូវឱ្យមានចេតនាដើម្បីធ្វើឱ្យស្លាប់[55]។ ផ្ទុយទៅវិញ អំពើមនុស្សឃាត ក្នុងនាមជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើឃាតកម្មក្នុងនាមជាអំពើបំពារបំពានធ្ងន់ធ្ងរ អាចបំពេញគ្រប់គ្រាន់ដោយមានចេតនាក្នុងការសម្លាប់ ឬមួយក៏ដោយមានចេតនាក្នុងការធ្វើឱ្យមានការខូចខាតធ្ងន់ធ្ងរខាងរាងកាយ ឬឱ្យមានការរងរបួសជាទម្ងន់[56]។ ស្ថានភាពខាងបញ្ញាស្មារតីទាំងពីរនេះ ត្រូវតែចាត់ទុកជាធាតុផ្សំជាក់ស្ដែងដែលខុសពីគ្នា ពីព្រោះវាមានករណីខ្លះដែលការប្រព្រឹត្តិតែមួយដដែល អាចចូលជាអំពើមនុស្សឃាតដែលជាបទល្មើសក្រោមច្បាប់អន្តរជាតិ ក៏ប៉ុន្តែមិនមែនជាអំពើមនុស្សឃាតក្រោមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ នោះទេ[57]។

៣៥. ហេតុដូចនេះ បទល្មើសនានាក្រោមច្បាប់ជាតិ មិនអាចដាក់បញ្ចូលទៅក្រោមបទល្មើសនានាក្រោមច្បាប់អន្តរជាតិបានទេ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះ ពីព្រោះបទល្មើសនីមួយៗក្រោមច្បាប់ជាតិគឺតម្រូវឱ្យមានធាតុផ្សំជាក់ស្ដែងណាមួយដែលមិនមាននៅក្នុងបទល្មើសក្រោមច្បាប់អន្តរជាតិ។ ហើយបញ្ច្រាស់មកវិញ បទល្មើសនីមួយៗក្រោមច្បាប់អន្តរជាតិក៏តម្រូវឱ្យមានធាតុផ្សំជាក់ស្ដែងណាមួយដែលមិនមាននៅក្នុងបទល្មើសក្រោមច្បាប់ជាតិនោះដែរ។

---

[55] ដីកាសន្និដ្ឋានស្ថាពរ, កថាខណ្ឌទី ១២៥ ។

[56] ដីកាសន្និដ្ឋានស្ថាពរ, កថាខណ្ឌទី ២០៣ និង ២៣០ ។

[57] ឧទាហរណ៍ដូចជា ការសម្លាប់មួយដែលបណ្ដាលមកពីចេតនាចង់ធ្វើឱ្យមានការខូចខាតធ្ងន់ធ្ងរខាងផ្លូវកាយ អាចជាអំពើមនុស្សឃាត (murder)ដែលជាបទល្មើសក្រោមច្បាប់អន្តរជាតិ ក៏ប៉ុន្តែមិនអាចជាការធ្វើមនុស្សឃាតក្រោមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ នោះទេ។

## គ. អង្គហេតុនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កំណត់បានទូវបទឧក្រិដ្ឋតាមតាមច្បាប់ជាតិ

៣៦. បទល្មើសនៃការធ្វើទារុណកម្ម និងអំពើមនុស្សឃាត ក្រោមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ត្រូវបានផ្តល់សក្ខីកម្មដោយអង្គហេតុផ្សេងៗដែលត្រូវបានរកឃើញនៅក្នុងដីកាដំណោះស្រាយ ។ សហព្រះរាជអាជ្ញា សូមជូនសេចក្តីសន្និដ្ឋានថា មិនចាំបាច់ឲ្យ អង្គបុរេជំនុំជម្រះ ធ្វើការវាយតម្លៃលើភស្តុតាងដែលមាននៅក្នុងសំណុំរឿងនោះទេ ដោយសារ សហចៅក្រមស៊ើបអង្កេតបានរកឃើញរួចហើយនៅក្នុងកថាខណ្ឌទី១៥២នៃដីកាដំណោះស្រាយដែលថា "អំពើទាំងឡាយដែលត្រូវបានកំណត់បទចោទដោយកិច្ចស៊ើបសួររបស់តុលាការ ក៏អាចបង្កើតជាបទមនុស្សឃាត និង ការធ្វើទារុណកម្មដែលជាបទល្មើសក្រោមច្បាប់ជាតិបានដែរ"។ ក្រោយពីសហចៅក្រមស៊ើបអង្កេត បានរកឃើញថា អង្គហេតុទាំងឡាយបានបង្កើតទៅជាបទល្មើសក្រោមច្បាប់ជាតិនានាដែលស្ថិតនៅជាធរមានហើយនោះ គឺសហចៅក្រមស៊ើបអង្កេតត្រូវតែធ្វើការចោទប្រកាន់អំពីបទល្មើសទាំងនោះ។

## ឃ. ហានិភ័យមិនចាំបាច់នៃការលើកលែងការចោទប្រកាន់ក្នុងពេលជំនុំជម្រះក្តី

៣៧. ដោយមានការខកខានមិនបានធ្វើការចោទប្រកាន់អំពីបទល្មើសតាមច្បាប់ជាតិនោះ សហចៅក្រមស៊ើបអង្កេត បានបង្កើតជាហានិភ័យដែលមិនមានការចាំបាច់មួយដែលមានសក្តានុពលថា **ឌុច**អាចនឹងត្រូវបានលើកលែងការចោទប្រកាន់ទាំងស្រុងនៅក្នុងពេលជំនុំជម្រះក្តី។

៣៨. ដោយបទល្មើសទាំងឡាយក្រោមច្បាប់អន្តរជាតិ តម្រូវឲ្យផ្តល់សក្ខីកម្មអំពីធាតុផ្សំជាក់លាក់ខាងយុត្តាធិការដែលបានបង្កើតឡើងនៅក្នុងអង្គហេតុបន្ថែមនៃបទល្មើសដោយផ្ទាល់។ ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺតម្រូវឲ្យសហព្រះរាជអាជ្ញា ត្រូវបង្ហាញសក្ខីកម្មជាបន្ថែមពីលើការទទួលខុសត្រូវរបស់ជនជាប់ចោទចំពោះឧក្រិដ្ឋកម្មនានាជាដើមអាទិ៍ថែមទៀតដើម្បីឲ្យឃើញថា ឧក្រិដ្ឋកម្មជាដើមអាទិ៍នោះ បានបង្កើត: (១)ជាផ្នែកនៃការវាយប្រហារជាលក្ខណៈទូលំទូលាយនិងជាប្រព័ន្ធ ដែល(២) សំដៅប្រឆាំងនឹង (៣) ប្រជាជនស៊ីវិលណាមួយ

(៤) ដោយសារមូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា ហើយថា (៥) ជនជាប់ចោទបានដឹងអំពីការវាយប្រហារនោះ ហើយថា (៦) អំពើទាំងឡាយរបស់គាត់ គឺជាផ្នែកមួយនៅក្នុងការវាយប្រហារនោះ។

៣៩. ស្រដៀងគ្នានេះដែរ ចំពោះអំពើបំពារបំពានធ្ងន់ធ្ងរនានា គឺតម្រូវឱ្យសហព្រះរាជអាជ្ញា ផ្តល់សក្ខីកម្មបន្ថែមពីលើឧក្រិដ្ឋកម្មជាដើមអាទ៏ដោយផ្ទាល់ អំពីថា: (១) ជនរងគ្រោះគឺជាជនដែលត្រូវបានទទួលការការពារក្រោមអនុសញ្ញានានានៃទីក្រុងហ្សឺណែវ (២) មានការជាប់ទាក់ទងគ្នារវាងឧក្រិដ្ឋកម្មដែលជាដើមអាទ៏ ហើយនិងជម្លោះប្រដាប់អាវុធអន្តរជាតិ និង (៣) ជនចាប់ចោទបានដឹងហើយថា ជម្លោះប្រដាប់អាវុធបានមានអត្ថិភាពមែន ហើយ (៤) ជនជាប់ចោទបានដឹងថា ជនរងគ្រោះគឺជាជនដែលត្រូវបានទទួលការការពារ។

៤០. ប្រសិនបើ សហព្រះរាជអាជ្ញា ខកខានក្នុងការបង្ហាញសក្ខីកម្មនៅក្នុងផ្នែកនីមួយៗនៃផ្នែកទាំងអស់នៃធាតុផ្សំខាងយុត្តាធិការ គឺមុខជានឹងបណ្តាលឱ្យ អង្គជំនុំជម្រះសាលាដំបូង សម្រេចធ្វើការលើកលែងការចោទប្រកាន់អំពីបទចោទទាំងនេះជាពុំខាន។ ផ្ទុយទៅវិញ បទល្មើសក្រោមច្បាប់ជាតិ គឺមិនតម្រូវឱ្យបង្ហាញភស្តុតាងអំពីធាតុផ្សំបន្ថែមទាំងនេះនោះទេ។ បើសិនជាបទល្មើសនានាក្រោមច្បាប់ជាតិត្រូវបានរៀបរាប់ជាក់លាក់ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះ បញ្ហាចោទតែមួយគត់សម្រាប់អង្គជំនុំជម្រះសាលាដំបូងនោះគឺត្រូវពិនិត្យពិចារណាអំពីថា តើធាតុផ្សំទាំងឡាយនៃបទល្មើសក្រោមច្បាប់ជាតិទាំងនោះបានបង្ហាញសក្ខីកម្មឱ្យឃើញថា វាហួសពីវិមតិសង្ស័យដែរ ឬទេ?

៤១. ក៏ប៉ុន្តែ ប្រសិនជា **ឌុច** *មិន*ត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌផ្សេងៗក្រោមច្បាប់ជាតិនៅមុនពេលសវនាការជំនុំជម្រះក្តីទេនោះ មុខជានឹងតម្រូវឱ្យ អង្គជំនុំជម្រះសាលាដំបូងត្រូវធ្វើការពិចារណាលើការអនុវត្តនូវវិធាន៩៨.២ នៃវិធានផ្ទៃក្នុងហើយ។ បើសិនជា អង្គជំនុំជម្រះសាលាដំបូង ត្រូវអនុម័តយកនូវវិធីសាស្ត្រដែលតឹងតែងមួយនៅក្នុងវិធាន៩៨.២នោះ ដូចបានពិភាក្សាខាងលើរួចហើយការកែប្រែការកំណត់បទចោទជាថ្មីឡើងវិញ ដោយផ្អែកលើអង្គហេតុនានាដោយបទល្មើសនានាក្រោមច្បាប់ជាតិអាច និងត្រូវហាមឃាត់មិនឱ្យធ្វើការ

ពិនិត្យពិចារណាទេ សូម្បីតែភស្តុតាងក៏ដោយ។ ការណ៍នេះ ជាលទ្ធផលគឺអាចនឹងបណ្តាលឲ្យមានការលើកលែងការចោទប្រកាន់ទាំងស្រុង។ ដើម្បីលុបបំបាត់ចោលកុំឲ្យមានលទ្ធភាពដែលអាចឲ្យមានការលើកលែងការចោទប្រកាន់លើបទចោទទាំងអស់នេះ ស្នើឲ្យ អង្គបុរេជំនុំជម្រះ ធ្វើវិសោធនកម្មលើដីកាដំណោះស្រាយនេះទៅតាមខ្លឹមសារដូចខាងក្រោម។

## ង. អនុសាសន៍ក្នុងការធ្វើវិសោធនកម្មទៅលើដីកាដំណោះស្រាយ

៤២. អាស្រ័យហេតុនេះ សូមស្នើឲ្យ អង្គបុរេជំនុំជម្រះ ធ្វើការកែប្រែទៅលើដីកាដំណោះស្រាយ និងចោទប្រកាន់ **ឌុច** ពីបទមនុស្សឃាតនិងការធ្វើទារុណកម្មអនុលោមតាមក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។ សូមជូនសេចក្តីសន្និដ្ឋានថា មិនចាំបាច់ឲ្យ អង្គបុរេជំនុំជម្រះធ្វើការវាយតម្លៃទៅលើភស្តុតាងនៅក្នុងសំណុំរឿងទេ ដោយសហចៅក្រមស៊ើបអង្កេត បានរកឃើញរួចហើយថា "អំពើទាំងឡាយដែលត្រូវបានកំណត់បទល្មើសដោយកិច្ចស៊ើបសួររួចហើយនោះ ក៏បង្កើតបានទៅជាបទមនុស្សឃាតនិងការធ្វើទារុណកម្មដែលជាបទល្មើសក្រោមច្បាប់ជាតិដែរ"។ ហេតុនេះ សហព្រះរាជអាជ្ញា សូមស្នើឲ្យធ្វើវិសោធនកម្មលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយដកចេញនូវឃ្លាទី២ពីក្នុងកថាខណ្ឌទី១៥២នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងដោយដាក់បញ្ចូលបន្ថែមនូវកថាខណ្ឌទី៣ថ្មីនៅក្នុងផ្នែកទីIV នៃដីកាបញ្ជូនជូនរឿងទៅជំនុំជម្រះ ដូចតទៅនេះ៖

៣. <u>**អំពើរំលោភបំពានផ្សេងៗនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦**</u>

- អំពើមនុស្សឃាត (មាត្រា ៥០១ មាត្រា៥០៣ និងមាត្រា៥០៦)
- ការធ្វើទារុណកម្ម (មាត្រា៥០០)។

ដែលជាបទល្មើសដែលបានកំណត់និយមន័យ និងផ្តន្ទាទោសតាមមាត្រា ៣(ថ្មី) មាត្រា២៩ (ថ្មី) និងមាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការ

កម្ពុជាដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។

## ៦. ឧទ្ធរណ៍ទី ២
## ការខកខានមិនបានចោទប្រកាន់ពីការប្រព្រឹត្តិ តាមរយៈសហកម្មឧក្រិដ្ឋកម្មរួម

៤៣. សហចៅក្រមស៊ើបអង្កេត មានកំហុសក្នុងការខាកខានមិនបានចាត់ទង្វើរបស់ **ឌុច** ថាជាការប្រព្រឹត្តិតាមរយៈការចូលរួមក្នុងសហកម្មឧក្រិដ្ឋកម្មរួម ទោះបីជាអង្គហេតុនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជាអង្គហេតុគាំទ្រដល់ការប្រើប្រាស់សហកម្មឧក្រិដ្ឋកម្មរួម ក៏ដោយ ។ វាជាកំហុសមួយដែលមានហេតុផលពីរយ៉ាង ។ ទីមួយ ទម្រង់បីយ៉ាងនៃការទទួលខុសត្រូវដែលបានចាត់ថាជា ការបញ្ជា ការញុះញង់ ការរៀបចំផែនការ គឺមិនមានលក្ខណៈទូលំទូលាយគ្រប់គ្រាន់ដើម្បីគ្របដណ្ដប់ទៅលើ ពិរុទ្ធភាពទាំងស្រុងនៃអំពើរបស់ **ឌុច** ទេ ។ ទីពីរ ទម្រង់ចំនួនពីរផ្សេងទៀតនៃការទទួលខុសត្រូវ ដែលបានចាត់ថាជា ការជួយនិងជំរុញ និងការទទួលខុសត្រូវរបស់ ថ្នាក់លើ មិនឆ្លុះបញ្ចាំងទាំងស្រុងនូវតួនាទីឧក្រិដ្ឋដ៏សំខាន់ដែល **ឌុច** មាននៅមន្ទីរស-២១ ទេ ។ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ការទទួលខុសត្រូវរបស់ **ឌុច** គឺ មានលក្ខណៈចង្អៀតមិនសមហេតុផលដោយគ្មានសហកម្មឧក្រិដ្ឋកម្មរួមហើយ ដែលអាចនឹងមានលទ្ធភាពខ្ពស់មួយថា គាត់អាចមិនត្រូវបានដាក់ឱ្យទទួលខុសត្រូវចំពោះពិរុទ្ធភាពទាំងស្រុងនៃអំពើរបស់គាត់ទេ ។

៤៤. សហកម្មឧក្រិដ្ឋកម្មរួម មិនមែនជាបទល្មើសទេ ។ វាគឺជាវិធីមួយដែលតាមរយៈនោះឧក្រិដ្ឋកម្មអាចត្រូវបានប្រព្រឹត្ត[58] ។ នៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម មនុស្សមួយក្រុម[59] ព្រមព្រៀងប្រព្រឹត្តនូវអំពើអ្វីមួយជាមួយគ្នាដើម្បីធ្វើឱ្យបានសម្រេចនូវគោលបំណងអ្វីមួយដែ

[58] ការពិភាក្សាស៊ីជម្រៅអំពីសហកម្មឧក្រិដ្ឋកម្មរួមមានក្នុងកថាខណ្ឌ២៤១-២៥៣ នៃដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាទាក់ទងនឹងកាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៨, ឯកសារតុលាការ D96។

[59] សាលដីកាសម្រេចលើករណីរបស់ Vasiljevic, កថាខណ្ឌទី ១០០ ។ *រដ្ឋអាជ្ញា ទល់នឹង Stakic,* សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការ ICTY, សំណុំរឿងលេខ IT-97-24-A, កថាខណ្ឌទី ៦៤ [*បន្ទាប់ពីនេះទៅហៅថា៖* សាលដីកាសម្រេចលើករណីរបស់ Stakic] ។

លខុសច្បាប់[60] ។ សមាជិកម្នាក់ៗក្នុងក្រុមដែល៖ ទី១) ព្រមព្រៀងធ្វើឱ្យសម្រេចបាននូវគោលបំណងខុសច្បាប់[61], និងទី២) ប្រព្រឹត្តនូវអំពើមួយដ៏សំខាន់ដើម្បីជម្រុញឱ្យបានដល់គោលបំណងខុសច្បាប់នោះ[62] សមាជិកនោះគឺជាអ្នកចូលរួមម្នាក់ក្នុងសហកម្មឧក្រិដ្ឋកម្មរួម ។ សហកម្មឧក្រិដ្ឋកម្មរួមមានទម្រង់៣យ៉ាង ហើយវិសាលភាពនៃការទទួលខុសត្រូវរបស់ជនជាប់ចោទទៅតាមទម្រង់នៃការទទួលខុសត្រូវនេះ អាស្រ័យទៅលើថាតើ ការទទួលខុសត្រូវនៃសហកម្មឧក្រិដ្ឋរួមនេះ ត្រូវបានគេចាត់ទុកក្នុងទម្រង់មួយណា ៖ "ទម្រង់មូលដ្ឋាន" "ទម្រង់ជាប្រព័ន្ធ" ឬជា "ទម្រង់វិបុលកម្ម"។

៤៥. ជនជាប់ចោទចូលរួមក្នុងសហកម្មឧក្រិដ្ឋកម្មរួម "ជាមូលដ្ឋាន" នៅពេលជននោះមាន ចេតនាប្រព្រឹត្តនូវបទល្មើសជាក់លាក់នានាហើយអ្នកចូលរួមប្រព្រឹត្តបទល្មើសផ្សេង ទៀត ក៏មានចេតនាប្រព្រឹត្តបទល្មើសនេះដែរ[63]។ សហកម្មឧក្រិដ្ឋកម្មរួម "ជាប្រព័ន្ធ" ជាធម្មតាទាក់ទងនឹងជំរុំពន្ធនាគារ ឬ "ប្រព័ន្ធចាត់តាំងនៃការធ្វើទុក្ខបុកម្នេញ" ណាមួយ[64]។ សហកម្មឧក្រិដ្ឋកម្មរួម "ជាប្រព័ន្ធ" តម្រូវឱ្យជនជាប់ចោទដឹង ដោយខ្លួនឯងអំពីប្រព័ន្ធចាត់តាំងនៃការធ្វើទុក្ខបុកម្នេញ និងមានចេតនាធ្វើឱ្យប្រព័ន្ធនោះកាន់តែរីករាលដាល[65]។ នៅក្នុងសហកម្ម

[60] សាលដីកាសម្រេចលើករណីរបស់ Tadić, កថាខណ្ឌទី២២៧ ។ សាលដីកាសម្រេចលើករណីរបស់ Vasiljevic, កថាខណ្ឌទី១០០ ។

[61] ចេតនាឧក្រិដ្ឋរបស់អ្នកចូលរួម អាស្រ័យលើថាតើជនជាប់ចោទត្រូវបានចោទប្រកាន់ថាជាសមាជិកម្នាក់នៅក្នុងទម្រង់ "មូលដ្ឋាន" "ជាប្រព័ន្ធ" ឬជា "វិបុលកម្ម" នៃសហកម្មឧក្រិដ្ឋកម្មរួម ។ សាលដីកាសម្រេចលើករណីរបស់ Tadić, កថាខណ្ឌទី ២២០ និង ២២៨ (ទម្រង់ជាមូលដ្ឋាន) ។ សាលដីកាសម្រេចលើករណីរបស់ Krnojelac, កថាខណ្ឌទី ៣២ (ទម្រង់ជាប្រព័ន្ធ) ។ សាលដីកាសម្រេចលើករណីរបស់ *Vasiljevic,* កថាខណ្ឌទី ១០១ និង ១០៥ (ទម្រង់ជាប្រព័ន្ធ) ។ សាលដីកាសម្រេចលើករណីរបស់ Kvocka, កថាខណ្ឌទី (ទម្រង់ជាវិបុលកម្ម) ។ សាលដីកាសម្រេចលើករណីរបស់ Tadić, កថាខណ្ឌទី ២២៨ (ទម្រង់ជាវិបុលកម្ម) ។ សេចក្តីសម្រេចលើករណីរបស់ Mrksic, កថាខណ្ឌទី ៥៤៦ (ទម្រង់ជាវិបុលកម្ម) ។ សាលដីកាសម្រេចលើករណីរបស់ Brdjanin, កថាខណ្ឌទី ៤១១, ៤៣១ (ទម្រង់ជាវិបុលកម្ម) ។

[62] សាលដីកាសម្រេចលើករណីរបស់ Tadić, កថាខណ្ឌទី ២២៧ ។ សាលដីកាសម្រេចលើករណីរបស់ Stakić, កថាខណ្ឌទី ៦៤ ។ សាលដីកាសម្រេចលើករណីរបស់ Brdjanin, កថាខណ្ឌទី ៤១៨, ៤៣០ ។ សាលដីកាសម្រេចលើករណីរបស់ Kvocka, កថាខណ្ឌទី ៩៨ ។

[63] សាលដីកាសាលាឧទ្ធរណ៍ក្នុងរឿងក្តី *Tadic* កថាខណ្ឌទី២២០, ២២៨។

[64] សាលដីកាសាលាឧទ្ធរណ៍ក្នុងរឿងក្តី *Vasiljevic* កថាខណ្ឌទី៩៨។

[65] សាលដីកាសាលាឧទ្ធរណ៍ក្នុងរឿងក្តី *Krnojelac* កថាខណ្ឌទី៣២។ សាលដីកាសាលាឧទ្ធរណ៍ក្នុងរឿងក្តី *Vasiljevic* កថាខណ្ឌទី ១០១, ១០៥។

ឧក្រិដ្ឋកម្មរួម "វិបុលកម្ម" វិញ ជនជាប់ចោទដែលបានប្រព្រឹត្តក្នុងបំណងធ្វើឲ្យសម្រេចគោលបំណងនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម ត្រូវទទួលខុសត្រូវចំពោះបទល្មើសរបស់អ្នកផ្សេងទៀតប្រសិនបើ៖ (១) បទល្មើសគឺជា "ផលវិបាកទូទៅ និងអាចដឹងជាមុន" ដែលបណ្តាលមកពីគោលបំណងខុសច្បាប់ ទោះបីជាបទល្មើសត្រូវបានគេប្រព្រឹត្តនៅក្រៅវិសាលភាពនៃគោលបំណងខុសច្បាប់នេះក៏ដោយ[66] និង(២) ជនជាប់ចោទធ្វើការប្រថុយប្រថានដោយស្ម័គ្រចិត្ត ថាបទល្មើសអាចត្រូវបានគេប្រព្រឹត្តរួមគ្នា ឬបន្តចូលរួមក្នុងសហកម្មនោះ[67]។

៤៦. សហកម្មឧក្រិដ្ឋកម្មរួមជាទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានគេទទួលស្គាល់ យ៉ាងទូលាយ និងត្រូវបានគេយកមកអនុវត្តជាប្រចាំនៅតុលាការអន្តរជាតិផ្សេងទៀត ពីព្រោះសហកម្មឧក្រិដ្ឋកម្មរួមបានបង្ហាញនូវការទទួលខុសត្រូវរបស់អ្នកចូលរួម ប្រព្រឹត្តបទល្មើសអន្តរជាតិត្រឹមត្រូវជាងទំរង់នៃការទទួលខុសត្រូវផ្សេងទៀត។ ការទទួលខុសត្រូវក្នុងសហកម្មឧក្រិដ្ឋកម្មរួមត្រូវបានគេយកមកប្រើ នៅពេលចោទប្រកាន់លើអំពើឃោរឃៅទ្រង់ទ្រាយធំ ពីព្រោះសហកម្មឧក្រិដ្ឋកម្មរួមអាចរួមបញ្ចូលទង្វើ ដែលមិនមានចែងនៅក្នុងអំពើពិរុទ្ធនៃការបញ្ជា ការរៀបចំផែនការ ឬញុះញង់ប្រព្រឹត្តបទល្មើសជាក់លាក់នានា ប៉ុន្តែទង្វើទាំងអស់នោះមានលក្ខណៈសំខាន់នាំដល់ការប្រព្រឹត្តិអំពើឃោរឃៅ។ ចំពោះជនជាប់ចោទដែលចូលរួមក្នុងការប្រព្រឹត្តិនៅក្នុងទម្រង់សហកម្មឧក្រិដ្ឋកម្មរួម ជារឿយៗជាសមាជិកមានតួនាទីជាន់ខ្ពស់នៅក្នុងក្រុម និងឃ្លាតឆ្ងាយពីការប្រព្រឹត្តិបទល្មើសជាក់ស្តែង ជននោះគឺជាអ្នកចូលរួមប្រព្រឹត្ត

---

[66] សាលដីកាសាលាឧទ្ធរណ៍ក្នុងរឿងក្តី *Tadic* កថាខណ្ឌទី២០៤។ ឧទាហរណ៍នេះជាចេតនាប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌរួម ដើម្បីបោសសម្អាតជាតិពន្ធុនៅកន្លែងជាក់លាក់មួយដោយប្រើអាវុធគម្រាមកំហែង ប៉ុន្តែចេតនាប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌរួមគឺ *ត្រឹមតែ* បណ្តេញជនដែលមិនត្រូវការចេញពីកន្លែងនោះ។ នៅក្នុងពេលបណ្តេញចេញនោះ ជនម្នាក់ត្រូវបានគេបាញ់និងបានស្លាប់។ នៅពេលគោលបំណងប្រព្រឹត្តបទល្មើសរួមគ្រាន់តែបោសសម្អាតជាតិពន្ធុតំបន់នោះទេ មិនមែនប្រព្រឹត្តឃាតដកម្មទេ។ ផលវិបាកនៃការសម្អាតអាចទស្សន៍ទាយបាននិងអាចដឹងមុនបានថា មនុស្សអាចនឹងស្លាប់ប្រសិនបើចារីដែលធ្វើយុទ្ធនាការបោសសម្អាតជាតិពន្ធុបំពាក់ដោយអាវុធ, សាលដីកាសាលាឧទ្ធរណ៍ក្នុងរឿងក្តី *Vasiljevic* កថាខណ្ឌទី៩៩។

[67] សាលដីកាសាលាឧទ្ធរណ៍ក្នុងរឿងក្តី *Kvocka* កថាខណ្ឌទី៨៣។ សាលដីកាសាលាឧទ្ធរណ៍ក្នុង រឿងក្តី *Tadic* កថាខណ្ឌទី ២២៨។ សាលដីកាសាលាឧទ្ធរណ៍ក្នុងរឿងក្តី *Mrksic* កថាខណ្ឌទី៥៤៦។សាលដីកាសាលាឧទ្ធរណ៍ក្នុងរឿងក្តី *Brdjanin* កថាខណ្ឌទី៤១១, ទី៤៣១។

00222058

D99/3/3



បទល្មើសដោយឆន្ទៈនៅក្នុងគោលបំណងឧក្រិដ្ឋ។ ប្រសិនបើគ្មានការទទួលខុសត្រូវក្នុងសហកម្មឧក្រិដ្ឋកម្មរួមនោះទេ ជនជាប់ចោទមានតួនាទីជាន់ខ្ពស់អាចនឹងដាក់ឲ្យទទួលខុសត្រូវចំពោះតែសកម្មភាពនៃការបញ្ជា ការញុះញង់ និងរៀបចំផែនការប្រព្រឹត្តបទល្មើសតែប៉ុណ្ណោះ ឬអាចសម្រេចឲ្យទទួលខុសត្រូវជាអ្នកជួយទំនុកបំរុងតែប៉ុណ្ណោះ។ ជាមួយនឹងការអនុវត្តន៍ទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម ជនជាប់ចោទត្រូវបានកាត់ទោសគ្រប់បទល្មើស ទាំងអស់ដែលបានប្រព្រឹត្តនៅក្នុងការសម្រេចគោលបំណងឧក្រិដ្ឋកម្មរួម។

៤៧. ច្បាប់យុត្តិសាស្ត្ររបស់តុលាការអន្តរជាតិផ្សេងៗទៀតបានបង្ហាញថា ទង្វើរបស់ជនជាប់ចោទអាចជាភស្តុតាងគ្រប់គ្រាន់ ដើម្បីឲ្យជនជាប់ចោទ ទទួលខុស ត្រូវក្នុងទម្រង់ជាសហចារីនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម ទោះបីជាទង្វើដែលនេះ មិនមានភាពគ្រប់គ្រាន់សម្រាប់បំពេញទម្រង់នៃការទទួលខុសត្រូវផ្សេងទៀតក៏ដោយ។ ឧទាហរណ៍ នៅក្នុងបរិបទនៃជំរុំពន្ធនាគារមួយ តុលាការបានសម្រេចថា "គ្រាន់តែកាន់តួនាទីផ្នែកប្រតិបត្តិផ្នែករដ្ឋបាល ឬផ្នែកការពារជំរុំនោះ គឺគ្រប់គ្រាន់សម្រាប់ចាត់ទុកថាជាអំពើនៃការចូលរួមជាទូទៅក្នុងការប្រព្រឹត្តិបទល្មើសរួចទៅហើយ"[68]។ តុលាការបានសម្រេចថាមេបញ្ជាការរងនៅជំរុំពន្ធនាគារក៏អាចទទួលខុសត្រូវក្នុងនាមជាអ្នកចូលរួមក្នុងសហកម្មឧក្រិដ្ឋកម្មរួមនៅពេល៖ (១) គាត់បានដឹងអំពីការប្រព្រឹត្តិរំលោភបំពាននៅក្នុងជំរុំ និង(២) គាត់បានឃើញការប្រព្រឹត្តិបទល្មើសមួយចំនួន (៣) ប៉ុន្តែបានចាត់វិធានការតិចតួច ដើម្បីទប់ស្កាត់ ឬកាត់បន្ថយការរំលោភបំពានទាំងនោះ[69]។

៤៨. ការប្រើប្រាស់ការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួម ដើម្បីពិនិត្យមើលឲ្យគ្រប់ជ្រុងជ្រោយអំពីស្ថានភាពជាក់ស្តែង នៃការប្រព្រឹត្តិបទល្មើសស្មុគស្មាញ ដែលពាក់ពន្ធ័នឹងអ្នកប្រព្រឹត្តច្រើននាក់ អាចបង្ហាញតាមរយៈឧទាហរណ៍នៃការធ្វើទារុណកម្ម។ បទល្មើសនេះត្រូវ

---

68 សាលដីកាសម្រេចលើករណីរបស់ Kvocka, កថាខណ្ឌទី ១០៣ ដែលបានគាំទ្រដល់ សេចក្តីសម្រេចលើករនីរបស់ Kvocka, កថាខណ្ឌទី ២៧៨ ។

69 ក្នុងសាលក្រមតុលាការ Kvocka ជនជាប់ចោទត្រូវតែមានការទទួលខុសត្រូវ ទោះបីជាគាត់គ្រាន់តែជាមេបញ្ជាការរងនៃជំរុំពន្ធនាគារបានតែចំនួន១៧ថ្ងៃ ក៏ដោយ ។

បានប្រព្រឹត្តដោយជនជាច្រើននាក់ ដែលបានប្រព្រឹត្តរួមគ្នាដើម្បីធ្វើឲ្យឈឺចាប់ផ្នែករូបរាងកាយដល់ជនរងគ្រោះ។ ទារុណកម្មបានធ្វើដោយមានបុគ្គលម្នាក់ជាអ្នកបញ្ជាឲ្យធ្វើទារុណកម្ម ជនម្នាក់ទៀតជាអ្នកវាយដុំរូបរាងកាយ ជនម្នាក់ទៀតជាអ្នកសួរចម្លើយ និងជនម្នាក់ទៀតជាអ្នកវាស់កម្រិតរបួស ដើម្បីធ្វើយ៉ាងណាឲ្យជនរងគ្រោះឈឺចាប់ជាអតិប្បរមា តែមិនបណ្តាលឲ្យគាត់ស្លាប់នោះទេ។ សហកម្មឧក្រិដ្ឋកម្មរួមបង្ហាញអំពីពិរុទ្ធភាពរបស់បុគ្គលទាំងនោះ នៅពេលបទល្មើសទាំងនោះគឺជាផ្នែកនៃការប្រព្រឹត្តិមានភាពស្មុគស្មាញ និងរយៈពេលយូរ នៅពេលអ្នកប្រព្រឹត្តបទល្មើសបានប្រើតួនាទីផ្សេងៗគ្នា ឬអវត្តមានក្នុងអំឡុងពេលមានបទល្មើសក៏ដោយ។ សហចារីនៃសហកម្មឧក្រិដ្ឋកម្មរួមមិនអាចការពារខ្លួនក្នុងការលើកទឡ្ហីករណ៍ថា ពេលខ្លះគាត់គ្រាន់តែបញ្ជាឲ្យប្រព្រឹត្តបទល្មើស និងពេលខ្លះគាត់គ្រាន់តែសួរចម្លើយប៉ុណ្ណោះទេ។ ប្រសិនបើមិនអនុវត្តទ្រឹស្តីសហចារីតាមរយៈសហកម្មឧក្រិដ្ឋកម្មរួមនៅក្នុងរឿងក្តីស្មុគស្មាញនោះទេ លទ្ធភាពនៃការវាយតម្លៃទៅលើការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទគឺមានកម្រិតទាបណាស់។

## ក. ច្បាប់ អ.វ.ត.ក អនុញ្ញាតឲ្យយក ការទទួលខុសត្រូវបែបសហកម្មឧក្រិដ្ឋកម្មរួម មកអនុវត្តបាន

៤៩. ដើម្បីឲ្យ អ.វ.ត.ក បានប្រើប្រាស់នូវទម្រង់នៃការទទួលខុសត្រូវណាមួយ ទម្រង់នៃការទទួលខុសត្រូវនោះ ត្រូវតែស្របទៅតាមលក្ខខណ្ឌចំនួនបួនគឺ៖ ទី១) ទម្រង់នោះត្រូវតែមានចែងនៅក្នុងច្បាប់ អ.វ.ត.ក ទោះជា *វាទិក* (មានចែងច្បាស់លាស់) ឬ *វាទានុហិត* ក្តី (មិនមានចែងច្បាស់លាស់), ទី២) ទម្រង់នោះត្រូវតែមាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលត្រូវទៅតាមពេលវេលានោះ, ទី៣) ច្បាប់ដែលបានបញ្ញត្តឲ្យមានទម្រង់នៃការទទួលខុសត្រូវនោះ ត្រូវតែអាចរកបានយ៉ាងគ្រប់គ្រាន់ដោយចុងចោទ ដែលត្រូវទៅតាមពេលវេលានោះ និងទី៤) ចុងចោទត្រូវតែមានលទ្ធភាពអាចប្រមើលមើលបានថា ខ្លួនអាចនឹងត្រូវឲ្យទទួលខុសត្រូវផ្នែក

ព្រហ្មទណ្ឌចំពោះអំពើទាំងឡាយរបស់ខ្លួន[70] ។ សហកម្មឧក្រិដ្ឋកម្មរួម បំពេញបានទៅនឹងលក្ខខណ្ឌនីមួយៗនេះ និងជាទម្រង់នៃការ ទទួលខុសត្រូវមួយដែលមានសុពលភាពនៅក្នុង អ.វ.ត.ក នេះ ។

៥០. មាត្រា ២៩ នៃច្បាប់ អ.វ.ត.ក ចែងអំពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់បុគ្គលណាក៏ដោយដែលជា "ជនសង្ស័យណាមួយ ដែលមានផែនការ ញុះញង់ បញ្ជា ជួយនិង ជម្រុញឬប្រព្រឹត្ត" ឧក្រិដ្ឋកម្មទាំងឡាយដែលអង្គជំនុំជម្រះនេះអាចផ្តន្ទាទោសបាន ។ ទម្រង់នៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌទាំងនេះ គឺមានលក្ខណៈដូចគ្នាសុទ្ធសាធទៅនឹងទម្រង់ទាំងឡាយដែលមាននៅក្នុងលក្ខន្តិកៈសម្រាប់តុលាការ ICTY, ICTR និង តុលាការពិសេសសម្រាប់ប្រទេសស៊ីរ៉ាឡេអូន ("SCSL") ។ តុលាការនីមួយៗដូចដែលរៀបរាប់ខាងលើនេះ បានសម្រេចថា ការចូលរួមនៅក្នុងផែនការឬគោលបំណងឧក្រិដ្ឋរួមណាមួយ នោះគឺជាទម្រង់មួយនៃ "ការប្រព្រឹត្តិ" ឧក្រិដ្ឋកម្ម[71] ។ តុលាការទាំងនេះបានយកតាមសេចក្តីសម្រេចលើករណីរបស់ *Tadić* ដែលបានសម្រេចថា ការចូលរួមនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម គឺជាទម្រង់មួយនៃការប្រព្រឹត្តិ ហើយថា សហកម្មឧក្រិដ្ឋកម្មរួមឆ្លុះបញ្ចាំងអំពីការទទួលខុសត្រូវរបស់សហចារីនៅក្នុងឧក្រិដ្ឋកម្មអន្តរជាតិផ្សេងៗ បានយ៉ាងច្បាស់លាស់ជាងទម្រង់នៃការទទួលខុសត្រូវដទៃទៀត[72]។

---

[70] *រដ្ឋអាជ្ញា ទល់នឹង Milutinović និង គូកន* , សេចក្តីសម្រេចលើញត្តិរបស់ Dragoljub Ojdanić ជំទាស់នឹងបញ្ញាយុត្តធិការសហកម្មឧក្រិដ្ឋកម្មរួម, IT-99-37-AR72, អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការ ICTY, ចុះថ្ងៃទី២១ ឧសភា ២០០៣, កថាខណ្ឌទី ២១ [*បន្ទាប់ពីនេះទៅហៅថា៖* សេចក្តីសម្រេចលើករណីរបស់ Milutinović] ។

[71] *រដ្ឋអាជ្ញា ទល់នឹង Gacumbitsi,* សាលដីកា, ICTY-2001-64-A, ចុះថ្ងៃទី០៧ កក្កដា ២០០៦, កថាខណ្ឌទី ១៥៨។*រដ្ឋអាជ្ញា ទល់នឹង Fofana & Kondewa,* សេចក្តីសម្រេច, សំណុំរឿងលេខ SCSL-04-14-T, ចុះថ្ងៃទី០២ សីហា ២០០៧, កថាខណ្ឌទី ២០៨ ។ ការយោងយ៉ាងជាក់លាក់ទៅដល់សហកម្មឧក្រិដ្ឋកម្មរួមនៅក្នុងលក្ខន្តិកៈ មិនតម្រូវឱ្យតុលាការណាមួយអនុវត្តវាទេ ។ សេចក្តីសម្រេចលើករណីរបស់ Milutinović, កថាខណ្ឌទី ១៨, ២០ ។

[72] *រដ្ឋអាជ្ញា ទល់នឹង Dusko Tadić,* សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការ ICTY, ចុះថ្ងៃទី១៥ កក្កដា ១៩៩៩, IT-94-1-A, កថាខណ្ឌទី ១៨៨-១៩៣ [*បន្ទាប់ពីនេះទៅហៅថា៖* សេចក្តីសម្រេចលើករណីរបស់ Tadić] ។ សេចក្តីសម្រេចលើករណីរបស់ Tadić នេះបានសម្រេចថា ការប្រព្រឹត្តិគួរត្រូវបានបកស្រាយដោយរាប់បញ្ចូលនូវការចូលរួមនៅក្នុងផែនការរួម ពីព្រោះ ៖ ទី១) ឧក្រិដ្ឋកម្មអន្តរជាតិជាច្រើន មិនមែនកើតមកពីអំពើទាំងឡាយរបស់បុគ្គលតែម្នាក់ៗនោះទេ ក៏ប៉ុន្តែកើតមកពីក្រុមបុគ្គលដែលបានប្រព្រឹត្តតាមផែនការឧក្រិដ្ឋកម្មរួមណាមួយ, និងទី២) ទោះបីជាមានសមាជិកខ្លះៗតែប៉ុណ្ណោះនៅក្នុងក្រុម ដែលអាចនឹងប្រព្រឹត្តអំពើឧក្រិដ្ឋដោយផ្ទាល់ក៏ដោយ ក៏ការចូលរួម និងវិភាគទានរបស់សមាជិកដទៃទៀតនៅក្នុងក្រុម ជាញឹកញាប់គឺមានសារៈសំខាន់នៅក្នុងការសម្រប

៥១. ការដាក់បញ្ចូលសហកម្មឧក្រិដ្ឋកម្មរួមនៅក្នុងមាត្រា ២៩ នៃច្បាប់ អ.វ.ត.ក គឺត្រូវបានគាំទ្រដោយកម្មវត្ថុ និងគោលបំណងនៃច្បាប់ អ.វ.ត.ក ។ មាត្រា ១ នៃច្បាប់ អ.វ.ត.ក ចែងថា ច្បាប់នេះរៀបចំឡើងក្នុង "គោលបំណង" វិនិច្ឆ័យទោស "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មនៅ ក្នុងរបបនោះ ។ ដើម្បីធ្វើការកាត់ទោសពួក "មេដឹកនាំជាន់ខ្ពស់" និង "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ឲ្យបានជោគជ័យ អង្គជំនុំជម្រះនេះត្រូវតែមានលទ្ធភាពអាចដាក់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ដល់បុគ្គលទាំងឡាយដែលបានបង្កើត និងអនុវត្តនូវគោលនយោបាយឧក្រិដ្ឋផ្សេងៗនៃរបបកម្ពុជាប្រជាធិបតេយ្យ គឺមិនមែនគ្រាន់តែបុគ្គលដែលបាន ប្រព្រឹត្តអំពើឧក្រិដ្ឋដោយផ្ទាល់ ដែលជាលទ្ធផលលេចចេញមកពីគោលនយោបាយទាំងនោះ តែប៉ុណ្ណោះទេ ។ សហកម្មឧក្រិដ្ឋកម្មរួម គឺជាទម្រង់នៃការទទួលខុសត្រូវមួយដ៏សមស្របបំផុតទៅនឹងកិច្ចការនេះ[73]។ អាស្រ័យហេតុនេះ ការដាក់បញ្ចូលសហកម្មឧក្រិដ្ឋកម្មរួម ជាទម្រង់មួយនៃ "ការប្រព្រឹត្ត" គឺស្របគ្នាជាមួយនឹងគោលបំណងនៃច្បាប់ អ.វ.ត.ក ស្របជាមួយនឹងលក្ខណៈនៃឧក្រិដ្ឋកម្មអន្តរជាតិ និងស្របគ្នាជាមួយនឹងរបៀបដែលតុលាការអន្តរជាតិផ្សេងៗធ្លាប់បានធ្វើការបកស្រាយខ្លឹមសារដោយដូចគ្នា អំពីលក្ខន្តិកៈរបស់តុលាការទាំងនោះរៀងៗខ្លួន ។

៥២. វាក្យស័ព្ទបច្ចេកទេស "សហកម្មឧក្រិដ្ឋកម្មរួម" នេះគឺជាស័ព្ទបង្កើតឡើងនាពេលថ្មីៗនេះក៏ពិតមែន ប៉ុន្តែគំនិតស្រដៀងគ្នានេះស្ដីពីគោលបំណងឧក្រិដ្ឋកម្មរួម ឬ ផែនការឧក្រិដ្ឋកម្មរួម ក៏ធ្លាប់មានផងដែរចាប់តាំងពីសង្គ្រាមលោកលើកទី II[74]។ គេអាចរកឃើញគំនិតទាំងនេះមាន

សម្រួលឲ្យមានការប្រព្រឹត្តិបទល្មើស ។ សហកម្មឧក្រិដ្ឋកម្មរួម គឺជាទម្រង់នៃការទទួលខុសត្រូវមួយដ៏សមស្រប ពីព្រោះវាឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវពិតប្រាកដនូវទង្វើឧក្រិដ្ឋទាំងស្រុងនៅក្នុងស្ថានភាពផ្សេងៗ ដែលទម្រង់នៃការទទួលខុសត្រូវផងទៃទៀតនឹងមិនត្រូវបានថ្លែងឲ្យអស់សេចក្ដី អំពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់សហចារី ។

[73] សាលដីកាសម្រេចលើករណីរបស់ Tadić, កថាខណ្ឌទី ១៩០ ។

[74] *សាលដីកាសម្រេចលើករណីរបស់ Tadić*, កថាខណ្ឌទី ១៩៥, ២២០, ២២៦-២២៧ ។ ក្នុងករណី Tadić បានរកឃើញថា ក្នុងខណៈដែលច្បាប់ និងយុត្តិសាស្ត្រនៅក្រោយសង្គ្រាមលោកលើកទី II មិនបានសំដៅទៅលើ "សហកម្មឧក្រិដ្ឋកម្មរួម" ចំៗក៏ដោយ តែបរិបទនៃពាក្យថា "គោលបំណងរួម" និង "ផែនការរួម" គឺជាពាក្យដែលមានន័យដូចគ្នានឹងពាក្យ សហកម្មឧក្រិដ្ឋកម្មរួម ។

នៅក្នុងឯកសារច្បាប់ជាសារវ័ន្តចំនួនបី ចាប់ពីសម័យក្រោយសង្គ្រាម៖ ធម្មនុញ្ញទីក្រុងឡុងស្តីពីតុលាការយោធាអន្តរជាតិ (“ធម្មនុញ្ញ IMT” និង “IMT”)[75] ច្បាប់គ្រប់គ្រងក្រុមប្រឹក្សាលេខ១០ (“ច្បាប់គ្រប់គ្រងក្រុមប្រឹក្សា”)[76] និងធម្មនុញ្ញនៃតុលាការយោធាអន្តរជាតិសំរាប់ចុងបូព៌ា[77]។ ធម្មនុញ្ញ IMT ចែងថា ជនណាមួយដែលបានចូលរួមនៅក្នុងផែនការរួម ឬការសមគំនិត ដើម្បីប្រព្រឹត្តបទឧក្រិដ្ឋណាមួយនៅក្រោមធម្មនុញ្ញ IMT នឹងត្រូវទទួលខុសត្រូវចំពោះគ្រប់ទង្វើទាំងអស់ ដែលបានប្រព្រឹត្តនៅក្នុងការអនុវត្តន៍ផែនការរួម ឬការសមគំនិតនោះ[78]។ ជាពិសេស គេបានដាក់បញ្ចូលខ្លឹមសារស្រដៀងគ្នានេះទៅក្នុងមាត្រា ៥ នៃតុលាការយោធាអន្តរជាតិសំរាប់ចុងបូព៌ា ។ មាត្រា ២.២ នៃច្បាប់គ្រប់គ្រងក្រុមប្រឹក្សាបានបង្កើតឲ្យមានការទទួលខុសត្រូវចំពោះជនទាំងឡាយណាដែលបាន “ភ្ជាប់ខ្លួនទៅនឹងផែនការ ឬ សហកម្មនោះ” ដែលកំពុងចូលរួមប្រព្រឹត្តឧក្រិដ្ឋកម្មអ្វីមួយ។

៥៣. បន្ថែមទៅលើ សវនាការរបស់តុលាការ IMT និងសវនាការទាំងឡាយ ដែលបានដំណើរការទៅតាមច្បាប់គ្រប់គ្រងក្រុមប្រឹក្សា ក៏នៅមានជំនុំជម្រះក្តីថ្នាក់ជាតិចំនួនរាប់ពាន់រឿងក្តីទៀតផងដែរ[79] ។ ការជំនុំជម្រះក្តីទាំងនោះ គឺមានការទាក់ទងគ្នា ពីព្រោះពួកវាបានជួយសម្រេចថា សហកម្មឧក្រិដ្ឋកម្មរួម គឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ[80] ។ វាមានលក្ខណៈច្បាស់លាស់ដែល សាលក្រមនានារបស់តុលាការយោធានៃប្រទេសអង់គ្លេស[81] បានអនុវត្ត

---

*សាលដីកាសម្រេចលើករណីរបស់ Milutinović*, មតិដោយឡែករបស់ចៅក្រម David Hunt, កថាខណ្ឌទី ៣-៥ ។ *សាលដីកាសម្រេចលើករណីរបស់ Milutinović*, កថាខណ្ឌទី ៣៦ ។

[75] ធម្មនុញ្ញទីក្រុងឡុងនៃតុលាការយោធាអន្តរជាតិ, មាត្រា ៦ [*បន្ទាប់ពីនេះទៅហៅថា៖* ធម្មនុញ្ញ IMT] ។

[76] ច្បាប់គ្រប់គ្រងក្រុមប្រឹក្សាលេខ១០ *នៅក្នុងរដ្ឋកិច្ចផ្លូវការនៃក្រុមប្រឹក្សាគ្រប់គ្រងប្រទេសអាល្លឺម៉ង់* (១៩៤៦), ភាគទី ៣ ទំព័រទី ៥០ [*បន្ទាប់ពី នេះទៅហៅថា៖* ច្បាប់គ្រប់គ្រងក្រុមប្រឹក្សា] ។

[77] ធម្មនុញ្ញនៃតុលាការយោធាអន្តរជាតិសំរាប់ចុងបូព៌ា, មាត្រា ៥ ។

[78] ធម្មនុញ្ញ IMT, មាត្រា ៦ ។

[79] M. Cherif Bassiouni, ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ។ ការបោះពុម្ពផ្សាយលើកទី ២ ។ (ទីក្រុងឡាអេ៖ Kluwer Law International, ឆ្នាំ១៩៩៩) ទំព័រទី ៥៣១-៥៣២ ។

[80] សាលដីកាសម្រេចលើករណីរបស់ Tadić, កថាខណ្ឌទី ១៩៥-២១៩ ។

[81] ករណីទាំងអស់បានជំនុំជម្រះក្នុងតំបន់ក្នុងប្រទេសអង់គ្លេស។ សូមមើលបន្ថែម រាជ្យដីកា បទប្បញ្ញត្តិស្តីអំពីការកាត់ទោសឧក្រិដ្ឋកម្មសង្គ្រាម ១១៦០/២៤៩៨។ គេហទំព័រ http://www.yale.edu/lawweb/avalon/imt/imtroyal.htm

នូវទម្រង់នៃសហកម្មឧក្រិដ្ឋកម្មរួមនេះ ។ ក្នុងករណី Essen Lynching[82] តុលាការនេះបាន រកឃើញថា ជនស៊ីវិលចំនួន៣នាក់ "មានទោស ពីព្រោះពួកគេម្នាក់ៗសុទ្ធតែបានចូលរួម បើមិនក្នុងរបៀបមួយនេះ ក៏របៀបមួយផ្សេងទៀតដែរ ក្នុងការធ្វើទុក្ខបុកម្នេញ ដែល ក្រោយមក បណ្តាលឱ្យជនរងគ្រោះស្លាប់បាត់បង់ជីវិត" ទោះបីជាគ្មានភស្តុតាងបញ្ជាក់ថា គ្មានពួកគេណាម្នាក់ពិតជាបានបាញ់សម្លាប់ ឬវាយជនរងគ្រោះរហូតដល់ស្លាប់ក្តី[83]។

៥៤. នៅក្នុងសវនាការជំនុំជម្រះក្តីករណី *Almelo Trial* ចៅក្រមយោធាបានពន្យល់ថា៖"ប្រសិនបើ មនុស្សទាំងអស់បង្ហាញខ្លួនទាំងអស់គ្នាក្នុងពេលតែមួយ ដោយចូលរួមនៅក្នុងសហកម្មរួមដែល ជាអំពើខុសនឹងច្បាប់ ហើយតាមមធ្យោបាយផ្ទាល់ខ្លួន មនុស្សម្នាក់ៗក្នុងចំណោមពួកគេ ជួយ នៅក្នុងគោលបំណងរួមរបស់មនុស្សទាំងអស់ នោះពួកគេទាំងអស់គ្នាមានពិរុទ្ធស្មើៗគ្នាទៅ តាមច្បាប់"[84]។ ក្នុងករណី Jespen តុលាការបានប្រើប្រាស់ទម្រង់នៃសហកម្មឧក្រិដ្ឋរួម ដើម្បីដាក់ការទទួលខុសត្រូវចំពោះការសម្លាប់ឈ្លើយសឹក[85]។ សរុបសេចក្តីមក ចៅក្រម តស៊ូមតិ (Judge Advocate) កត់សម្គាល់ថា ប្រសិនបើ Jespen បានចូលរួម ដោយសកម្ម ដោយខ្លួនឯង និងបានជួយទំនុកបម្រុងអ្នកយាមផ្សេងទៀតឱ្យមានការសម្លាប់រង្គាលនោះ អំពើរបស់អ្នកណាម្នាក់ក្នុងចំណោមអ្នកទាំងនោះគឺជាអំពើរបស់អ្នកទាំងអស់គ្នាតែម្តង[86]។

---

[82] មាននៅក្នុង re Erich Heyer et al, តុលាការយោធាចក្រភពអង់គ្លេស សម្រាប់ការកាត់ទោសឧក្រិដ្ឋកម្មសង្គ្រាម Essen (ត្រូវបានពិភាក្សាក្នុងរបាយការណ៍ច្បាប់របស់អង្គការសហប្រជាជាតិ សម្រាប់ការកាត់ទោសឧក្រិដ្ឋកម្មសង្គ្រាម, គណៈកម្មាធិការ ឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ ៨៨ (១៩៤៧) [*បន្ទាប់ពីនេះទៅហៅថា៖* ករណី Lynching Case]

[83] ករណី Lynching Case, ទំព័រទី ៩១ ។

[84] *ការជំនុំជម្រះក្តីលើករណីរបស់ Almelo,* ការជំនុំជម្រះក្តីលើករណីរបស់ Otto Sandrock និងជនចំនួន ៣ នាក់ផ្សេងទៀត, តុលាការយោធាអង់គ្លេសសម្រាប់ជំនុំជម្រះក្តីឧក្រិដ្ឋជនសង្គ្រាម, ទំព័រទី ៤០ (បានពិភាក្សានៅក្នុងរបាយការណ៍ច្បាប់សម្រាប់ជំនុំជម្រះក្តី ឧក្រិដ្ឋជនសង្គ្រាម, គណៈកម្មការទទួលបន្ទុកកិច្ចការឧក្រិដ្ឋកម្មសង្គ្រាមនៃអង្គការសហប្រជាជាតិ (ឆ្នាំ១៩៤៩) [*បន្ទាប់ពីនេះទៅហៅថា៖* ការជំនុំជម្រះក្តីលើករណីរបស់ Almelo] ។

[85] *Gustav Alfred Jespen* តុលាការយោធាចក្រភពអង់គ្លេស, Luneburg សាលក្រម ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ១៩៤៦, Journal of International Criminal Justice, ខែមីនា ឆ្នាំ២០០៧, ទំព័រទី ២២៨ ។ [*បន្ទាប់ពីនេះទៅហៅថា៖* សាលក្រម Jespen] ។

[86] សាលក្រម Jespen, ទំព័រទី ២២៩ ។

៥៥. នៅក្នុងសវនាការជំនុំជម្រះក្តីករណីជំរុំប្រមូលផ្តុំ *Dachau Concentration Camp* តុលាការយោធាអាមេរិក[87] បានសន្និដ្ឋានជាចុងក្រោយថា "នៅក្នុងជំរុំ មានប្រព័ន្ធជាទូទៅមួយនៃអំពើឃោរឃៅ និងការធ្វើមនុស្សឃាតទៅលើអ្នកទោស", ថា "ប្រព័ន្ធនេះ ត្រូវបានអនុវត្តដោយមានការ ដឹងឮរបស់ជនសង្ស័យដែលពួកគេជាសមាជិកនៃបុគ្គលិក និងដោយមានការចូលរួមយ៉ាងសកម្មពីពួកគេ" ហើយថាអំពើនេះត្រូវបានធ្វើឡើង "ទៅតាមគំរោងផែនការរួមមួយដើម្បីរំលោភច្បាប់ និងទម្លាប់ធ្វើសង្គ្រាម"[88] ។ ករណី *Mauthausen Camp Case*[89] បានបង្កើតឲ្យមាន "របកគំហើញពិសេសចំនួនបី"៖(១) ការប្រព្រឹត្តិទៅរបស់ជំរុំ គឺជាសហឧក្រិដ្ឋកម្មមួយ (២) មន្ត្រីទាំងអស់នៅក្នុងជំរុំដែលបានបំរើការងារ ឬដែលគ្រាន់តែមានវត្តមាននៅក្នុងជំរុំនៅពេលណាមួយត្រូវតែបានដឹងពីឧក្រិដ្ឋភាពនៃសហាកម្មនោះ និង (៣) មន្ត្រីទាំងអស់ដែលបានចូលរួមពាក់ព័ន្ធនៅក្នុងប្រតិបត្តិការនៃសហាកម្មឧក្រិដ្ឋកម្មនេះ "ទោះតាមមធ្យាបាយណាមួយក៏ដោយ" ត្រូវមានពិរុទ្ធអំពីការរំលោភច្បាប់ និងទម្លាប់ធ្វើសង្គ្រាម"[90]។ អង្គហេតុនានានៃករណី *Borkum Island Case* បានផ្តល់យោបល់ថា ចុងចោទត្រូវបានកាត់ឲ្យជាប់ទោសដោយសារពួកគេ "បានចូលរួមនៅក្នុងគំរោងសហាកម្មឧក្រិដ្ឋកម្មរួម ដែលមានការពាក់ព័ន្ធក្នុងការធ្វើមនុស្សឃាតទៅលើឈ្លើយសឹក[91]។

[87] តុលាការយោធាអាមេរិកបានត្រូវបង្កើតឡើងស្របតាម សេចក្តីបង្គាប់ស្តីពីការកំណត់អត្តសញ្ញាណ និងការចាប់ខ្លួនជនសង្ស័យនៃឧក្រិដ្ឋកម្មសង្គ្រាម ឬបទល្មើសផ្សេងទៀត និងការជំនុំជម្រះក្តីជនល្មើសជាក់លាក់, ចុះថ្ងៃទី០៨ កក្កដា ១៩៤៥, ច្បាប់ចម្លងលេខ ២៦ JCS. 1023/10, មាត្រា ៣, អាចរកមើលបាននៅក្នុងគេហទំព័រ http://www.yale.edu/lawweb/avalon/imt/imtjcs.htm [*បន្ទាប់ពីនេះទៅហៅថា៖* សេចក្តីបង្គាប់] ។ សេចក្តីបង្គាប់នេះ បានបញ្ជាក់ថា ពាក្យថា "ឧក្រិដ្ឋជន" រាប់បញ្ចូលទាំងជនទាំងឡាយណាដែល "បានជាប់ជំពាក់ជាមួយនឹងផែនការ ឬសហាកម្មដែលជាក់ទាក់ទិននៅក្នុង" ការប្រព្រឹត្តិបទឧក្រិដ្ឋណាមួយ ។

[88] *ការជំនុំជម្រះក្តីលើករណីជំរុំប្រមូលផ្តុំ Dachau (Dachau Concentration Camp Trial),* ការជំនុំជម្រះក្តីលើករណីរបស់ Martin Gottfried Weiss និងជនចំនួន ៣៩ នាក់ផ្សេងទៀត, តុលាការរដ្ឋាភិបាលយោធាទូទៅនៃតំបន់សហរដ្ឋអាមេរិក (General Military Government Court of the United States Zone), *ដែលបានបោះពុម្ពឡើងវិញនៅក្នុង* របាយការណ៍ច្បាប់ស្តីពីការជំនុំជម្រះក្តីឧក្រិដ្ឋជនសង្គ្រាម របស់គណៈកម្មការទទួលបន្ទុកឧក្រិដ្ឋកម្មសង្គ្រាមនៃអង្គការសហប្រជាជាតិ ឆ្នាំ១៩៤៧, ទំព័រទី ១៤ [*បន្ទាប់ពីនេះទៅហៅថា៖* ការជំនុំជម្រះក្តីលើករណីជំរុំប្រមូលផ្តុំ Dachau] ។

[89] តុលាការរដ្ឋាភិបាលយោធាទូទៅនៃតំបន់សហរដ្ឋអាមេរិក, Dachau, ប្រទេសអាល្លឺម៉ង់, ចុះថ្ងៃទី២៩ មីនា - ១៣ ឧសភា ១៩៤៦ (ដែលបានពិភាក្សានៅក្នុងការជំនុំជម្រះក្តីលើករណីជំរុំប្រមូលផ្តុំ Dachau, ទំព័រទី ១៥-១៦) ។

[90] ការជំនុំជម្រះក្តីលើករណីជំរុំប្រមូលផ្តុំ Dachau, ទំព័រទី ១៥ ។

[91] សេចក្តីសម្រេចលើករណីរបស់ Tadić, កថាខណ្ឌទី ២១០ ។

៥៦. មានករណីរឿងមួយចំនួនក្នុងសង្គ្រាមលោកលើកទីពីរ ដែលបានធ្វើការសម្រេចដោយតុលាការអ៊ីតាលីផងដែរ ដោយអនុវត្តតាមច្បាប់អ៊ីតាលី ដែលច្បាប់នេះបានអនុម័តនូវទម្រង់នៃការទទួលខុសត្រូវ មានលក្ខណៈស្រដៀងគ្នាទៅនឹងសហកម្មឧក្រិដ្ឋកម្មរួមនេះដែរ[92]។ លើសពីនេះទៀត យុត្តិសាស្ត្រនៃច្បាប់អង់គ្លេ-អាមេរិកាំង និងច្បាប់ស៊ីវិលជាច្រើន សុទ្ធតែមាននិយាយអំពីទម្រង់នៃការទទួលខុសត្រូវប្រហាក់ប្រហែលគ្នានឹងសហកម្មឧក្រិដ្ឋកម្មរួមដែរ[93]។ ធម្មនុញ្ញ IMT, Control Civil Law និងសេចក្តីសម្រេចនានារបស់តុលាការ ដែលបានពិចារណាទៅលើទង្វើកើតចេញពីសង្គ្រាមលោកលើកទី២ ថាសុទ្ធតែជាការចូលរួមក្នុងគោលបំណង ឬផែនការឧក្រិដ្ឋកម្មរួមគឺជាទម្រង់នៃការទទួលខុសត្រូវមុនដែនអាជ្ញាយុកាលនៃតុលាការនេះ។

៥៧. ច្បាប់ អ.វ.ត.ក ដាក់បញ្ចូលគោលការណ៍នីត្យានុកូលភាព ដែលមានចែងនៅក្នុងមាត្រា១៥(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ("ICCPR")[94] ។ គោលការណ៍នីត្យានុកូលភាពនេះ តម្រូវឲ្យច្បាប់ដែលបានប្រើប្រាស់ដើម្បីចោទប្រកាន់លើចុងចោទណាម្នាក់ត្រូវតែមានលក្ខណៈអាចព្យាករណ៍បាន និងលទ្ធភាពទទួលបានយ៉ាងគ្រប់គ្រាន់ នៅក្នុងពេល

[92] សេចក្តីសម្រេចលើករណីរបស់ Tadić, កថាខណ្ឌទី ២១៤-២១៨ ។ ឧទាហរណ៍ករណី D'Ottavio តុលាការបានអនុវត្តមាត្រា ១១៦ នៃក្រមព្រហ្មទណ្ឌអ៊ីតាលីដែលចែងថា "នៅពេលណាក៏ដោយដែលបទឧក្រិដ្ឋបានប្រព្រឹត្តឡើង ដែលមានលក្ខណៈខុសពីឆន្ទៈចង់បានរបស់អ្នកចូលរួមម្នាក់ ក្នុងចំណោមអ្នកចូលរួមទាំងអស់ អ្នកចូលរួមរូបនោះក៏ឆ្លើយចំពោះបទឧក្រិដ្ឋនោះដែរ ប្រសិនបើមានអង្គហេតុបង្ហាញថា វាគឺជាផលវិបាកដែលបានកើតចេញពីសកម្មភាព ឬការខកខានរបស់ខ្លួន" *ករណីរបស់ D'Ottavio,* សាលាវិនិច្ឆ័យប្រទេសអ៊ីតាលី, ផ្នែកព្រហ្មទណ្ឌ ទី១, សាលដីកា ថ្ងៃទី១២ មីនា ១៩៤៧, លេខ ២៧០, *បោះពុម្ពឡើងវិញនៅក្នុង* ទិនានុប្បវត្តិនៃយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ ៥, ២៣២, ខែមីនា ឆ្នាំ២០០៧ ។

[93] សេចក្តីសម្រេចលើករណីរបស់ Tadić, កថាខណ្ឌទី ២២៤។ ឧទាហរណ៍ ចាប់តាំងពីឆ្នាំ១៩៤៧ ប្រទេសបារាំងបានចាប់ផ្តើមអនុវត្តសញ្ញាណនៃ "សហចារី" ដែលចែងថា ប្រសិនបើបុគ្គលណាម្នាក់ ដែលបានចូលរួមក្នុងផែនការ ឬសហកម្មឧក្រិដ្ឋកម្មរួម ពិតជាបានចូលរួមប្រព្រឹត្តបទឧក្រិដ្ឋ ដែលអាចស្ថិតក្រៅវង្វង់នៃផែនការរួម ប៉ុន្តែវាជាអំពើដែលគេអាចដឹងមុន អ្នកទាំងអស់គ្នាសុទ្ធតែជាអ្នកទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនោះ ។ សេចក្តីសម្រេចលើករណីរបស់ Tadić , កថាខណ្ឌទី ២២៤ ។

[94] មាត្រា៣៣(ថ្មី) នៃច្បាប់អ.វ.ត.ក (ដោយបញ្ចូលមាត្រា១៤ និងមាត្រា១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ("ICCPR") ។ មាត្រា១៥(១) នៃ ICCPR ចែងថា "គ្មានបុគ្គលណាម្នាក់ត្រូវបានគេដាក់ឲ្យទទួលពិរុទ្ធលើបទល្មើសព្រហ្មទណ្ឌ ចំពោះអំពើ ឬកំហុសអកម្មណាបានមួយឡើយ បើសិនវាមិនបានរួមបង្កើតបានជាបទល្មើសព្រហ្មទណ្ឌណាមួយ នៅក្រោមច្បាប់ជាតិ និងច្បាប់អន្តរជាតិ នៅពេលដែលបទល្មើសនោះត្រូវបានប្រព្រឹត្តឡើង" ។

ប្រព្រឹត្តអំពីឧក្រិដ្ឋនោះត្រូវបានចោទប្រកាន់[95] ។ ដោយការប្រើប្រាស់សហកម្មឧក្រិដ្ឋកម្មរួមធ្វើជាទម្រង់មួយនៃការទទួលខុសត្រូវ វាមិនរំលោភលើគោលការណ៍នីត្យានុកូលភាពនោះទេ បើសិន បទឧក្រិដ្ឋរបស់ជនជាប់ចោទមានលក្ខណៈសាហាវឃោរឃៅនោះ ហើយក៏មានសេចក្ដីសម្រេចតាមផ្លូវតុលាការ លិខិតុបករណ៍អន្តរជាតិ និងច្បាប់ជាតិនានាដែលទទួលស្គាល់ទម្រង់នៃការទទួលខុសត្រូវដែលមានលក្ខណៈស្រដៀងគ្នានឹងសហកម្មឧក្រិដ្ឋកម្មរួមនេះដែរ[96] ។

៥៨. កត្តាទាំងពីរនេះ មានបង្ហាញជូននៅក្នុងរឿងក្ដីដែលកំពុងសិក្សានេះ ។ ទីមួយ បទឧក្រិដ្ឋទាំងឡាយដែលបានធ្វើការចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ មានលក្ខណៈសាហាវឃោរឃៅ ដោយរួមបញ្ចូលទាំងចំនួនជាងដប់ពីរពាន់នៃការសម្លាប់ ការធ្វើទារុណកម្មជាប្រព័ន្ធ និងលក្ខខណ្ឌឃុំឃាំងដោយអមនុស្សធម៌[97] ។ បុគ្គលណាក៏ដោយដែលមិនលំអៀង អាចដឹងបានថាអំពើទាំងអស់នេះមុខជានឹងនាំឱ្យមានការទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌមិនខាន[98] ។ ទីពីរ លិខិតុបករណ៍ និងសាលក្រមនានា ដែលកើតចេញពី

[95] សេចក្ដីសម្រេចលើករណីរបស់ Milutinović, កថាខណ្ឌទី ៣៧ ។ ប៉ុន្តែ ការណ៍នេះមិនបានរារាំងតុលាការមិនឱ្យ “ធ្វើការបកស្រាយ ឬបញ្ជាក់អំពីធាតុផ្សំនៃបទល្មើសជាក់លាក់ណាមួយនោះទេ” ហើយក៏មិនបានប្រាមចោលដំណើរជឿនលឿននៃច្បាប់ក៏ទេដែរ ។ សេចក្ដីសម្រេចលើករណីរបស់ Milutinović, កថាខណ្ឌទី ៣៨ ។

[96] សេចក្ដីសម្រេចលើករណីរបស់ Milutinović, កថាខណ្ឌទី ៣៩-៤២ ។ កត្តាទាំងពីរនេះតំណាងឱ្យ “ភាពអាចព្យាករណ៍ជាមុន” និង “លទ្ធភាពអាចទទួលបាន” ។ លក្ខណៈសាហាវឃោរឃៅនៃបទឧក្រិដ្ឋបង្កើតបាននូវការផ្ដន្ទាទោសដែលគេអាចព្យាករណ៍ទុកជាមុនបាន ខណៈដែលអត្ថិភាពនៃសេចក្ដីសម្រេចតាមផ្លូវតុលាការ លិខិតុបករណ៍អន្តរជាតិ និងច្បាប់របស់ប្រទេសបង្កើតបាននូវច្បាប់ដែលបង្កលទ្ធភាពដល់ជនជាប់ចោទ ។

[97] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌទី ១០៧-១២៨ (ការសម្លាប់), កថាខណ្ឌទី ៨៥-៨៩ (ការប្រើប្រាស់ទារុណកម្មជាប្រព័ន្ធ), កថាខណ្ឌទី ១០០-១០៥ (វិធីសាស្ត្រធ្វើទារុណកម្ម), កថាខណ្ឌទី ៦២-៧១ (លក្ខខណ្ឌនៃការឃុំខ្លួន) ។

[98] ជាការពិតណាស់ **ឌុច** ព្យាករណ៍ជាមុនថា សកម្មភាពផ្សេងៗរបស់គាត់ ជាលទ្ធផលនឹងនាំឱ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ។ **ឌុច** បានសារភាពថា គាត់បានដឹងតាំងពីពេលដំបូងមកម្ល៉េះថា ការងាររបស់គាត់ក្នុងការទទួលបានចម្លើយសារភាពនានា ជាការបញ្ឆោត និងថា ចម្លើយសារភាពនានាគ្រាន់តែជា “ការដោះសារដើម្បីកំទេចជនណាដែលតំណាងឱ្យឧបសគ្គ” និងថា ការងារ របស់មន្ទីរស-២១ គឺ “ពិតណាស់ថាវាគ្មានវិសមិតភាពនឹងអត្ថិភាពរបស់តុលាការ និងការការពារ នោះទេ” ។ ដីកាបញ្ជូនរឿងទៅ ជំនុំជម្រះ កថាខណ្ឌទី៤៤ ។ គាត់បានសារភាពលើការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងនៅមន្ទីរស-២១ តាមការបញ្ជារបស់គាត់ ហើយគាត់បានដឹងថា “ចាប់ពីឆ្នាំ១៩៧១តទៅ” គាត់បានក្លាយទៅជា“អ្នកប្រព្រឹត្តម្នាក់ក្នុងអំពើឧក្រិដ្ឋនានា”, ដដែលដូចខាងលើ កថាខណ្ឌទី១៦៧, ១៦៩។

កិច្ចខិតខំប្រឹងប្រែងនានានៅក្រោយសម័យសង្គ្រាមលោកលើកទីពីរ ដើម្បីធ្វើការចោទប្រកាន់ឧក្រិដ្ឋជនសង្គ្រាម តាមរយៈនៃការប្រើប្រាស់ទូលំទូលាយនូវប្រភេទនៃការទទួលខុសត្រូវនៃសហកម្មឧក្រិដ្ឋកម្មរួម ទាំងក្នុងប្រព័ន្ធច្បាប់អង់គ្លេ-អាមេរិកាំង និងប្រពន្ធ័ច្បាប់ស៊ីវីល គឺវាមានលក្ខណៈគ្រប់គ្រាន់ហើយ ដើម្បីជាកិច្ចគាំទ្រដល់របកគំហើញដែលថា ចុងចោទទាំងឡាយនៅចំពោះមុខតុលាការនេះ បានកត់សំគាល់ថា ការចូលរួមនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម នឹងតម្រូវឲ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ។ ការសន្និដ្ឋាននោះ បានជួយពង្រឹងតាមរយៈបទបញ្ញត្តិនានានៃ ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ដែលមានមាត្រាជាច្រើនធ្វើការចោទប្រកាន់ចំពោះអំពើឧក្រិដ្ឋកម្មផ្សេងៗដែលធ្វើឡើង ដោយក្រុមមនុស្សដែលធ្វើសកម្មភាពរួមជាមួយគ្នា[99] ។

## ខ. អង្គហេតុនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះកំណត់បាននូវការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួម

៥៩. ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទុកនូវអង្គហេតុទាំងអស់ ដែលចាំបាច់ក្នុងការចោទប្រកាន់ឌុច ចំពោះការចូលរួមរបស់ខ្លួននៅក្នុងសហកម្មឧក្រិដ្ឋកម្មរួមនៅមន្ទីរស-២១ ។ ជាផលវិបាក សហចៅក្រមស៊ើបអង្កេតត្រូវបានតម្រូវឱ្យចោទប្រកាន់ **ឌុច** ចំពោះការចូលរួមរបស់ខ្លួននៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម ដូចបានលើកឡើងខាងលើ។ សហព្រះរាជអាជ្ញា មិនមែនសុំឱ្យអង្គបុរេជំនុំជម្រះធ្វើការស្វែងរកអង្គហេតុថ្មីឡើយ ពីព្រោះធាតុផ្សំនៃសហកម្មឧក្រិដ្ឋកម្មរួមត្រូវបានរៀបរាប់យ៉ាងសាមញ្ញងាយយល់នៅក្នុងការរកឃើញអង្គហេតុនៅក្នុង ដីកាបញ្ជូនរឿងទៅជំនុំជម្រះរួចស្រេចហើយ។

---

[99] មាត្រា៨២ មាត្រា១៤៥ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ [*ចាប់ពីនេះតទៅហៅថា* ក្រមព្រហ្មទណ្ឌ] ។ មាត្រាទាំងនេះ បែងចែកបទឧក្រិដ្ឋ ដែលមានការពាក់ព័ន្ធបុគ្គលច្រើនជាងម្នាក់ទៅជាពីរជំពូក: "ការរួមប្រព្រឹត្ត" និង "ការសមគំនិត", មាត្រា៨២ នៃក្រមព្រហ្មទណ្ឌ ។ ដើម្បីមានលក្ខណៈគ្រប់គ្រាន់ជាសហចារី ជនជាប់ចោទរូបនោះត្រូវចូលរួមដោយផ្ទាល់ និងដោយចេតនា ក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋណាមួយ ។ ក្រមព្រហ្មទណ្ឌនេះ ផ្តល់និយមន័យអំពី "ចារីដើមគំនិត" នៃឧក្រិដ្ឋកម្ម ។ ក្រមនេះបានចែងថា មានអ្នកចូលរួមប្រព្រឹត្តច្រើនគ្នា នៅពេលណាមានសកម្មភាពរបស់អ្នកទីពីរបន្ថែមចំនួនដែលគ្រាន់តែមាន ការជួយ ឬការទំនុកបំរុង តែប៉ុណ្ណោះពេលនោះ ជននោះត្រូវគេបានពិចារណាថា ជាជនសមគំនិត មិនមែនជា ចារីដើមគំនិត ទេ ។

៦០. ក្រុមបុគ្គលដែលបានចូលរួមនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួមត្រូវបានរៀបរាប់នៅក្នុង កថាខណ្ឌ ២០ ២១ និង ២២ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយបញ្ចូលសមាជិកនៃគណៈមន្ទីរ ស-២១។ ដូចដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះពិពណ៌នាស្រាប់[100] គោលបំណងច្បាស់មិនអាចប្រកែកបានរបស់មន្ទីរស-២១ គឺការស្វែងរក "ខ្មាំង"ពិតប្រាកដនិងតាមការគិត និងបន្ទាប់មកមានការចាប់ខ្លួនដោយខុសច្បាប់ ការឃុំខ្លួន ការធ្វើទារុណកម្ម និង យកទៅសម្លាប់ចោល។ គោលបំណងរួមនៃគណៈមន្ទីរស-២១ក្នុងនោះមាន **ឌុច** ម្នាក់ផងគឺដើម្បីសម្រេចឱ្យបាននូវគោលបំណងទាំងនេះតាមរយៈការប្រព្រឹត្តិនូវបទឧក្រិដ្ឋនានា ដែលបានរៀបរាប់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះរកឃើញថា"តាមរយៈតួនាទី អំណាចដែលបានអនុវត្តនៅមន្ទីរ ស-២១ **ឌុច** បានដឹងអំពីគោលបំណងនៃមន្ទីរនេះ"[101]។

៦១. ស្តែងចេញពីអង្គហេតុដែលបានរកឃើញនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជាការច្បាស់ណាស់ថា **ឌុច** បានចូលរួមនៅក្នុងរាល់ដំណាក់កាលនីមួយៗនៃប្រតិបត្តិការរបស់មន្ទីរស-២១។ អំពើទាំងនេះរួមបញ្ចូលការចូលរួមក្នុងកិច្ចប្រជុំបង្កើតមន្ទីរស-២១[102] ការជ្រើសរើសបុគ្គលិកដែលមានបទពិសោធន៍មកពីមន្ទីរម-១៣ របស់គាត់ពីមុនមកឱ្យធ្វើការនៅ មន្ទីរស-២១[103] អនុវត្តវិធានទូទៅរបស់បក្សនៅមន្ទីរស-២១[104] ផ្សព្វផ្សាយមាគ៌ានយោបាយ "កម្ទេច" ខ្មាំងតាមរយៈការប្រជុំការងារជាមួយបុគ្គលិកនៅមន្ទីរស-២១[105] អនុវត្តសិទ្ធិផ្តាច់មុខក្នុងមន្ទីរស-២១ ក្នុងការទំនាក់ទំនងជាមួយមេដឹកនាំជាន់ខ្ពស់លើកិច្ចការសន្តិសុខ[106] និងផ្តល់ជូនដល់មេដឹកនាំជាន់ខ្ពស់នូវការវិភាគរបស់ខ្លួនទៅលើ"ចម្លើយសារភាព" ដែលមានឥទ្ធិពលលើ

---

[100] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌទី ៣១ "តួនាទីជាចម្បងរបស់មន្ទីរស២១គឺការអនុវត្តន៍ "មាគ៌ានយោបាយបក្សចំពោះខ្មាំង" ដែលតាមរយៈមាគ៌ានេះ អ្នកទោស "ត្រូវតែកម្ទេចចោលជាដាច់ខាត"។

[101] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌទី ១៣១ ។ បន្ថែមលើនេះទៀត ឌុច បានទទួលស្គាល់ថា "ក្នុងតួនាទីរបស់គាត់ជាប្រធានមន្ទីរស-២១ គឺផ្តោតសំខាន់លើការកម្ទេចអ្នកដែលគេសន្មតថាជាជនក្បត់បង្កប់ក្នុងជួរបដិវត្តន៍" ។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌទី ៣៧ ។

[102] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌទី ២០ ។

[103] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌ ២១ ។

[104] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌទី ២៥ ។

[105] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌទី ៤០ ។

[106] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌទី ៤២ ។

សេចក្តីសម្រេចក្នុងការចាប់ខ្លួនជនសង្ស័យណាម្នាក់[107] ទំនាក់ទំនងដោយផ្ទាល់ ជាមួយប្រធានអង្គភាពផ្សេងៗទៀតអំពីការចាប់ខ្លួនកម្មាភិបាលពីអង្គភាពទាំងនេះ[108] ចូលរួមក្នុងកិច្ចប្រជុំនានាដែលក្នុងកិច្ចប្រជុំនោះមានការពិភាក្សាអំពីយុទ្ធសាស្ត្រ និងផែនការចាប់ខ្លួន[109] បង្រៀនបុគ្គលិកមន្ទីរស-២១ អំពីវិធីសាស្ត្រក្នុងការសួរចម្លើយ និង ធ្វើទារុណកម្ម[110] ធ្វើទុក្ខទោស និងធ្វើទារុណកម្មអ្នកទោសមន្ទីរ ស-២១ ដោយខ្លួនឯង [111]បញ្ជាឱ្យសម្លាប់មនុស្ស ទោះជាដោយផ្ទាល់និង/ឬ តាមរយៈការផ្ទេរអំណាចនេះទៅឱ្យកូនចៅក្រោមបង្គាប់[112] សម្រេចផ្លាស់ប្តូរកន្លែងសម្លាប់ជនរងគ្រោះមន្ទីរស-២១ ភាគច្រើនឱ្យទៅ កន្លែងផ្សេងឆ្ងាយពីបរិវេណមន្ទីរស-២១កណ្តាលដោយសារខ្លាចឆ្លងជំងឺ[113] បង្រៀនវិធីសម្លាប់មនុស្ស[114] និងមានវត្តមានយ៉ាងហោចណាស់មួយដងនៅវាលពិឃាតជើងឯក[115]។ អំពើទាំងនេះត្រូវបានកំណត់យ៉ាងត្រឹមត្រូវថាជាការចូលរួមយ៉ាងសំខាន់របស់ **ឌុច** ចំពោះគោលបំណងឧក្រិដ្ឋកម្មរួម នៃមន្ទីរស-២១[116] ។

៦២. ក្រោមទម្រង់ “ជាមូលដ្ឋាន” នៃសហកម្មឧក្រិដ្ឋកម្មរួម[117] ចេតនារបស់ ឌុច អាចទាញចេញពីការផ្សំគ្នានៃអំពើរបស់គាត់ក្នុងការសម្រេចនូវគោលបំណងរួម។ ជាងនេះទៀត ដីកាបញ្ជូនរឿងទៅជំនុំជម្រះបានរកឃើញជាក់ច្បាស់ថា **ឌុច** “បានមានចេតនាធ្វើឱ្យសកម្មភាពរបស់ខ្លួនចូលរួមចំណែកដល់” គោលបំណងឧក្រិដ្ឋកម្មនៅមន្ទីរស-២១[118]។ម្យ៉ាងវិញទៀត ក្រោម

[107] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌទី ៤៣ និង ៤៥ ។

[108] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌទី ៥៥ ។

[109] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌទី ៥៦ ។

[110] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌទី ៨៣ និង ៨៦ ។

[111] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌទី ៩០-១០០ ។

[112] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌទី ១០៧-១១០ ។

[113] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌទី ២៩ ។

[114] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌទី ១១០ ។

[115] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌទី ១០៩ និង ១១៣ ។

[116] រឿងក្តី *Kvocka* អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ថ្ងៃទី២៨ កុម្ភៈ ២០០៥ កថាខណ្ឌទី ៨៩ ។

[117] ករណីកាំង ហ្កេកអ៊ាវ ហៅ ឌុច វិធាន៦៦ នៃដីកាសន្និដ្ឋានស្ថាពរ ទាក់ទងនឹងករណីកាំង ហ្កេកអ៊ាវ ហៅ ឌុច ថ្ងៃទី១៨ កក្កដា ២០០៨, D96, កថាខណ្ឌទី ២៤៥, ២៤៦ និង ២៤៧ ។

[118] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌទី ១៣១ ។

ទម្រង់ "ជាប្រព័ន្ធ" នៃសហកម្មឧក្រិដ្ឋកម្មរួម[119] ការដឹងឮអំពីប្រព័ន្ធនៃការប្រព្រឹត្តិឃោរឃៅនៅក្នុងមន្ទីរស-២១ គឺមានលក្ខណៈច្បាស់ចេញពីអង្គហេតុ និងចេញពីការទទួលសារភាពរបស់ **ឌុច** ផ្ទាល់។ ផ្ទុយទៅវិញ ដោយអនុលោមទៅតាមទម្រង់"វិបុលកម្ម" នៃសហកម្មឧក្រិដ្ឋកម្មរួម ឧក្រិដ្ឋកម្មដែលបានរកឃើញក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺជាផលវិបាកជាធម្មតា និងដែលអាចព្យាករណ៍ទុកជាមុនអំពីគោលបំណងអនុវត្តសហកម្មឧក្រិដ្ឋកម្មរួម ។

## គ. ខកខានមិនបានបញ្ចូលសហកម្មឧក្រិដ្ឋកម្មរួមជាការកម្រិតមិនឱ្យអង្គជំនុំជម្រះមានលទ្ធភាពក្នុងការវាយតម្លៃពេញលេញទៅលើការទទួលខុសត្រូវ

៦៣. ការដែលខកខានមិនបានចោទអំពីការប្រព្រឹត្តិតាមរយៈសហកម្មឧក្រិដ្ឋកម្មរួម ដីកាបញ្ជូនរឿងទៅជំនុំជម្រះបានកម្រិតមិនឱ្យអង្គជំនុំជម្រះមានលទ្ធភាពរកឃើញថា **ឌុច** មានការទទួលខុសត្រូវតាមផ្លូវច្បាប់ចំពោះអំពើរបស់ខ្លួន។ ការខកខាននេះបង្កើតបានជាលទ្ធភាពសំខាន់មួយថា **ឌុច** អាចត្រឹមតែត្រូវបានដាក់ឱ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មភាគច្រើនរបស់ខ្លួននៅមន្ទីរស-២១ តាមរយៈទម្រង់នៃការទទួលខុសត្រូវ ក្នុងលក្ខណៈជាអ្នក"ជួយ និង ជំរុញ" ឬតាមរយៈការទទួលខុសត្រូវក្នុងនាមថ្នាក់លើតែប៉ុណ្ណោះ។ ក៏ប៉ុន្តែទម្រង់នៃការទទួលខុសត្រូវទាំងនេះអាចកំណត់ខុសនូវតួនាទីឧក្រិដ្ឋកម្មជាក់ស្តែងរបស់គាត់នៅមន្ទីរស-២១ ។ សហកម្មឧក្រិដ្ឋកម្មរួមមានលក្ខណៈចាំបាច់ក្នុងការធានាថាការសម្រេចទោស (ប្រសិនបើ **ឌុច** ត្រូវបានរកឃើញថាមានកំហុស) ឆ្លុះបញ្ចាំងពីភាពពេញលេញនៃអំពើព្រហ្មទណ្ឌរបស់គាត់ និងសារសំខាន់បំផុតនៃតួនាទីរបស់គាត់នៅក្នុងដំណើរប្រតិបត្តិការរបស់មន្ទីរស-២១។

៦៤. ក្រោមអត្ថន័យនៃពាក្យ **"ការប្រព្រឹត្តិ"** ដីកាបញ្ជូនរឿងទៅជំនុំជម្រះកម្រិតការចូលរួមរបស់ **ឌុច** តាមរយៈការប្រព្រឹត្តិជាក់ស្តែងរបស់ខ្លួននូវឧក្រិដ្ឋកម្មនានាបានតែមួយចំនួនតូចប៉ុណ្ណោះ។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅក្រោមទម្រង់នៃការទទួលខុសត្រូវនេះលើកឡើងថា **ឌុច** "ធ្វើទារុណកម្ម ឬ ធ្វើបាបអ្នកជាប់ឃុំឃាំងនៅមន្ទីរស-២១ ជាច្រើនលើកច្រើនសារក្នុងឱកាស

[119] ករណីកាំង ហ្គេកអ៊ាវ ហៅឌុច វិធាន៦៦ នៃដីកាសន្និដ្ឋានស្ថាពរ ទាក់ទងនឹងករណីកាំង ហ្គេកអ៊ាវ ហៅ ឌុច ថ្ងៃទី១៨ កក្កដា ២០០៨, D96, កថាខណ្ឌទី ២៤៥, ២៤៦ និង២៤៧ ។

ដាច់ដោយឡែកពីគ្នា"[120]។ ប្រការនេះហាក់មិនបានគ្រោបរាល់ការសម្លាប់ ឬការស្លាប់ផ្សេងទៀត ដែលកើតឡើងនៅមន្ទីរ ស-២១ ឡើយ។ ជាងនេះទៅទៀត វាហាក់ដូចជាមិនគ្រោបនូវវិសាលភាពពេញលេញនៃអំពី ទារុណកម្ម ឬ ការធ្វើបាបមកលើអ្នកជាប់ឃុំឃាំង ដែលត្រូវបានអនុវត្តនៅមន្ទីរស-២១[121]។ ដូចដែលបានលើកឡើងថ្មីៗនេះ នៅផ្នែកដែលនិយាយអំពីការប្រព្រឹត្តិបទល្មើសនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនបានគ្រោបឧក្រិដ្ឋកម្មភាគច្រើន ដែលបានប្រព្រឹត្តនៅមន្ទីរស-២១ ឡើយ។

៦៥. ក្រោមអត្ថន័យនៃពាក្យ "**ការរៀបចំផែនការ**" នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ បានរកឃើញថា **ឌុច** បានរៀបចំផែនការក្នុងការបង្កើតមន្ទីរស-២១ ដោយបានដឹងហើយអំពីមុខងារឧក្រិដ្ឋរបស់មន្ទីរនេះ ហើយគាត់ក៏បានរៀបចំផងដែរនូវផែនការឧក្រិដ្ឋកម្មជាក់លាក់នានាដែលត្រូវបានប្រព្រឹត្តនៅមន្ទីរស-២១[122] ។ សហព្រះរាជអាជ្ញា ជឿថារឿងនេះគឺជាការពិត ក៏ប៉ុន្តែអង្គហេតុទាំងឡាយដែលនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ អាចនឹងមិនគាំទ្រចំពោះ ការរកឃើញនោះទេ[123]។ ហេតុដូចនេះ គឺមានភាពដែលអាចកើតឡើងមួយថា ការទទួលខុសត្រូវរបស់ **ឌុច** នៅក្រោម(ចំណងជើងស្តីពី)ការរៀបចំផែនការ និងត្រូវបានកំរិតឱ្យមកនៅត្រឹមតែឧក្រិដ្ឋកម្ម ចំនួនមួយឈុតតូចដែលបានកើតឡើងនៅមន្ទីរស-២១ ។

[120] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌទី ១៥៣។

[121] ដោយអាស្រ័យលើការបកស្រាយទៅលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ វាអាចកម្រិតការទទួលខុសត្រូវនៃការប្រព្រឹត្តិរបស់ **ឌុច** ថាវាសំដៅតែទៅលើតែអំពើដូចដែលបានរៀបរាប់នៅក្នុងកថាខណ្ឌ ៨០-៨៤ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះ។

[122] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌទី ១៥៩។

[123] ចំពោះការបង្កើតមន្ទីរស-២១ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ គ្រាន់តែរកឃើញថា **ឌុច** បានជួបជាមួយមេដឹកនាំដទៃទៀត ដើម្បីរៀបចំផែនការបង្កើតមន្ទីរស-២១តែប៉ុណ្ណោះ។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះ មិនបានបញ្ជាក់ឱ្យឃើញច្បាស់អំពីថា តើមានអ្វីកើតឡើងនៅក្នុងពេលប្រជុំនោះ ឬ ក៏អំពីការចូលរួមជាក់ចំណែកជាក់លាក់របស់ **ឌុច** ក្នុងការរៀបចំផែនការនោះទេ។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះមាត្រា២០។ ចំណែកឯការរៀបចំផែនការសម្រាប់អំពើឧក្រិដ្ឋកម្មផ្សេងៗដែលបានប្រព្រឹត្តនៅមន្ទីរស-២១ ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនឃើញមាននិយាយបញ្ជាក់ពីការរកឃើញច្បាស់លាស់ណាមួយថា **ឌុច** បានរៀបចំផែនការនីមួយៗនោះទេ។ តាមពិត ទាក់ទងទៅនឹងលក្ខខណ្ឌនៃការឃុំឃាំង គឺមិនមានភាពច្បាស់លាស់ទេថា តើអ្នកណាជាអ្នកដែលបានរៀបចំផែនការទាំងនេះ។ កថាខណ្ឌទី ៦២-៧១។

00222072

D99/3/3



៦៦. ក្រោមអត្ថន័យនៃពាក្យ "**ការញុះញង់**" នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ បានរកឃើញថា **ឌុច** បាន "ជម្រុញ លើកទឹកចិត្ត និង ដាស់តឿនដល់បុគ្គលិក" ឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មទាំងឡាយ ដូចដែលបានរៀបរាប់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[124]។ ក៏ប៉ុន្តែ ឱកាសត្រូវបាន កំរិតកំណត់ឲ្យមកនៅត្រឹមតែមួយចំនួនប៉ុណ្ណោះ ដែលនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ បានបង្ហាញអត្តសញ្ញាណដ៏ច្បាស់លាស់អំពីករណីដែល **ឌុច** បាន ជម្រុញ លើកទឹកចិត្ត ឬ ដាស់តឿនដល់បុគ្គលិកឲ្យប្រព្រឹត្តអំពើឧក្រិដ្ឋផ្សេងៗ[125]។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិន បានរកឃើញដោយច្បាស់លាស់ថា **ឌុច** បានលើកទឹកចិត្ត ឬជម្រុញឲ្យប្រព្រឹត្តគ្រប់ឧក្រិដ្ឋកម្ម ទាំងអស់ដែលបានកើតឡើងនៅមន្ទីរស-២១នោះទេ[126]។ មានភាពអាចកើតឡើងមួយថា ការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់ **ឌុច** ក្រោម(ចំណងជើងស្តីពី)ការញុះញង់នឹងត្រូវបាន កំរិតកំណត់ឲ្យមកនៅត្រឹមតែអំពើមួយចំនួនតូចតែប៉ុណ្ណោះ។

៦៧. ក្រោមអត្ថន័យនៃពាក្យ "**ការបញ្ជា**" នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ បានរកឃើញថា "**ឌុច** បានមានលទ្ធភាពក្នុងការដឹកនាំ ណែនាំ ឬបញ្ជា អ្នកនៅក្រោមបង្គាប់ទាំងឡាយ របស់គាត់ឲ្យអនុវត្តនូវភារកិច្ចណាមួយដែលផ្សារភ្ជាប់ទៅនិងដំណើរការរបស់ពហុអគារមន្ទីរ ស-២១"[127]។ បទបញ្ជាដ៏ជាក់លាក់នានាដែលបានចេញដោយ **ឌុច** ត្រូវបានបង្ហាញ នៅក្នុង ផ្នែកផ្សេងៗទៀតនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ **ឌុច** ត្រូវបានរកឃើញថាបានបញ្ជាលើ ការធ្វើទារុណកម្ម[128] និងបញ្ជាលើការសម្លាប់នានា[129]។ ក៏ប៉ុន្តែ នៅក្នុងដីកាបញ្ជូនរឿង ទៅជំនុំជម្រះ បានទុកចំហរអំពីលទ្ធភាពដែលថា **ឌុច** មិនបានបញ្ជាទៅលើគ្រប់ករណីនៃ

---

[124] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌទី ១៦០ ។

[125] ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និយាយថា **ឌុច** បានចូលរួមនៅក្នុងវគ្គហ្វឹកហ្វឺននានានឹងបានបង្កើតគោលនយោបាយស្តីពីការសម្លាប់ក្រៅច្បាប់ (កថាខណ្ឌទី ៤០-៤២) បានបង្រៀនពីបច្ចេកទេសក្នុងការធ្វើទារុណកម្ម និងបានលើកទឹកចិត្តក្នុងការប្រើប្រាស់នូវទារុណកម្ម (កថាខណ្ឌទី៨៧ និង ទី៩៥-៩៨) និងបានលើកទឹកចិត្តឲ្យប្រើប្រាស់បច្ចេកទេសក្នុងការបរហារជីវិតដោយឡែកមួយ(កថាខណ្ឌទី ១១០)។

[126] ជាពិសេស មិនមានការរកឃើញថា **ឌុច** បានជំរុញ លើកទឹកចិត្ត ឬដាស់តឿនដល់បុគ្គលិកដើម្បីឲ្យធ្វើបាបទៅលើជនជាប់ឃុំនោះទេ ។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌទី ៦២-៧១។

[127] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌទី ១៥៤។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនបានរកឃើញថា ដីកាបង្គាប់ទាំងឡាយអាច មានលក្ខណៈ "ច្បាស់លាស់ មិនបាននិយាយច្បាស់លាស់ ទូលំទូលាយ ឬជាក់លាក់"នោះទេ។ ដូចខាងលើដែល កថាខណ្ឌទី ១៥៥។

[128] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌទី ៩៥។

[129] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌទី ១០៧។

ការធ្វើទារុណកម្ម ឬការសម្លាប់ទាំងអស់នោះទេ[130] ដែលធ្វើឱ្យកើតមាននូវលទ្ធភាពដែលអាចកើតឡើងមួយដែលថា **ឌុច** អាចនឹងមិនត្រូវទទួលខុសត្រូវទៅលើរាល់ការធ្វើទារុណកម្ម និងការសម្លាប់ទាំងអស់តាមរយៈការបញ្ជានោះទេ។ លើសពីនេះ ហាក់ដូចជាមិនមានការរកឃើញដ៏ច្បាស់លាស់ណាមួយដែលថា **ឌុច** បានបញ្ជាទៅលើលក្ខខណ្ឌនៃការឃុំឃាំងនៅក្នុងមន្ទីរស-២១[131] ដែលអាចជាលទ្ធផលគឺធ្វើឱ្យគាត់មិនត្រូវបានចាប់បង្ខំឱ្យទទួលខុសត្រូវចំពោះលក្ខខណ្ឌទាំងនោះតាមរយៈការបញ្ជានោះទេ។

៦៨. ក្រោមអត្ថន័យនៃពាក្យ "**ការជួយ និងជម្រុញ**" នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ បានគ្របដណ្តប់ទៅលើគ្រប់ការប្រព្រឹត្តិអំពើឧក្រិដ្ឋទាំងអស់ដែលបានកើតមាននៅមន្ទីរស-២១[132] ក៏ប៉ុន្តែការជួយ និងជម្រុញគឺជាទម្រង់នៃការទទួលខុសត្រូវមួយដែលមានលក្ខណៈស្រាលជាងសហកម្មឧក្រិដ្ឋកម្មរួម។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានសម្រេចថា "ការជួយ និងជម្រុញ គឺជាទម្រង់មួយនៃការទទួលខុសត្រូវដែលជាទូទៅគឺគួរតែទទួលការផ្តន្ទាទោសដែលស្រាលជាងទោស ដែលត្រូវទទួលខុសត្រូវក្នុងនាមជាសហចារី ដោយផ្អែកតាមន័យនេះ ត្រូវផ្តន្ទាទោសឱ្យធ្ងន់ជាងចំពោះបទរួមគ្នាប្រព្រឹត្ត (co-perpetration)[133]។ តុលាការ ICTR បានឈានទៅដល់ការធ្វើសេចក្តីសន្និដ្ឋានស្រដៀងគ្នានេះដែរ[134]។

---

[130] កថាខណ្ឌទី ៩៥ និយាយថា **ឌុច** បានបញ្ជាលើការធ្វើទារុណកម្ម ក៏ប៉ុន្តែទុកចំហរអំពីបញ្ហាថា តើគាត់បានបញ្ជាលើការធ្វើទារុណកម្មទាំងអស់ ឬក៏អត់?។ កថាខណ្ឌទី១០៧ បានឱ្យដឹងថា **ឌុច** គ្រាន់តែជាអ្នកបានបញ្ជាការសម្លាប់នានាដោយផ្ទាល់តែប៉ុណ្ណោះ ក្រោយពីមានឧប្បត្តិហេតុមួយដែលមានអ្នកទោសម្នាក់ត្រូវបានសម្លាប់នៅមុនពេលការសួរចម្លើយរបស់គាត់ត្រូវចប់សព្វគ្រប់ ។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះបានកត់សំគាល់អំពីថា មាន "បទបញ្ជាជាប្រចាំមួយដែលមិននិយាយច្បាស់លាស់" ពី **ឌុច** ឱ្យសម្លាប់រាល់អ្នកទោសទាំងអស់។ មិនមានភាពច្បាស់លាស់ទេថា តើការណ៍នេះនិងគ្របដណ្តប់ទៅលើការស្លាប់នៃអ្នកទោសដែលមិនត្រូវបានគេសម្លាប់ចោលទេ តែបានស្លាប់ដោយសារការអត់អាហារ ដោយសារជម្ងឺ ឬការធ្វើទារុណកម្មដែរឬទេ?

[131] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌទី ៦២-៧១។ កថាខណ្ឌទាំងនេះ មិនបានបញ្ជាក់ឱ្យបានច្បាស់លាស់ អំពីថាតើបញ្ជាណាខ្លះដែល **ឌុច** បានផ្តល់ ដែលទាក់ទងទៅនឹងលក្ខខណ្ឌនៃការឃុំឃាំង។

[132] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌទី ១៦១។

[133] ករណីរឿងរដ្ឋអាជ្ញា ទល់នឹង Mitar Vajilyevic ។ សាលដីកាលើបណ្តឹងឧទ្ធរណ៍។ សំណុំរឿងលេខ IT-38-92-A, ចុះថ្ងៃទី២៥ កុម្ភៈ ឆ្នាំ២០០៤ កថាខណ្ឌទី ១៨២។ ករណីរឿងរដ្ឋអាជ្ញា ទល់នឹង Radislav Krstic សាលដីកាលើបណ្តឹងឧទ្ធរណ៍នៃតុលាការ ICTY។ សំណុំរឿងលេខ IT-98-33-A, ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៤ កថាខណ្ឌទី ២៦៨១។ សាលក្រមនៃករណីរឿងក្តីរបស់ Tadic ត្រង់កថាខណ្ឌទី១៩២ ។ *សូមអានផងដែរ* ករណីរឿងក្តីរបស់ Ines Monica Weinberg de Roca និង Christopher M. Rassi *ដែលត្រូវបានផ្តន្ទាទោស និងឃុំខ្លួននៅក្នុងតុលាការពិសេស* សារពត៏មាន លេខ ៤៤ Standford Journal of International

៦៩. ក្រោមអត្ថន័យនៃពាក្យ **"ការទទួលខុសត្រូវរបស់ថ្នាក់លើ"** ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបានគ្របដណ្តប់ទៅលើគ្រប់ការប្រព្រឹត្តិអំពើឧក្រិដ្ឋទាំងអស់ដែលបានកើតមាននៅមន្ទីរស-២១។ ក៏ប៉ុន្តែការទទួលខុសត្រូវរបស់ថ្នាក់លើគឺជាទម្រង់នៃការទទួលខុសត្រូវមួយដែលមានលក្ខណៈស្រាលជាងសហកម្មឧក្រិដ្ឋកម្មរួម។ សហកម្មឧក្រិដ្ឋកម្មរួមតម្រូវឱ្យមានភស្តុតាងថាជនជាប់ចោទមានចេតនាចូលរួមក្នុងគោលបំណងឧក្រិដ្ឋកម្មរួម ហើយថាគាត់ពិតជាបានចូលរួមដើម្បីឱ្យសម្រេចគោលបំណងឧក្រិដ្ឋកម្មនោះ។ សហកម្មឧក្រិដ្ឋកម្មរួមជាទម្រង់នៃការប្រព្រឹត្តិឧក្រិដ្ឋដោយផ្ទាល់។ ផ្ទុយទៅវិញ ការទទួលខុសត្រូវរបស់ថ្នាក់លើមិនតម្រូវឱ្យថ្នាក់លើមានចេតនាប្រព្រឹត្តបទឧក្រិដ្ឋដោយកូនចៅរបស់គាត់ទេ ឬថាថ្នាក់លើនោះពិតជាបានចូលរួមយ៉ាងសំខាន់ចំពោះការប្រព្រឹត្តិបទឧក្រិដ្ឋរបស់កូនចៅខ្លួននោះទេ។ ដូចនេះ ដូចជាការជួយ និងជម្រុញដែរ ការទទួលខុសត្រូវរបស់ថ្នាក់លើជាទម្រង់នៃការទទួលខុសត្រូវស្រាលជាងសហកម្មឧក្រិដ្ឋកម្មរួម។

៧០. លើសពីនេះទៀត ការឱ្យជនត្រូវចោទទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ ដោយឈរលើមូលដ្ឋាននៃការទទួលខុសត្រូវរបស់ថ្នាក់លើ ទាមទារឱ្យមានភស្តុតាងអំពីធាតុផ្សំជាក់លាក់ ដែលភស្តុតាងនេះ មិនមែនជាភស្តុតាងចាំបាច់ នៃការទទួលខុសត្រូវក្នុងសហកម្មឧក្រិដ្ឋកម្មរួមទេ ដូចជា ការត្រួតត្រាយ៉ាងមានប្រសិទ្ធភាពចំពោះអ្នកនៅក្រោមបង្គាប់ ដែលបានប្រព្រឹត្ត ឬបំរុងនឹងប្រព្រឹត្តបទឧក្រិដ្ឋ។ ដូចក្នុងទម្រង់ផ្សេងៗទៀតនៃការទទួលខុសត្រូវដែរ ការខកខានមិនបានបញ្ជាក់ធាតុផ្សំទាំងនេះឱ្យបានច្បាស់លាស់ ដោយអនុវត្តទម្រង់នៃការទទួលខុសត្រូវនៃសហកម្មឧក្រិដ្ឋកម្មរួម នឹងបង្កើនលទ្ធភាពដែលថា **ឌុច** នឹងមិនត្រូវបានចោទប្រកាន់ឱ្យទទួលខុសត្រូវទាំងស្រុងចំពោះរាល់ទង្វើរបស់គាត់នោះទេ។

---

Law, ចុះថ្ងៃទី២៨ ឆ្នាំ២០០៨ (ដែលបានកត់សំគាល់ថា ការជួយ និងជម្រុញ គឺជាទម្រង់នៃការទទួលខុសត្រូវដែលស្រាលជាង សហកម្មឧក្រិដ្ឋកម្មរួម)។

[134] ករណីរឿងរដ្ឋអាជ្ញា ទល់នឹង Laurent Semanza អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR សំណុំរឿងលេខ ICTR-97-20-A ចុះថ្ងៃទី២០ ឧសភា ២០០៥ ត្រង់កថាខណ្ឌទី៣៨៨ (ដែលបានតម្លើងបន្ថែមទោសរបស់ជនជាប់ចោទ ដោយសារមូលហេតុថាគាត់ជាអ្នកទទួលខុសត្រូវក្នុងការឱ្យបញ្ជា ហើយដែលមិនមែនគ្រាន់តែជួយ និងជម្រុញក្នុងការសម្លាប់នៅឯព្រះវិហារ Musha Church តែប៉ុណ្ណោះនោះទេ។

៧១. ដូចដែលបានពិភាក្សាខាងលើស្រាប់ អំពើមួយចំនួនធំរបស់ជនត្រូវចោទដែលត្រូវបានរកឃើញនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួររបស់តុលាការនោះ ប្រហែលជាមិនមានលទ្ធភាពដើម្បីតភ្ជាប់គ្នាទៅនឹងឧក្រិដ្ឋកម្មដោយឡែកណាមួយបានទេ ហើយអាស្រ័យហេតុនេះ គឺអាចថាមិនចាំបាច់តម្រូវឱ្យអង្គជំនុំជម្រះសាលាដំបូងរកឱ្យឃើញ ដើម្បីបំពេញឱ្យបានគ្រប់គ្រាន់ទៅតាមលក្ខខណ្ឌតម្រូវអំពីអំពើពិរុទ្ធ (*actus reus*) ក្នុងការទទួលខុសត្រូវទៅលើការរៀបចំផែនការ បញ្ជា ញុះញង់ ឬជួយនិងជម្រុញនោះទេ។ ហេតុដូចនេះ ឧក្រិដ្ឋកម្មទាំងនេះមុខជានឹងត្រូវកន្លងផុតទៅដោយមិនបានធ្វើការផ្តន្ទាទោស ឬជាជំនួសឱ្យការផ្តន្ទាទោសនេះដោយការកំណត់ឱ្យទទួលខុសត្រូវបន្ទាប់បន្សំទៅវិញ ដែលអាចបណ្តាលឱ្យតុលាការធ្វើការផ្តន្ទាទោសក្នុងកំរិតស្រាលជាងដែលជាការមិនរំលេចឱ្យឃើញពិតប្រាកដអំពីពិរុទ្ធភាពរបស់ **ឌុច** នោះទេ។

## ឃ. អនុសាសន៍ក្នុងការធ្វើវិសោធនកម្មទៅលើ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ

៧២. អាស្រ័យហេតុនេះ ស្នើឱ្យអង្គបុរេជំនុំជម្រះ ធ្វើការកែប្រែទៅលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងធ្វើការចោទប្រកាន់ **ឌុច** ពីបទឧក្រិដ្ឋទាំងអស់តាមរយៈការប្រព្រឹត្តិនៅក្នុង សហកម្មឧក្រិដ្ឋកម្មរួម។ សូមជូនសេចក្តីសន្និដ្ឋានថា អង្គបុរេជំនុំជម្រះ មិនចាំបាច់ធ្វើការវាយតម្លៃលើភស្តុតាងទាំងឡាយដែលមាននៅក្នុងសំណុំរឿងនោះទេ ដោយសារ សហចៅក្រមស៊ើបអង្កេតបានរកឃើញរួចហើយថា អង្គហេតុនានាបានគាំទ្រចំពោះទ្រឹស្តីនៃការទទួលខុសត្រូវនេះ។ ហេតុដូចនេះ សហព្រះរាជអាជ្ញា ស្នើឱ្យធ្វើវិសោធនកម្មលើដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះ ដោយជំនួសកថាខណ្ឌ ១៥៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយកថាខណ្ឌដូចខាងក្រោម ដូចដែលសហព្រះរាជអាជ្ញាបានស្នើក្នុងដីកាសន្និដ្ឋានស្ថាពរ ដែលមានខ្លឹមសារដូចតទៅ៖

(ក) **ឌុច** បានធ្វើទារុណកម្ម និងធ្វើទុក្ខទោសចំពោះជនជាប់ឃុំនៅមន្ទីរ ស-២១ ដោយខ្លួនគាត់ផ្ទាល់ ក្នុងឱកាសដាច់ដោយឡែកពីគ្នាជាច្រើន និងដោយប្រើមធ្យោបាយខុសគ្នាក្នុងការធ្វើទារុណកម្ម។

(ខ) ឌុចបានប្រព្រឹត្តបទឧក្រិដ្ឋក្នុងនាមជាអ្នកចូលរួមក្នុងសហកម្មឧក្រិដ្ឋកម្មរួម ។ សហកម្មឧក្រិដ្ឋកម្មរួមមានអត្ថិភាពចាប់តាំងពីថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៥ នៅពេលដែល សុន សេន បានប្រាប់ ណាត និង **ឌុច** ឲ្យបង្កើតមន្ទីរ ស-២១[135]។ សហកម្មឧក្រិដ្ឋកម្មរួមចាប់មានអត្ថិភាពពី ខែតុលា ឆ្នាំ១៩៧៥[136] នៅពេលមន្ទីរស-២១ ចាប់ផ្តើមដំណើរការទាំងស្រុង រហូតដល់ថ្ងៃទី ០៦ ខែមករា ឆ្នាំ១៩៧៩ ជាពេលដែលរបបកម្ពុជាប្រជាធិប្បតេយ្យ ត្រូវដួលរលំ[137]។ គោលបំណងនៃសហកម្មឧក្រិដ្ឋកម្មរួមមាន ការអនុវត្តជាប្រព័ន្ធនូវការចាប់ខ្លួន ការឃុំឃាំង ការប្រព្រឹត្តិឃោរឃៅ ការសួរចម្លើយ ការធ្វើទារុណកម្ម និងការប្រហារជីវិត "ខ្មាំងសត្រូវ" របស់របបកម្ពុជាប្រជាធិប្បតេយ្យ[138] ដោយប្រព្រឹត្តបទឧក្រិដ្ឋដូចមាននៅក្នុងដីកាដំណោះស្រាយ។ ប្រព័ន្ធនៃការគាបសង្កត់ដែលមានការចាត់តាំង នៅមន្ទីរ ស-២១ មានអត្ថិភាពក្នុងអំឡុងពេលទាំងស្រុងនៃសហកម្មឧក្រិដ្ឋកម្មរួម[139]។ រាល់ឧក្រិដ្ឋកម្ម ទាំងអស់ ដែលកើតនៅមន្ទីរស-២១ ហើយបានរៀបរាប់ក្នុងដីកាដំណោះស្រាយនេះ គឺស្ថិតក្នុងគោលបំណងនៃសហកម្មឧក្រិដ្ឋកម្មរួម។

(គ) **ឌុច** បានចូលរួមប្រព្រឹត្តនៅក្នុងទូទាំងអំឡុងពេលដែលសហកម្មឧក្រិដ្ឋរួមនេះមានអត្ថិភាព[140] រួមគ្នាជាមួយនិងអ្នកចូលរួមដទៃៗទៀតនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួមនេះ ដែលពួកគេទាំងនោះបានចូលរួមនៅក្នុងរយៈពេលខុសៗពី

---

[135] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌទី ២០ ។

[136] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌទី ២១។

[137] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌទី ២៧ ។

[138] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌទី ៣១ ៣៣ និង ៣៧ ។

[139] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌទី ២៤ និង ចាប់ពី ៤៦ រហូតដល់ ១២៨ ។

[140] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌទី ២០-២៥ ២៧ ២៩ ៣១ ៣៣ ៣៧ ៣៨ ៤០-៤៥ ៥១-៥៩ ៦១ ៧០ ៧៤ ៧៩ ៨២-៨៧ ៩០-៩៩ ១០២ ១០៤ ១០៥ ១០៧-១១១ ១១៣ ១១៨ ១១៩ ១២១ និង ១២២ ។

គ្នាដោយរាប់បញ្ចូលទាំងអតីតលេខាមន្ទីរ ស-២១ ឈ្មោះ ណាត[141] និងសមាជិកដទៃៗទៀតនៃគណៈកម្មាធិការមន្ទីរ ស-២១ ពោលគឺ ឃឹម វ៉ាត ហៅ ហ៊ និង ហ៊ុយ ស្រែ ព្រមទាំងអ្នកនៅក្រោមបង្គាប់របស់ពួកគេផងដែរ[142] ។

(ឃ) **ឌុច** បានចូលរួមក្នុងសហកម្មឧក្រិដ្ឋកម្មរួមក្នុងនាមជា សហចារីមួយរូប។ **ឌុច** និងសមាជិកផ្សេងៗទៀតនៃសហកម្មឧក្រិដ្ឋកម្មរួម បានប្រព្រឹត្តដោយអនុលោមទៅតាមគោលបំណងរួម នេះនិងដោយមានចេតនារួមគ្នាមួយដើម្បីធ្វើឲ្យកើតមាននូវគោលបំណងរួមនេះ (ទម្រង់“ជាមូលដ្ឋាន”នៃសហកម្មឧក្រិដ្ឋកម្មរួម)។ លើសពីនេះទៀត **ឌុច** បានចូលរួមយ៉ាងសកម្មក្នុងការអនុវត្តនូវប្រព័ន្ធសម្រាប់ធ្វើការគាបសង្កត់នៅក្នុងមន្ទីរស-២១ ក្នុងឋានៈគាត់ជាអនុប្រធាន និងក្រោយមកជាប្រធាន។ **ឌុច** បានដឹងយ៉ាងច្បាស់អំពីស្ថានភាពនៃប្រព័ន្ធសម្រាប់ធ្វើការគាបសង្កត់នៅមន្ទីរ ស-២១នេះ។ ដោយរួមសហការគ្នាជាមួយសមាជិកផ្សេងៗទៀតនៃសហកម្មឧក្រិដ្ឋរួម **ឌុច** មានចេតនាពង្រីកប្រព័ន្ធសម្រាប់ធ្វើការគាបសង្កត់នេះបន្ថែមទៀតនៅមន្ទីរស-២១ (ទម្រង់ជា “ប្រព័ន្ធ” នៃសហកម្មឧក្រិដ្ឋកម្មរួម)។

(ង) ឬម៉្យាងទៀត ឧក្រិដ្ឋកម្មទាំងឡាយដែលបានរៀបរាប់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះ គឺជាផលវិបាកជា ទូទៅនិងអាចរំពឹងទុកជាមុនបាន នៃការអនុវត្តគោលបំណងនៃសហកម្មឧក្រិដ្ឋកម្មរួម។ **ឌុច** បានដឹងថា ឧក្រិដ្ឋកម្មទាំងនេះ គឺជាផលវិបាកដែលអាចនឹងកើតឡើងពីសហកម្មរួមរបស់មន្ទីរ ស-២១ និងដោយសារតែការដឹងបែបនេះហើយបានជា **ឌុច** សម្រេចចិត្តចូលរួមក្នុងសហកម្មឧក្រិដ្ឋរួមនេះ (ទម្រង់ “វិបុលកម្ម” នៃសហកម្មឧក្រិដ្ឋរួម)។ **ឌុច** អាចទាយទុកជាមុនថា ចារីពីខាងក្រៅដែលមានសក្តានុពលអាចនឹងប្រព្រឹត្តនូវឧក្រិដ្ឋកម្មឃោរឃៅ នៅក្នុងពេលបំពេញភារកិច្ចរបស់ពួកគេ ដែលទោះបីជាបានដឹងបែបនេះហើយក្តី ក៏គាត់នៅតែចូលរួមក្នុងសហកម្មនេះទៀត។

---

[141] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌទី ២០ ។

[142] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌទី ២២ និង ២៤ ។

00222078

D99/3/3

*សំណុំរឿងលេខ៖ ០០១/១៨-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ-០២)*

**៧. សំណើ**

៧៣. សហព្រះរាជអាជ្ញា ស្នើឲ្យ អង្គបុរេជំនុំជម្រះ ធ្វើការកែប្រែទៅលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយដាក់បញ្ចូលនូវបទល្មើស មនុស្សឃាត និង ទារុណកម្ម ព្រមទាំងការទទួលខុសត្រូវនៃសហកម្មឧក្រិដ្ឋកម្មរួមដូចដែលបានបញ្ជាក់ខាងលើ ។ សហព្រះរាជអាជ្ញា ស្នើឲ្យបញ្ជូនសំណុំរឿងទៅ អង្គជំនុំជម្រះសាលាដំបូង ដើម្បីធ្វើការជំនុំជម្រះ ។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
នៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៨
**សហព្រះរាជអាជ្ញា**

| | |
|---|---|
| **លោកស្រី ជា លាង** | **លោក** Robert PETIT |
| **សហព្រះរាជអាជ្ញា** | **សហព្រះរាជអាជ្ញា** |